ជា ស៊ុម៉េត

សំណួរ_ចម្លើយ

# សិក្សាសង្គម

## សីលធម៌ + ពលរដ្ឋវិជ្ជា
## គេហវិទ្យា

១០






ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

សៀវភៅសំណួរចម្លើយ "សីលធម៌-ពលរដ្ឋវិជ្ជា និងគេហវិទ្យា ថ្នាក់ទី១០" ដែលប្អូនកាន់នឹងដៃនេះ គឺត្រូវបានរៀប ចំឡើងដោយសមស្របទៅតាមកម្មវិធីថ្មីនៃក្រសួ-ងអប់រំយុវជន និងកីឡា ។ យ៉ាងណាមិញក្នុងសៀវភៅនេះគឺតម្រូវឱ្យប្អូនៗ ហាត់ឆ្លើយដោយខ្លួនឯងនូវសំណួរខ្លះ ពីព្រោះថាវាជាសំណួរដែល ទាមទារការមើលឃើញ និងគំនិតផ្ទាល់ខ្លួនរបស់យើង ។

ក្នុងនាមជាអ្នករៀបរៀង មានសេចក្តីរីករាយសោមនស្សនិងទទួលការរិះគន់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីស្នាបនាឱ្យស្នាដៃនេះ កាន់តែប្រសើរឡើង ។

សូមឱ្យការសិក្សារបស់អ្នកទទួលបាននូវភាពរីកចម្រើន និងទទួលបានជោគជ័យគ្រប់ពេលវេលា ។

*ភ្នំពេញថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១១*

*រៀបរៀងដោយ* **ជាស៊ីម៉េត**

ជំពូកទី ១ **តម្លៃមនុស្ស**

មេរៀនទី១ **ការច្នៃប្រឌិត**

## <u>សំណួរចម្លើយ</u>

1. តើគំនិតច្នៃប្រឌិតមានន័យដូចម្ដេច ?

<u>ចម្លើយ</u> គំនិតច្នៃប្រឌិត សំដៅយកគំនិតផ្ដួចផ្ដើមធ្វើអ្វីមួយ បង្កើតអ្វីមួយឱ្យលេចចេញជារូបរាង និងអាចប្រើប្រាស់តាមតម្រូវការរបស់ខ្លួន ។

2. តើគំនិតច្នៃប្រឌិតផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់គ្រួសារនិងសង្គម ?

<u>ចម្លើយ</u> គំនិតច្នៃប្រឌិតផ្ដល់ផលប្រយោជន៍ ដល់គ្រួសារនិងសង្គម ដូចជា៖

❖ *គ្រួសារ*

- ជួយបង្កើនការងារសម្រាប់សមាជិកក្នុងគ្រួសារដើម្បីមានប្រាក់ចំណូលសមរម្យ
- មានជីវភាពធូរធា

▪ពង្រឹងសមត្ថភាព ទេព្យកោសល្យ និងបទពិសោធន៍ដល់សមាជិកគ្រួសារ

❖ *សង្គម*

▪កាត់បន្ថយការនាំចូលពីក្រៅប្រទេស

▪បង្កើតការទុកចិត្តលើផលិតផលរបស់ខ្លួន

▪សម្បូរទៅដោយអ្នកមានសមត្ថភាព

▪មានការប្រកួតប្រជែងផលិតផលលើទីផ្សារអន្តរជាតិ

▪សេដ្ឋកិច្ចជាតិមានការរីកចម្រើន

▪ប្រទេសជាតិមានការអភិវឌ្ឍជឿនលឿន....។

3. តើគំនិតច្នៃប្រឌិតអាចជួយពង្រឹងសមត្ថភាពដល់អ្នកច្នៃប្រឌិត ឬទេ? ព្រោះ អ្វី ?

<u>ចម្លើយ</u> គំនិតច្នៃប្រឌិតអាចជួយពង្រឹងសមត្ថភាពដល់អ្នកច្នៃប្រឌិត ព្រោះ ការរកឃើញថ្មីកាន់តែធ្វើឱ្យអ្នកច្នៃប្រឌិតមានភាពប៉ិនប្រសប់ មានជំនាញច្បាស់លាស់ ភាពវៃឆ្លាត និងបទពិសោធល្អៗ សម្រាប់ខ្លួនឯងក៏ដូចជាចែកចាយដល់អ្នកដទៃ។

4. តើមូលហេតុអ្វីបានជាគេផ្តល់ការលើកទឹកចិត្ត ឬរង្វាន់ដល់អ្នកគំនិតច្នៃប្រឌិត និងរបកគំហើញថ្មី ?

<u>ចម្លើយ</u> បានជាគេផ្តល់ការលើកទឹកចិត្ត ឬរង្វាន់ដល់អ្នកគំនិតច្នៃប្រឌិត និងរបកគំហើញថ្មី ដើម្បីឱ្យអ្នកគំនិតច្នៃប្រឌិត និងរីករាយរំភើបចំពោះស្នាដៃរបស់ខ្លួនត្រូវបានគេទទួលស្គាល់ ។

5. តើមូលហេតុអ្វីបានជាគេផ្តល់ការលើកទឹកចិត្ត ឬរង្វាន់ដល់អ្នកមានគំនិតច្នៃប្រឌិត និងរបកគំហើញថ្មី ?

<u>ចម្លើយ</u> ដើម្បីឱ្យការច្នៃប្រឌិតមានការអភិវឌ្ឍ ត្រូវមានគោលការណ៍៖

- លើកទឹកចិត្តឱ្យមានការបង្កើតស្នាដៃក្នុងការឃោសនា ។ប្រសិនបើអ្នកអាចសម្តែងអារម្មណ៍និងស្នាដៃច្នៃប្រឌិតរបស់អ្នកតាមរយៈការគូរបកែច្នៃផ្សេងៗការតែងកំណាព្យ ចម្រៀង...អ្នកពុំគួររាំរែកទេ ។
- ចូរឱ្យតម្លៃលើកទឹកចិត្តដល់អ្នកខិតខំប្រឹងប្រែងបង្កើតស្នាដៃ និងច្នៃប្រឌិត ។ អាចអាចចុះផ្សាយអត្ថបទរបស់អ្នកក្នុងទំព័រកាសែត ឬធ្វើអត្ថបទទាំងនោះ ឱ្យគេបោះពុម្ព

➢ ចូរជម្រុញខ្លួនឯងឱ្យមានការច្នៃប្រឌិតខ្ពស់

➢ អនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឱ្យបានត្រឹមត្រូវ ...។

## មេរៀនទី២ **ការសម្រេចចិត្តដោយទទួលខុសត្រូវ**

<u>សំណួរចម្លើយ</u>

1. ចូរឱ្យនិយមន័យទំនួលខុសត្រូវ និងការសម្រេចចិត្ត ?

<u>ចម្លើយ</u>

➢ ***ទំនួលខុសត្រូវ***ជាកាតព្វកិច្ចដែលត្រូវរ៉ាប់រងនូវអំពើរបស់ខ្លួន នៅចំពោះមុខអំណាចជាន់ខ្ពស់ណាមួយ ។

➢ ***ការសម្រេចចិត្ត*** ជាការជ្រើសរើសនូវជម្រើសណាមួយដែលខ្លួនពេញចិត្ត ឬត្រូវការជាចាំបាច់ហើយវាជាសកម្មភាពការងារប្រចាំថ្ងៃរបស់យើង ។

2. តើផែនការនៃការសម្រេចចិត្តសំដៅយកអ្វីខ្លះ ?

<u>ចម្លើយ</u> ផែនការនៃការសម្រេចចិត្តសំដៅយក៖

- ការដោះស្រាយបញ្ហាណាមួយ
- ការរៀបចំផែនការសកម្មភាពលំអិតតូចៗ ឬសមាសភាពតូច និងចំណុចសំខាន់ៗ ។

3. តើមុនអ្នកធ្វើការសម្រេចចិត្តធ្វើអ្វីមួយ ត្រូវគិតដល់ចំណុចសំខាន់ៗអ្វីខ្លះ ?

<u>ចម្លើយ</u> មុនធ្វើការសម្រេចចិត្តធ្វើអ្វីមួយ គេត្រូវគិតដល់ចំណុចសំខាន់ៗដូចជា៖

- ☞ គម្រោងផែនការ និង គោលបំណងឱ្យបានគ្រប់គ្រាន់គ្រប់ជ្រុងជ្រោយ
- ☞ ពិនិត្យមើលទិន្នន័យដែលពាក់ព័ន្ធ
- ☞ កំណត់គោលបំណង និងផែនការសកម្មភាពរបស់ខ្លួនសមស្របនឹងពេលវេលាកំណត់មួយ
- ☞ ចំណុចវិជ្ជមាន និងអវិជ្ជមាន (ហេតុផលត្រឹមត្រូវ)
- ☞ កំណត់ពីភាពខ្លាំងនិងភាពខ្សោយរបស់ខ្លួនឱ្យបានច្បាស់
- ☞ ច្បាប់សង្គម....។

4. តើការសម្រេចចិត្តដែលមានការទទួលខុសត្រូវខ្ពស់ត្រូវធ្វើដូចម្តេច ?

<u>ចម្លើយ</u> ការសម្រេចចិត្តដែលមានការទទួលខុសត្រូវខ្ពស់ត្រូវធ្វើតាមពេលកំណត់ លទ្ធផលដែលទទួលបានត្រូវដល់គោល

ដៅទាំងបរិមាណ និងគុណភាព ។ បើមានឧបសគ្គត្រូវរិះរកមធ្យោបាយដោះស្រាយឱ្យទាន់ពេលវេលា ។ ត្រូវស្វែងរកចំណុចខ្លាំងនិងចំណុចខ្សោយ និងរកវិធីសាស្ត្រផ្សេងៗ ព្រមទាំងមានការវាយតម្លៃលើការងាររបស់ខ្លួន ។

5. ដូចម្តេចដែលហៅថា ការកំណត់អាទិភាព ?

<u>ចម្លើយ</u> ដែលហៅថា*ការកំណត់អាទិភាព* គឺជាការជ្រើសរើសអ្វីដែលត្រូវមុន ឬសម្រេចចិត្តធ្វើមុន ឬអ្វីដែលត្រូវបន្ទាប់ដោយផ្អែកលើសារៈសំខាន់នៃកិច្ចការ និងតម្រូវការចាំបាច់របស់យើង ។

6. តើការកំណត់អាទិភាពមានចំណុចសំខាន់អ្វីខ្លះ ?

<u>ចម្លើយ</u> ការកំណត់អាទិភាពមានចំណុចសំខាន់ដូចជា៖

- រកឱ្យឃើញថា តើចង់បានអ្វីពិតប្រាកដក្នុងឆាកជីវិត ឬស្ថានភាពពិសេសណាមួយដែលជីវិតយើងត្រូវការ ។
- យើងត្រូវរៀបចំគោលដៅនៃជីវិតឱ្យបានច្បាស់លាស់តាមលំដាប់លំដោយនៃសារៈសំខាន់របស់វា ។ យើងត្រូវជ្រើសរើសនិងការសម្រេចចិត្តចំ ពោះគោលដៅខ្លះ ឬអាចទុកមួយរយៈសិនព្រោះ គោលដៅនីមួយៗត្រូវគិត

ពិចារណា ពីភាពលំបាក និងវិសាលភាពនៃអាទិភាពនោះ ។

7. ប្រសិនបើអ្នកសម្រេចចង់ធ្វើអ្វីមួយ តើអ្នកត្រូវគិតលើបញ្ហាអ្វីខ្លះ?

<u>ចម្លើយ</u> ប្រសិនបើអ្នកសម្រេចចង់ធ្វើអ្វីមួយយើងត្រូវគិតលើបញ្ហាដូចជា៖

- ➢ កំណត់អាទិភាព
- ➢ ឧបសគ្គ និងដំណើរការអាចធ្វើទៅបាន
- ➢ ពិចារណាលើមូលហេតុនិងហេតុផលឱ្យបានត្រឹមត្រូវ
- ➢ ត្រូវធ្វើជំហានមួយណាមុនគេ បន្ទាប់មកគិតលើការងារអ្វីដែលនៅសល់ក្នុងពេលវេលាសមស្រប។

8. តើការសម្រេចចិត្តប្រភេទណាខ្លះ ដែលប៉ះពាល់ដល់អនាគត ?

<u>ចម្លើយ</u> ការសម្រេចចិត្ត ដែលប៉ះពាល់ដល់អនាគត គឺ ការសម្រេចចិត្តខុសដែលមិនបានគិតគូពី អាទិភាពភាពដែលអាចធ្វើបាន និង ផលវិបាកផ្សេងៗ ។

9. ចូរបង្ហាញពីផលប្រយោជន៍នៃការសម្រេចចិត្តត្រឹមត្រូវ ។

ចម្លើយ បង្ហាញពីផលប្រយោជន៍នៃការសម្រេចចិត្តត្រឹមត្រូវ ៖

- គ្មានវិប្បដិសារី និងមានភាពសប្បាយរីករាយ
- ទទួលបានជោគជ័យច្រើន
- ធ្វើឱ្យខ្លួនឯងមានតម្លៃ និងសេចក្តីថ្លៃថ្នូរ
- ទទួលបានការសរសើររាប់អានពីមជ្ឈដ្ឋានជុំវិញ
- ធ្វើឱ្យជីវិតមានន័យ និងអនាគតល្អ...។

## មេរៀនទី៣ ការជួយគាំទ្រគ្នាដោយភាតរភាព

### សំណួរចម្លើយ

1. ដូចម្តេចដែលហៅថា ការអត់ឱនដោយភាតរភាព ?

ចម្លើយ ដែលហៅថា ការអត់ឱនដោយភាតរភាព គឺជាបំណងល្អដែលកើតចេញការយោគយល់អធ្យាស្រ័យ សន្តោសប្រណីនិងស្រឡាញ់រាប់អានគ្នាដូចបងប្អូន និងនិយាយរកគ្នាដោយក្តីស្រឡាញ់ និងចេះសង្គ្រោះគ្នាទៅវិញទៅមក ។

2. តើប្អូនត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានសេចក្តីសុខសុភមង្គលក្នុងគ្រួសាររបស់ប្អូន ?

ចម្លើយ ដើម្បីទទួលបានសេចក្តីសុខ សុភមង្គល ក្នុងគ្រួសារ យើងត្រូវ ៖

- ចេះជួយធុរៈគ្នា គោរព យោគយល់អធ្យាស្រ័យ និងសន្តោសប្រណីគ្នាទៅវិញទៅមក
- ផ្តល់ក្តីស្រឡាញ់ ភាពកក់ក្តៅមិនត្រូវច្រណែនឈ្នានីសឡើយ
- អប់រំចរិយាសម្បត្តិ និងណែនាំនូវកំហុសខុសឆ្គង
- មានភាពឧស្សាហ៍ព្យាយាមទាំងការងារនិងការរៀនសូត្រ
- ត្រូវប្រើពាក្យសម្តីសមរម្យ នៅក្នុងគ្រួសារនិងអ្នកជិតខាង (គោរពគ្នា)....។

3. ហេតុអ្វីបានជាគេនិយាយថា ការកែប្រែមិត្តភក្តិប្រាសចាកអំពើអាវាសែជាសកម្មភាពចូលរួមអភិវឌ្ឍជាតិ ?

ចម្លើយ៖ បានជាគេនិយាយថា ការកែប្រែមិត្តភក្តិប្រាសចាកអំពើអាវាសែជាសកម្មភាពចូលរួមអភិវឌ្ឍជាតិ ព្រោះជាការកែប្រែពួកគេឱ្យក្លាយជាមនុស្សល្អ ត្រឹមត្រូវមានសុជីវធម៌ គោរពច្បាប់សង្គម ។ មានន័យថាពួកគេមិនប្រព្រឹត្តអំពើអាក្រក់ដែល

ធ្វើបានមានភាពអសន្តិសុខសង្គម បាត់បង់សណ្តាប់ធ្នាប់សង្គមគឺធ្វើអោយប្រទេសជាតិទាំងមូលមានភាពសុខសាន្តនិងមានការអភិវឌ្ឍ ។

4. តើអ្នកគិតថា អ្នកជិតខាងមានសារៈសំខាន់ចំពោះអ្នកដែរឬទេ ? ព្រោះអ្វី ?

<u>ចម្លើយ</u> ខ្ញុំគិតថា អ្នកជិតខាងមានសារៈសំខាន់ណាស់ ព្រោះថាអ្នកជិតខាងជាមិត្តភក្តិសំខាន់គួររាប់អាន និងអាចជួយទុក្ខធុរៈយើងទាន់ពេលវេលា និងជួយឈឺឆ្អាលយើងដូចបងប្អូនបង្កើតដែរ ។ អ្នកជិតខាងជាអ្នកដែលជួយគាំទ្រ រាប់អានហើយយើងក៏ទទួលបានសេចក្តីសុខ ភាពកក់ក្តៅ ដូចជាក្រុមគ្រួសារយើងដែរ ។

5. ចូររៀបរាប់ពីសារៈសំខាន់នៃការអត់ឱននិងជួយកែលំអក្នុងគ្រួសារនិងសង្គម ។

<u>ចម្លើយ</u> សារៈសំខាន់នៃការអត់ឱននិងជួយកែលំអក្នុងគ្រួសារនិងសង្គម ៖

➢ *គ្រួសារ*

▪ មានភាពកក់ក្តៅ ការស្រឡាញ់ ភាពស្និទ្ធស្នាល សាមគ្គី

▪ មានចរិយាសម្បត្តិល្អ និងសុជីវធម៌

▪ មានសេចក្តីថ្លៃថ្នូរនៅក្នុងគ្រួសារ

▪ គ្រួសារមានសុភមង្គល ចៀសផុតពីអំពើហិង្សា

➢ *សង្គម*

▪ មានសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ

▪ មានសេចក្តីថ្លៃថ្នូរ សីលធម៌ និងទទួលបានការសរសើរ រាប់អានពីបរទេស

▪ មានភាពរីកចម្រើនជឿនលឿន

មេរៀនទី៤ **ការរស់នៅថ្លៃថ្នូរ**

<u>សំណួរចម្លើយ</u>

1. ដូចម្តេចដែលហៅថា អំពើហិង្សា ?

<u>ចម្លើយ</u> ដែលហៅថា *អំពើហិង្សា* គឺសំដៅយកការរំលោភបំពាន ឬបង្ខិតបង្ខំផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ផ្លូវសេដ្ឋកិច្ច រួមបញ្ចូលទាំងការប្រមាថមាក់ងាយ ការគំរាមកំហែងការដាក់ឱ្យនៅឯកោពីគេឯង និងការរំលោភបំពានផ្នែកជីវភាពសេដ្ឋកិច្ច ពីសំណាក់បុគ្គលម្នាក់ ឬច្រើនដើម្បីត្រួតត្រាទៅលើបុគ្គលផ្សេងៗទៀត ។

2. តើអំពើហិង្សាអាចប៉ះពាល់ដល់មនុស្សទូទៅលើផ្នែកអ្វីខ្លះ ?

<u>ចម្លើយ</u> អំពើហិង្សាអាចប៉ះពាល់ដល់មនុស្សទូទៅលើផ្នែកផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងជីវភាពសេដ្ឋកិច្ច ។

3. តើមនុស្សថ្លៃថ្នូរត្រូវមានឥរិយាបថដូចម្តេចខ្លះចំពោះគ្រួសារ ?

ចម្លើយ មនុស្សថ្លៃថ្នូរត្រូវមានឥរិយាបថ ចំពោះគ្រួសារ ដូចជា៖

- ត្រូវចេះស្រឡាញ់ អាណិត និងគោរពគ្នាទៅវិញទៅមក
- គោរពសិទ្ធិគ្នាទៅវិញទៅមក
- មានទំនួលខុសត្រូវនូវទង្វើដែលខ្លួនបានធ្វើ
- ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិន័យ និងច្បាប់សង្គម
- ចេះយល់ទុក្ខធុរៈ យល់ចិត្តអារម្មណ៍មនុស្សនៅក្នុងគ្រួសារ
- មិនត្រូវប្រើអំណាចរបស់ខ្លួនគាបសង្កត់លើអ្នកដទៃ
- ប្រាកចាកនូវអំពើអបាយមុខ និងសេពគ្រឿងញៀនគ្រប់ប្រភេទ
- ចេះប្រើប្រាស់ថវិកាសមស្របតាមចំណូលគ្រួសារ
- មិនជឿពាក្យអុចអាល ញុះញង់ពីអ្នកដទៃ
- ត្រូវប្រកបរបរសុចរិត ...។

4. តើមនុស្សថ្លៃថ្នូរត្រូវមានឥរិយាបថដូចម្តេចខ្លះចំពោះគ្រួសារ ?

ចម្លើយ វិធានការ ដើម្បីទប់ស្កាត់អំពើហិង្សា គឺៈ

- ✧ ផ្សព្វផ្សាយច្បាប់ស្តីពីអំពើហិង្សាឱ្យបានដឹងគ្រប់ៗគ្នា

✧ ដាក់ទណ្ឌកម្មដល់អ្នករំលោភច្បាប់ និងប្រើអំពើហិង្សា

✧ ធ្វើអន្តរាគមន៍តាមច្បាប់ឱ្យមានប្រសិទ្ធភាព ពេលមានអំពើហិង្សាក្នុងគ្រួសារ

✧ ការពារផ្លូវច្បាប់ជាបន្ទាន់ដោយតុលាការ

✧ ផ្តល់ព័ត៌មានដល់ជនរងគ្រោះ

✧ អាជ្ញាធរដែនដីធ្វើអន្តរាគមន៍ជាបន្ទាន់រាល់អំពើហិង្សាដែលកើតមានឡើង

✧ ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈនិងធានាសុវត្ថិភាព

✧ បង្វែរជនមុខសញ្ញា និងជនរងគ្រោះពីកន្លែងកើតហេតុក្នុងករណីកំពុងកើតហេតុ ។

5. តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកជាអំពើហិង្សាផ្នែកសេដ្ឋកិច្ច ?

<u>ចម្លើយ</u> សកម្មភាព ដែលចាត់ទុកជាអំពើហិង្សាផ្នែកសេដ្ឋកិច្ចមានដូចជា ៖

- ការគាបសង្កត់ពុំផ្តល់លុយឱ្យប្រពន្ធឬប្តី ដើម្បីរ៉ាប់រងការចំណាយផ្សេងៗរបស់គ្រួសារ

▪ការបង្អិតបង្ខំដល់ជនរងគ្រោះ ដើម្បីយកលុយកាក់ឱ្យខ្លួន ក្រោមលក្ខខណ្ឌរបស់ខ្លួនពុំសមហេតុផល...។

6. តើគ្រួសារដែលមានអំពើហិង្សាអាចអភិវឌ្ឍជីវភាពគ្រួសារបានដែរឬទេ ? ព្រោះអ្វី ?

<u>ចម្លើយ</u> គ្រួសារដែលមានអំពើហិង្សាមិនអាចអភិវឌ្ឍជីវភាពគ្រួសារបានទេព្រោះអំពើហិង្សាបង្កឱ្យមានផលលំបាកច្រើន ដូចជាការបាត់បង់ភាពស្និទ្ធស្នាល ព្រាត់ប្រាស នៅក្នុងគ្រួសារខាតបង់ប្រាក់កាសទិញថ្នាំព្យាបាលមុខរបួស ភាពមានអាម៉ាស់ក្នុងសង្គម កូនខ្វះភាពកក់ក្តៅ ពីអាណាព្យាបាល និងមិនបានទៅរៀនសូត្រ គ្រួសារគ្មានសុភមង្គល... ។

7. តើសង្គមជាតិមួយសម្បូរអំពើហិង្សាកើតឡើង តើសង្គមជាតិនោះ អាចអភិវឌ្ឍប្រទេសបានដែរឬទេ ? ព្រោះអ្វី ?

<u>ចម្លើយ</u> សង្គមជាតិមួយសម្បូរអំពើហិង្សាកើតឡើងសង្គមជាតិនោះមិន អាចអភិវឌ្ឍប្រទេសទេ ព្រោះវានឹងធ្វើឱ្យប្រទេសនោះសម្បូរដោយមនុស្សឯកោបាត់បង់ទំនុកចិត្ត ភាពកក់ក្តៅ និងជួបតែភាពព្រាត់ប្រាស់ពីក្រុមគ្រួសារ ។ គ្មានសាមគ្គីភាព និង

ធ្វើឱ្យសេដ្ឋកិច្ចសង្គមធ្លាក់ចុះ ជាហេតុនាំឱ្យប្រទេសជាតិគ្មានការរីកចម្រើន ។

## មេរៀនទី៥ **សីលធម៌ និងតម្លៃមនុស្ស**

### <u>សំណួរចម្លើយ</u>

1. ដូចម្ដេចដែលហៅថា សីលធម៌ ?

<u>ចម្លើយ</u> ដែលហៅថា ***សីលធម៌*** សំគាល់នូវទ្រឹស្ដីទាំងឡាយណាដែលនាំឱ្យមនុស្សប្រព្រឹត្តតែអំពើល្អ ឬដំបូន្មានទាំងឡាយណាដែលនាំគឺជាមនសិការក្រមច្បាប់វប្បធម៌នៃសកម្មភាពសង្គមដែលជ្រាបចូលទៅក្នុងបុគ្គលម្នាក់ៗ ។

2. តើសកម្មភាពឬ អំពើអ្វីខ្លះដែលគេចាត់ទុកថាជាអំពើប្រកបដោយសីលធម៌ ?

<u>ចម្លើយ</u> សកម្មភាពឬ អំពើ ដែលគេចាត់ទុកថា ជាអំពើប្រកបដោយសីលធម៌៖

- ការមានទំនាក់ទំនងល្អជាមួយអ្នកដទៃ
- ការគោរពសិទ្ធិអ្នកដទៃ

- សុភាពរាបសារ
- ចេះគួរសមពាក្យសម្ដី
- ចែករំលែក និងជួយយកអសារគ្នាទៅវិញទៅមក
- ការចេះផ្ដល់អទិភាព ដល់ចាស់ព្រឹទ្ធាចារ្យ ...។

3. ចូរសង្កេតលើសកម្មភាពប្រចាំថ្ងៃ តើមានអំពើឬសកម្មភាពអ្វីខ្លះជាអំពើអសីលធម៌ ?

<u>ចម្លើយ</u> សង្កេតលើសកម្មភាពប្រចាំថ្ងៃ អំពើឬ សកម្មភាពជាអំពើអសីលធម៌ មាន៖

- ការលួចឆក់ប្លន់
- ការ និយាយភូតភរ បោកប្រាស
- កេងប្រវ័ញ្ច ពុករលួយ
- ការរំលោភបំពាន
- អំពើហិង្សា
- ការបំពានលើច្បាប់ (ចរាចរណ៍ ...) ។

4. ហេតុអ្វីបានជាមនុស្សខ្លះ នៅតែប្រព្រឹត្តអំពើអសីលធម៌ ?

<u>ចម្លើយ</u> បានជាមនុស្សខ្លះ នៅតែប្រព្រឹត្តអំពើអសីលធម៌ ព្រោះមនុស្សនោះ ខ្វះការអប់រំ មានចំណេះដឹងតិចតួច គ្មានការ

ពិចារណាត្រឹមត្រូវ សង្គមលំហូរចូលនូវវប្បធម៌មិនល្អពីបរទេសការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើបៗ ។

5. ចូរឱ្យឧទាហរណ៍លើការប្រព្រឹត្តអំពើល្អ ទាំងផ្លូវកាយ វាចា និងផ្លូវចិត្ត ។

ចម្លើយ ឧទាហរណ៍លើការប្រព្រឹត្តអំពើល្អ ទាំងផ្លូវកាយ វាចានិងផ្លូវចិត្ត ៖

❖ *ផ្លូវចិត្ត*

- ការលើកទឹកចិត្តគ្នា (ផ្តល់កម្លាំងចិត្ត)
- ការសរសើរពីទង្វើអ្វីមួយដែលធ្វើបានសម្រេច
- ការស្រលាញ់លួងលោមឱ្យមានក្តីសង្ឃឹម និងភាពសប្បាយរីករាយ...។

❖ *ផ្លូវកាយ*

- ការជួយថែទាំ និងសម្រួលការងារគ្នាទៅវិញទៅមក
- ការប្រើពាក្យសម្តីទន់ភ្លន់ មិនគំរោះគំរើយទៅកាន់អ្នកដទៃ
- ការចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើអបាយមុខអំពើហិង្សាគ្រឿងញៀន

▪ការចូលរួមធ្វើយុទ្ធនាការប្រឆាំងអំពើខុសច្បាប់ ...។

6. តើការធ្លាក់ចុះនៃតម្លៃសីលធម៌របស់មនុស្សបណ្តាលមកពីមូលហេតុអ្វីខ្លះ?

ចម្លើយ ការធ្លាក់ចុះនៃតម្លៃសីលធម៌របស់មនុស្សបណ្តាលមកពីមូលហេតុដូចជា ៖

▪ប្រព័ន្ធអប់រំនៅមានកម្រិត (កម្រិតការយល់ដឹងទាប)

▪ការផ្សព្វផ្សាយពីសីលធម៌មិនទាន់បានទូលំទូលាយ

▪ការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យាទំនើបៗ

▪ការលំហូរចូលនៃវប្បធម៌មិនល្អ ពីបរទេស

▪ច្បាប់សង្គមធូររលុង...។

7. តើវិទ្យាសាស្ត្រផ្តល់គុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ដល់សីលធម៌រស់នៅរបស់មនុស្ស ?

ចម្លើយ វិទ្យាសាស្ត្រផ្តល់គុណសម្បត្តិ និងគុណវិបត្តិដល់សីលធម៌រស់នៅរបស់មនុស្ស ដូចជា ៖

❖ *គុណសម្បត្តិ*

▪ទទួលបានចំណេះដឹងច្រើន

▪ទាន់សម័យ និងរីកចម្រើន

- ស្គាល់ពីភាពខុសគ្នានៃវប្បធម៌ខ្លួនឯង និងបរទេស
- ទទួលយកវប្បធម៌ផ្សេងៗ

❖ *គុណវិបត្តិ*

- អាចបង្កឱ្យមានអំពើមិនល្អ ការប្រើប្រាស់គ្រឿង ល្បែងស៊ីសង ...
- មនុស្សភ្លើតភ្លើនច្រើន (ម៉ូតសម្លៀកបំពាក់ សក់ ការគោរព...)
- បាត់បង់នូវអ្វីដែលជាអត្តសញ្ញាណសីលធម៌ (វប្បធម៌ ទំនៀមទម្លាប់...)...។

8. តើសីលធម៌មានសារៈសំខាន់យ៉ាងណាខ្លះ ចំពោះជីវភាពរស់នៅរបស់មនុស្ស ?

<u>ចម្លើយ</u> សីលធម៌មានសារៈសំខាន់ណាស់ ចំពោះជីវភាពរស់នៅរបស់មនុស្ស ព្រោះសីលធម៌ធ្វើឱ្យមនុស្សមានសេចក្ដីថ្លៃថ្នូរ មានការគោរពស្រឡាញ់អាណិតអាសូរចំពោះគ្នាទៅវិញទៅមក ។ មិនត្រឹមតែប៉ុណ្ណោះ ធ្វើឱ្យមនុស្សទាំងអស់មានសេចក្ដីសុខសន្តិភាព គ្មានជម្លោះ និងអំពើហិង្សាឡើយ ។

មេរៀនទី៦ **សុជីវធម៌**

## សំណួរចម្លើយ

1. ចូរឱ្យនិយមន័យសុជីវធម៌និងលើកឧទាហរណ៍មកបង្ហាញ

ចម្លើយ និយមន័យសុជីវធម៌ គឺ សម្គាល់នូវការរស់នៅល្អ មានរបៀបរៀបរយ ចេះគួរសមក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ។ ឧទាហរណ៍៖ ការទទួលភ្ញៀវដោយស្ញសរាយរាក់ទាក់ ស្លៀកពាក់ឱ្យបានសមរម្យទៅតាមពេលវេលា ...។

2. តើសុជីវធម៌ចំពោះខ្លួន ឯងមានអ្វីខ្លះ ? ចូររៀបរាប់ ។

ចម្លើយ សុជីវធម៌ចំពោះខ្លួន ឯងមាន មានដូចជា ៖

- ការសម្អាតខ្លួនប្រាណឱ្យបានស្អាត និងមានសោភ័ណភាពឱ្យបានទៀង
- ការស្លៀកពាក់ឱ្យបានសមរម្យ និងស្របតាមកាលៈទេសៈ
- មានអនាម័យ ថែទាំសុខភាពបានល្អ កុំឱ្យបានមានក្លិនមិនល្អទៅកាន់អ្នកដទៃ។

3. តើមនុស្សគ្រប់រូបនៅក្នុងសង្គមបច្ចុប្បន្ន ត្រូវការប្រកាន់ខ្ជាប់នូវសុជីវធម៌ ដែរឬទេ ? ហេតុអ្វី ?

<u>ចម្លើយ</u> មនុស្សគ្រប់រូបនៅក្នុងសង្គមបច្ចុប្បន្ន ត្រូវការប្រកាន់ខ្ជាប់នូវសុជីវធម៌ ព្រោះសុជីវធម៌ធ្វើឱ្យមនុស្សមានឫកពារល្អ មិនឆ្គាំឆ្គងក្នុងទង្វើរបស់ខ្លួននៅពេលធម្មតា និងពេលចេញមុខក្នុងពិធី ។ សុជីវធម៌ធ្វើឱ្យអត្តចរិតស្លូតបូតសមរម្យ មានភាពថ្លៃថ្នូរ មានទំនាក់ទំនងល្អ និងរស់នៅចុះសម្រុងជាមួយអ្នកដទៃនៅក្នុងសង្គម ។

4. ចូរអ្នកសង្កេតសកម្មភាពរបស់មនុស្សសព្វថ្ងៃហើយបង្ហាញលក្ខណៈ នៃមនុស្សមានសុជីវធម៌ល្អ និងមនុស្សគ្មានសុជីវធម៌ ព្រមទាំងចំណុចពីរដែលត្រូវកែប្រែចំពោះមនុស្សគ្មានសុជីវធម៌ ។

<u>ចម្លើយ</u> សកម្មភាពរបស់មនុស្សសព្វថ្ងៃមានសុជីវធម៌ល្អ និងមនុស្សគ្មានសុជីវធម៌ ព្រមទាំងចំណុចពីរដែលត្រូវកែប្រែចំពោះមនុស្សគ្មានសុជីវធម៌ ។

## ២. *សុជីវធម៌ល្អ*

- ការគោរពសញ្ញាចរាចរណ៍

- ប្រើពាក្យគួរសមទៅកាន់អ្នកដទៃដូចជា អរគុណ សុំទោស
- ជួយដឹកដៃមនុស្សចាស់ឆ្លងផ្លូវ
- ពេលជួបចាស់ព្រឹទ្ធាចារ្យ ឬនៅចូលក្នុងវត្ត ដោះមួក
- លើកដៃសំពះជម្រាបសួរ ។ល។

២. *គ្មានសុជីវធម៌*

- មើលងាយ ឬរើសអើងជនពិការ មេរោគអេដស៍
- ចោលសម្រាមពាសវាលពាសកាល
- ការខាកស្ដោះក្នុងទីសាធារណៈ
- ប្រើពាក្យសម្ដីគំរោះគំរើយ ឬអាសអាភាស
- លួច ឆក់ ទ្រព្យសម្បត្តិអ្នកដទៃ
- ភូតកុហកគេ ...។

៦. *ចំណុចពីរដែលត្រូវតែប្រែចំពោះអ្នកគ្មានសុជីវធម៌គឺៈ*

➢ ណែនាំអប់រំជននោះឱ្យយល់ដឹងអំពីក្បួនសុជីវធម៌
➢ បង្កើតច្បាប់ឬដាក់ពិន័យលើជននោះ កុំឱ្យគេប្រព្រឹត្តអំពើរបៀបនោះទៀត...។

5. ចូរអ្នកសរសេររៀបរាប់ពីសុជីវធម៌ពេលធ្វើដំណើរតាមរថយន្តឈ្នួល ក្នុងទី វត្ត ឬកន្លែងសក្ការៈបូជាពេលបរិភោគនៅទីកន្លែងសាធារណៈ នៅតាមផ្លូវថ្នល់និង នៅក្នុងពិធីបុណ្យផ្សេងៗ។រៀបរាប់ពីសុជីវធម៌ពេលធ្វើដំណើរតាមរថយន្តឈ្នួល ក្នុងទី វត្ត ឬកន្លែងសក្ការៈបូជាពេលបរិភោគនៅទីកន្លែងសាធារណៈនៅតាមផ្លូវថ្នល់និង នៅក្នុងពិធីបុណ្យផ្សេងៗ ៖

✧ *តាមរថយន្តឈ្នួលៈ* ត្រូវអង្គុយអោយមានរបៀបរៀបរយ មិនច្រងេងច្រងាង ហើយផ្តល់អាទិភាពដល់ចាស់ព្រឹទ្ធាចារ្យឱ្យគាត់អង្គុយបានស្រួល ។ យើងមិនត្រូវបរិភោគចំណីអាហារ ដែលជាហេតុធ្វើឱ្យមានក្លិនមិនល្អប៉ះពាល់ដល់អ្នកដទៃឡើយ ។

✧ *ក្នុងទីវត្តឬកន្លែងសក្ការៈបូជាៈ* ត្រូវរក្សាភាពស្ងៀមស្ងាត់ស្លៀកពាក់ឱ្យបានសមរម្យ មិនត្រូវពាក់មួកនោះទេ ។

✧ *ពេលបរិភោគអាហារៈ* ត្រូវចៀសវាងការខាកស្តោះឬព្រូសមាយនៅមុខគេឯងពេលបរិភោគអាហារ មិនត្រូវនិយាយពាក្យគួរឱ្យខ្ពើម (អាចម៍ ក្អួត ) ឡើយ ។

...

ចំពោះការជួសអាហារបរិភោគគឺ ត្រូវមើលគេមើលឯង មិនមែនចេះតែជួសដើម្បីចម្អែតក្រពះតែខ្លួនឯងនោះទេ

- *នៅទីសាធារណៈ:* មិនត្រូវបោះសម្រាមចោលផ្តេសផ្តាសដែលជាហេតុនាំឱ្យបាត់បង់សោភ័ណភាព ស្រែកឡូឡាឥតសណ្តាប់ធ្នាប់ ខាកស្តោះ គឺត្រូវគោរពសិទ្ធិអ្នកដទៃ ។
- *នៅតាមផ្លូវថ្នល់:* យើងត្រូវចេះផ្តល់អាទិភាពចំពោះអ្នកដំណើរដទៃទៀត មិនត្រូវប្រជែងយកឈ្នះបានទៅមុនគេឯងនោះទេ គឺត្រូវគោរពច្បាប់ឬសញ្ញាចរាចរណ៍ ។ ម្យ៉ាងទៀតប្រសិន បើឃើញមានស្ត្រីមានផ្ទៃពោះ ជនពិការ ឬចាស់ព្រឹទ្ធាចាស់ឆ្លងផ្លូវ ត្រូវជួយចម្លង។យើងក៏មិនត្រូវដើរឆ្វេចឆ្វាច ឬចោលសម្រាមលើផ្លូវថ្នល់នោះទេ។ក្នុងពិធីបុណ្យផ្សេងៗ យើងត្រូវស្លៀកពាក់ឱ្យបានសមរម្យ មានសុជីវធម៌ក្នុងការទទួលស្វាគមន៍ ឬគោរពដូចជា ការលើកដៃសំពះឱនក្បាល ...។

# សំណួរបញ្ចប់ជំពូក១

I. ចូរគូសសញ្ញា ✓ ឬ × ខាងមុខឃ្លាខាងក្រោម

១. —— ការច្នៃប្រឌិតសំដៅគំនិតផ្ដួចផ្ដើមធ្វើអ្វីមួយ ដោយប្រើធនធានមានស្រាប់ ថវិកាតិច និង ស្របតាមតម្រូវការរបស់ខ្លួន ។

២.—— មនុស្សគ្រប់រូបត្រូវខិតខំរកប្រាក់ព្រោះវាផ្ដល់កិត្តិយសដល់យើងទោះវិធីណាក៏ដោយ ។

៣. ——ការឈ្លោះប្រកែកគ្នានៅក្នុងគ្រួសារជារឿងធម្មតារបស់មនុស្ស ។

៤. —— អំពើហិង្សាកើតឡើងតែចំពោះអ្នកក្រប៉ុណ្ណោះ ។

៥. —— មនុស្សមានសីលធម៌ល្អដោយពូជពង្សពីកំណើត ។

៦. —— ដើម្បីបន្ថយភាពតានតឹងក្នុងចិត្ត គួរផឹកស្រា ជក់បារី សេពគ្រឿងញៀន ។

II. ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវ

១. ការសម្រេចចិត្តធ្វើអ្វីមួយឱ្យបានត្រឹមត្រូវទាក់ទងនឹង

☐ ក. ឪពុកម្ដាយ

☐ ខ.ជីវភាពគ្រួសារ

☐ គ. ព័ត៌មានពាក់ពន្ធ័នឹងផែនការរបស់ខ្លួន

☐ ឃ. ចំណង់ចំណូលចិត្តរបស់ខ្លួន ។

២. មិត្តភក្តិល្អត្រូវ

☐ ក. ជួយលំអាល់កំហុសឆ្គង

☐ ខ. ជួយផ្តល់ថវិកា

☐ គ. ជួយផ្ទែកសំភារៈនិងស្មារតី

☐ ឃ. ជួយពេលប្រលង

៣. អំពើហិង្សាក្នុងគ្រួសារកើតមានចំពោះ

☐ ក. អ្នកមានប្រាក់ចំណូលខ្ពស់

☐ ខ. ជនក្រីក្រ

☐ គ. រស់នៅជនបទ

☐ ឃ. គ្រប់ស្រទាប់វណ្ណៈ

៤. យុវជនមានសុជីវធម៌ល្អ សំដៅយកយុវជនដែល

☐ ក. ចេះគោរពឪពុកម្តាយ

☐ ខ. មិនបង្កអសន្តិសុខសង្គម

☐ គ. មានយោបល់អធ្យាស្រ័យគ្នា

☐ ឃ. ក + ខ និង គ ។

III. ចូរផ្គូរផ្គងពាក្យក្នុងប្រអប់ *ក* ទៅអត្ថន័យប្រអប់ *ខ* ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១. សីលធម៌<br>២. ភាតរភាព<br>៣. ការសម្រេចចិត្ត<br>៤.ទេពកោសល្យ<br>។ | ក. រស់នៅដោយគ្មានការវាយដំឈ្លោះទាស់ទែងគ្នា ។<br>ខ. រស់នៅជាមួយគ្នាដោយឱ្យតម្លៃគ្នាទៅវិញទៅមក គោរពសិទ្ធគ្នា និងរួមរស់ដោយសន្តិភាព ។<br>គ.ជ្រើសរើសគោលដៅរបស់ខ្លួនសម្រាប់អនាគត ។<br>ឃ. មានសមត្ថភាពធ្វើអ្វីមួយយ៉ាងស្ទាត់ជំនាញ។ | ១.<br>២.<br>៣.<br>៤. |

IV. ចូរបំពេញល្បះចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ....................គំនិតផ្តួចផ្តើមធ្វើអ្វីមួយលេចចេញជារូបរាង ។

២.ការសម្រេចចិត្តត្រូវការមាន .........................គ្រប់គ្រាន់ ។

៣.................សំដៅយកជម្លោះរវាងប្ដីប្រពន្ធនិងមនុស្សរស់នៅក្រោមដំបូលផ្ទះតែមួយ។ការចេះអត់ឱននិងជួយគេលំអគ្នាដោយ

ស្មោះត្រង់អាចរស់ជាមួយគ្នាដោយក្ដីស្ងប់ទាំងផ្លូវ.......ទាំង.....
........... មិនចង់ឱ្យឃ្លាតគ្នា ។

V. ចូរឆ្លើយនឹងសំណួរខាងក្រោមនេះ

១. តើរបស់អ្វីខ្លះដែលបានច្នៃប្រឌិតក្នុងភូមិរបស់អ្នក ?

២.តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យការច្នៃប្រឌិតទទួលបានជោគជ័យ ?

៣. តើមិត្តភក្តិល្អ ត្រូវមានអាកប្បកិរិយាដូចម្ដេច ?

៤. ហេតុអ្វីបានជាចាំបាច់ទទួលខុសត្រូវចំពោះការងារ ?

៥. តើប្អូនៗត្រូវមានសីលធម៌អ្វីខ្លះ ចំពោះគ្រួសារ និងសហគមន៍ ?

# ចម្លើយ

I. គូសសញ្ញា ✓ ឬ ✗ ខាងមុខឈ្មោះខាងក្រោម

១. ✓

២. ✗

៣. ✗

៤. ✗

៥. ✗

៦. ✗

II. គូសសញ្ញា ✓ នៅក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវ

១. ការសម្រេចចិត្តធ្វើអ្វីមួយឱ្យបានត្រឹមត្រូវទាក់ទងនឹង

☑ គ. ព័ត៌មានពាក់ពន្ធ័នឹងផែនការរបស់ខ្លួន

២. មិត្តភក្តិល្អត្រូវ

☑ ក. ជួយលំអពល់កំហុសឆ្គង

៣. អំពើហិង្សាក្នុងគ្រួសារកើតមានចំពោះ

☑ ឃ. គ្រប់ស្រទាប់វណ្ណៈ

៤. យុវជនមានសុជីវធម៌ល្អ សំដៅយកយុវជនដែល

☑ ឃ. ក + ខ និង គ ។

III. ផ្គូរផ្គងពាក្យក្នុងប្រអប់ *ក* ទៅអត្ថន័យប្រអប់ *ខ* ឱ្យបានត្រឹមត្រូវ

១. → ខ, ២. → ក, ៣. → គ,

៤. → ឃ ។

IV. បំពេញល្បះចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. *គំនិតច្នៃប្រឌិត* ។

២. *គម្រោងផែនការ និងកំណត់គោលបំណង* ។

៣. *អំពើហិង្សា, កាយ, ផ្លូវចិត្ត* ។

V. ឆ្លើយនឹងសំណួរ

១. របស់ដែលបានច្នៃប្រឌិតក្នុងភូមិរបស់ខ្ញុំមានដូចជា តុ ទូ កៅអី គ្រែ វត្ថុអនុស្សាវរីយ៍ និងវត្ថុប្រើប្រាស់ផ្សេងៗ ។

២. កត្តា ដែលធ្វើឱ្យការច្នៃប្រឌិតទទួលបានជោគជ័យ គឺ ៖

- លើកទឹកចិត្តឱ្យមានការបង្កើតស្នាដៃក្នុងការឃោសនា ។ ប្រសិនបើអ្នកអាចសម្តែងអារម្មណ៍និងស្នាដៃច្នៃប្រឌិតរបស់អ្នកតាមរយៈការគូររូប កែច្នៃផលិតផលផ្សេងៗ ការតែងកំណាព្យ ចម្រៀង...អ្នកពុំគួររារែកទេ ។

- ចូរឱ្យតម្លៃលើកទឹកចិត្តដល់អ្នកខិតខំប្រឹងប្រែងបង្កើត ស្នាដៃ និងច្នៃប្រឌិត ។ អាចអាចចុះផ្សាយអត្ថបទរបស់ អ្នកក្នុងទំព័រកាសែត ឬធ្វើអត្ថបទទាំងនោះ ឱ្យគេបោះ ពុម្ព ។
- ចូរជម្រុញខ្លួនឯងឱ្យមានការច្នៃប្រឌិតខ្ពស់ ។
- អនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឱ្យបានត្រឹមត្រូវ ។

៣. មិត្តភក្តិល្អ ត្រូវមានអាកប្បកិរិយាដូចជា ៖

- ចេះជួយយកអាសារគ្នាក្នុងគ្រាក្រ និងជួយគ្នាពេលមាន អាសន្ន ជួយផ្នែកសម្ភារៈនិងកម្លាំងកាយ កម្លាំងចិត្ត តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន ។ មិត្តល្អត្រូវ ជួយកែប្រែរាល់ទង្វើប្រាកចាកច្បាប់និងខុសគន្លង ប្រពៃណី ។
- ត្រូវណែនាំមិត្តខ្លួន ពេលឃើញដើរផ្លូវខុសឬសេពគប់ មិត្តអាក្រក់ដូចជាប្រើគ្រឿងញៀន ផឹកស្រា ជក់បារី គេចសាលា ចូលហ្គេម (game) បង្កភាពអសកម្ម ដល់សាលារៀននិងសង្គម ។ មិត្តល្អមិនត្រូវតិះដៀល បៀតបៀន រំខានមិត្តភក្តិនៅក្នុងថ្នាក់រៀនទេ ។

៤. បានជាចាំបាច់ទទួលខុសត្រូវចំពោះការងារ ព្រោះការទទួលខុសត្រូវជាក្រមសីលធម៌មួយរបស់មនុស្សក្នុងការសម្រេចចិត្តធ្វើអ្វីមួយ ។ម្យ៉ាងទៀតធ្វើឱ្យអ្នកដែលនៅជុំវិញគោរពស្រឡាញ់យើង ព្រមទាំងមានទំនាក់ទំនងល្អទៀតផង វាធ្វើឱ្យការងាររបស់យើងមានប្រសិទ្ធិភាព និងមានដំណើរការល្អ ហើយទទួលបានជោគជ័យ ។

៥. ចំពោះគ្រួសារ និងសហគមន៍ ត្រូវមានសីលធម៌៖

❖ *គ្រួសារ*

- ត្រូវស្រឡាញ់ និងស្តាប់ដំបូន្មានឪពុកម្តាយ
- ផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគដល់លោកទាំងពីរ និងថែរក្សាសុខភាពលោកទាំងពីរ
- ជួយធ្វើការងារបងប្អូន និងឪពុកម្តាយ
- គោរពមនុស្សទាំងអស់នៅក្នុងគ្រួសារ
- ខិតខំសិក្សារៀនសូត្រមិនឱ្យឪពុកម្តាយអស់សង្ឃឹម

❖ *សង្គម*

▪ចូលរួមក្នុងសកម្មភាពសង្គម (ការប្រយុទ្ធប្រឆាំងអំពើហិង្សា គ្រឿងញៀន ការរំលោភបំពាន ប្រឆាំងជម្ងឺអេដស៍)

▪គោរពនិងឱ្យតម្លៃលើអ្នកដទៃ

▪ជួយសម្រាលទុក្ខដល់មិត្តភក្តិ ឬអ្នកដែលក្រលំបាក

▪ទទួលស្គាល់ទុក្ខលំបាករបស់អ្នកដទៃ

▪មិនឈ្លានពានអ្នកដទៃ

▪មិនមានការរើសអើងវណ្ណៈ និងមិនប្រកាន់ពូជសាសន៍។

ជំពូកទី ២ **វប្បធម៌សន្តិភាព**

មេរៀនទី១ **អរិយធម៌**

<u>សំណួរចម្លើយ</u>

1. តើអរិយធម៌ជាអ្វី ?

<u>ចម្លើយ</u> *អរិយធម៌* ជា ការសំគាល់ការរស់នៅ ការរៀបចំជីវភាពសង្គមមនុស្សឱ្យបានប្រកបដោយសេចក្តីសុខ រីកចម្រើនល្អលាស់ មានរបៀបរៀបរយល្អ មានគ្រឿងប្រដាប់ប្រើប្រាស់ជំនឿ ចំណេះដឹង ទៅតាមចំណង់ចំណូលចិត្ត ។

2. តើអរិយធម៌មានធាតុសំខាន់ៗ អ្វីខ្លះ ?

<u>ចម្លើយ</u> អរិយធម៌មានធាតុសំខាន់ៗ គឺវប្បធម៌ និងសង្គមធម៌ ។

3. តើវប្បធម៌និងសង្គមធម៌ មានទំនាក់ទំនងគ្នាដូចម្តេច ?

<u>ចម្លើយ</u> វប្បធម៌និងសង្គមធម៌ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធមានឥទ្ធិពលលើគ្នាទៅវិញទៅមក បំពេញឱ្យគ្នាទៅវិញទៅមកដូចកាយ និងចិត្តដែរ ។ សង្គមធម៌ល្អលាស់រីកចម្រើនបានអាស្រ័យនឹងវប្បធម៌សង្គម ដូចជាគ្រឿងប្រដាប់ប្រើប្រាស់អាចផលិតបានដោយសារមនុស្សមានចំណេះដឹង បំណិន និង

កម្រិតជំនាញច្បាស់លាស់ ។ ឯវប្បធម៌វិញក៏ពឹងពាក់លើសង្គមធម៌ សិល្បៈ អក្សរសិល្ប៍ ជំនឿសាសនា រីកចម្រើនល្អគលាស់អភិវឌ្ឍន៍អាស្រ័យនឹងរបបសង្គមគាំទ្រ ផ្តល់ឱកាសឱ្យសង្គមមានដំណើរការល្អ ។ វប្បធម៌ស្វែងរកសុខៈឱ្យមនុស្សតាមផ្លូវចិត្ត ឯសង្គមធម៌ស្វែងរកសុខៈមនុស្សតាមផ្លូវកាយ និងសម្ភារៈ ។

4. តើអរិយធម៌មានទំនាក់ទំនងជាមួយអរិយធម៌បរទេសដូចម្តេចខ្លះ

<u>ចម្លើយ</u> អរិយធម៌ខ្មែរមានទំនាក់ទំនងជាមួយអរិយធម៌បរទេសដោយ ទទួលឥទ្ធិពលពីគ្នាទៅវិញទៅមក ។ គឺខ្មែរបានសំយោគអរិយធម៌បរទេសមកកែច្នៃធ្វើជារបស់ខ្លួនដោយពុំបានចម្លងទាំងស្រុងនោះទេ ការធ្វើរបៀបនេះ គឺដើម្បីឱ្យអរិយធម៌ខ្មែរកាន់តែរីកដុះដាលកើនឡើង និងធ្វើមានការអភិវឌ្ឍ ។

5. ចូរបង្ហាញឱ្យឃើញឥទ្ធិពលខ្លះថា អរិយធម៌បរទេសមកលើអរិយធម៌ខ្មែរ។

ចម្លើយ អរិយធម៌បរទេសមកលើអរិយធម៌ខ្មែរ មានដូចជា ក្នុងពិធីអាពាហ៍ពិពាហ៍ គេឃើញមានពិធីសែនព្រេនតាមបែប ព្រហ្មសាសនា ពាក្យពេជចន៍មួយចំនួនមកពីភាសាបាលីសំស្ក្រឹត ការលក់ដូរ ការប្រើប្រាស់គ្រឿងអេឡិចត្រូនិច ...។

6. តើជនជាតិខ្មែរមានអរិយធម៌របស់ខ្លួនដែរឬទេ ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

ចម្លើយ ជនជាតិខ្មែរមានអរិយធម៌របស់ខ្លួន ។ ឧទាហរណ៍ ៖

- ស្ថាបត្យកម្ម (សំណង់ប្រាង្គប្រាសាទផ្សេងៗ... )
- ភាសាខ្មែរ
- ទំនៀមទម្លាប់ (ការអានសំពះ ការស្លៀកពាក់ ពិធីបុណ្យ ...)
- ជំនឿសាសនា (ព្រះពុទ្ធ) ...។

7. ចូររៀបរាប់តម្លៃអរិយធម៌ខ្មែរ ។

ចម្លើយ រៀបរាប់តម្លៃអរិយធម៌ខ្មែរ៖

ខ្មែរមានអរិយធម៌ពិតប្រាកដរបស់ខ្លួន ដែលមានចំណាស់ចាស់ជាងគេនៅលើពិភពលោកចាប់តាំងពីខ្មែរមានទំនាក់ទំនងជាមួយជាតិសាសន៍ដទៃមកម្ល៉េះ ។អរិយធម៌រីកចម្រើន

ល្អតលាស់ជាលំដាប់តាមរយៈការកែច្នៃវប្បធម៌បរទេសផ្សំនឹងវប្បធម៌របស់ខ្លួន ។ អរិយធម៌ខ្មែរក៏បានផ្សព្វផ្សាយដល់ប្រទេសជិតខាង ពិភពលោកផងដោយមានអ្នកស្រាវជ្រាវបរទេសជាច្រើនបានចំណាយពេលវេលា និងថវិកាយ៉ាងច្រើនធ្វើការស្រាវជ្រាវតាំងពីសតវត្សទី ១៩។ ដោយសារតែតម្លៃពិសេសនៃអរិយធម៌របស់ខ្លួន ទើបធ្វើឱ្យខ្មែរចេះកែច្នៃ ខំពង្រីកការពារព្រលឹងជាតិយើង ។

8. ហេតុអ្វីបានខ្មែរ ត្រូវស្គាល់អរិយធម៌ខ្មែរ ? តើការស្គាល់អរិយធម៌ខ្មែរគ្រប់គ្រាន់ហើយឬនៅ ? ព្រោះអ្វី ?

ចម្លើយ បានជាខ្មែរ ត្រូវស្គាល់អរិយធម៌ខ្មែរ វាជាសម្បត្តិនៃជាតិយើង។ ការស្គាល់អរិយធម៌ខ្មែរនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះគ្រាន់តែជាការស្គាល់ពីវប្បធម៌របស់ខ្លួនឯងមិនទាន់អាចធ្វើឱ្យអរិយធម៌ និងប្រទេសជាតិយើងរីកចម្រើននោះទេ គឺត្រូវស្គាល់ពីអរិយធម៌បរទេសផងដែរ ដើម្បីធ្វើសំយោគតែវប្បធម៌ណាដែលល្អ និងយកកែច្នៃធ្វើឱ្យអរិយធម៌ខ្មែររីកចម្រើន ។

9. តើសង្គមធម៌ និងវប្បធម៌មានទំនាក់ទំនងដូចម្តេច ? ពីព្រោះអ្វី ? ចូរលើកឧទាហរណ៍ក្នុងប្រវត្តិសាស្ត្របញ្ជាក់ ។

<u>ចម្លើយ</u> សង្គមធម៌ និងវប្បធម៌ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ។ ព្រោះវាមានឥទ្ធិពលទៅវិញទៅមកមិនអាចខ្វះមួយណាបានឡើយ។

ឧទាហរណ៍៖ក្នុងសម័យបុព្វកាលមនុស្សជួបបញ្ហាលំបាកតោកយ៉ាកមានជម្ងឺប្រចាំកាយដោះស្រាយបញ្ហាមិនរួចធ្វើឱ្យមនុស្សមានជំនឿ ដូចជាការបន់ស្រន់ ខ្មោច អារក្ស អ្នកតា អាទិទេពដែលជាជំនឿគ្មានហេតុផល ។ តែដោយសារវិទ្យាសាស្ត្រជឿនលឿន មនុស្សមានមធ្យោបាយគ្រប់គ្រាន់អាចពន្យល់អាថ៌កំបាំងក្នុងធម្មជាតិនោះជំនឿគ្មានហេតុផលក៏ថយចុះ។

មេរៀនទី២ **ស្ថាបត្យកម្មប្រាសាទបុរាណខ្មែរ**

<u>សំណួរចម្លើយ</u>

1. តើស្ថាបត្យកម្មខ្មែរយើងចែកជាប៉ុន្មានសម័យកាល ? មានសម័យកាលណាខ្លះ ?

<u>ចម្លើយ</u> ស្ថាបត្យកម្មខ្មែរយើងចែកជា២សម័យកាល គឺ ៖

- ស្ថាបត្យកម្មមុនសម័យអង្គរ (ស.វ ១ ដល់ ស.វ ៨)
- ស្ថាបត្យកម្មសម័យអង្គរ (ស.វ ៩ ដល់ ស.វ ១៣) ។

2. តើរចនាសម្ពន្ធ័ប្រាសាទមានអ្វីខ្លះ ?

<u>ចម្លើយ</u> រចនាសម្ពន្ធ័ប្រាសាទមាន ជញ្ជាំង រូត ទ្វារ បង្អួច ផ្តែរ ហោជាងដែលប្រកបដោយក្បាច់រចនាទាំងអស់ ។

3. តើសំណង់ប្រាសាទបែបព្រះពុទ្ធសាសនា និងបែបព្រាហ្មណ៍និយមខុសគ្នាដូចម្តេច ?

<u>ចម្លើយ</u> សំណង់ប្រាសាទបែបព្រះពុទ្ធសាសនា និងបែបព្រាហ្មណ៍និយមខុសគ្នាត្រង់ ៖

❖ សំណង់ប្រាសាទបែបព្រះពុទ្ធសាសនាៈ គេច្រើននៅលើដីរាបស្មើ បែបវត្តអារាមពុំមានជាន់ថ្នាក់ខ្ពស់ៗ ។

❖ សំណង់បែបព្រាហ្មណ៍សាសនា៖ គេសង់ប្រាសាទនៅលើកំពូលភ្នំ ដើម្បីគោរពភ្នំព្រះសុមេរុដែលជាទីឋាននៃព្រះអាទិទេព ។ ការសង់ប្រាសាទមានជាជាន់ៗថ្នាក់និងមានខឿនច្រើនជាន់និងខ្ពស់ ។

4. តើចម្លាក់របស់ខ្មែរចែកចេញជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

<u>ចម្លើយ</u> ចម្លាក់របស់ខ្មែរចែកចេញជា ៣ ប្រភេទ ចម្លាក់លិប លៀន លោត ។

5. តើចម្លាក់ខ្មែរមានមុខងារប៉ុន្មានយ៉ាង ?

<u>ចម្លើយ</u> ចម្លាក់ខ្មែរមានមុខងារ ពីរយ៉ាង គឺ សម្រាប់ធ្វើសក្ការបូជា និង សម្រាប់លំអ ។

6. តើប្រាសាទមានមុខងារអ្វីខ្លះ ?

<u>ចម្លើយ</u> ប្រាសាទមានមុខងារ សម្រាប់ឧទ្ទិសថ្វាយ៖

- ព្រះអាទិទេពឬទេវៈផ្សេងៗក្នុងសាសនាព្រាហ្មណ៍ ដូចជាព្រះវិស្ណុ (ព្រះនរាយណ៍) ព្រះសិវៈ(ព្រះឥសូរ) ព្រះព្រហ្មជាដើម ។
- ព្រះពោធិសត្វក្នុងពុទ្ធសាសនាមហាយានដូចជាលោកេស្វរៈ

- ទេវរាជ (គេដាក់តម្កល់លិង្គព្រះឥសូរក្នុងប្រាសាទជាតំណាងព្រះរាជា)
- បុព្វបុរសព្រះរាជាដូចជា ព្រះមាតា បិតានិងវរជនស្នេហាជាតិ ។

7. តើប្រាសាទខ្មែរយើង បានប្រាប់អត្ថន័យអ្វីខ្លះដល់មនុស្សជំនាន់ក្រោយ ?

<u>ចម្លើយ</u> ប្រាសាទខ្មែរយើងបានប្រាប់អត្ថន័យ ដល់មនុស្សជំនាន់ក្រោយ ដូចជា៖

- ➢ ស្នាដៃស្ថាបត្យកម្មដ៏ប៉ិនប្រសព្វ និងភាពរុងរឿងនៃសម័យកាលនីមួយៗ
- ➢ ការខិតខំប្រឹងប្រែង ភាពសាមគ្គីគ្នានៃបុព្វបុរសខ្មែរ
- ➢ ភាពច្នៃប្រឌិតប្រកបដោយសមត្ថភាព និងបច្ចេកទេសក្នុងការកសាងប្រាសាទ
- ➢ ភាពល្បាញល្បីនៃស្ថាបត្យកម្ម...។

8. តើប្រាសាទបុរាណខ្មែរយើងផ្តល់អ្វីខ្លះដល់សេដ្ឋកិច្ចជាតិ ?

<u>ចម្លើយ</u> ប្រាសាទបុរាណខ្មែរយើងផ្តល់ប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ដូចជា៖

- ទាក់ទាញភ្ញៀវទេសចរក្នុងនិងក្រៅប្រទេសចូលមកទស្សនា ជាហេតុធ្វើឱ្យប្រជាជន ព្រមទាំងប្រទេសទាំងមូលទទួលបានប្រាក់ចំណូល ។

9. តើក្បាច់ផ្សេងៗមានប្រយោជន៍អ្វីខ្លះដល់សង្គមខ្មែរ ?

<u>ចម្លើយ</u> ក្បាច់ផ្សេងៗមានប្រយោជន៍ដល់សង្គមខ្មែរ ដូចជាបង្ហាញនូវរូបរាងនិងលក្ខណៈខ្មែរនិងទេពកោសល្យបង្កើតថ្មី ។ មិនត្រឹមតែប៉ុណ្ណោះក្បាច់ទាំងនោះធ្វើឱ្យសង្គមទាំងមូលមានសោភ័ណភាពគួរឱ្យកោតសរសើរ ។

10. ដើម្បីថែរក្សា ប្រាសាទបុរាណ និងវត្ថុបុរាណឱ្យបានគង់វង្សអ្នកត្រូវធ្វើអ្វីខ្លះ ?

<u>ចម្លើយ</u> ដើម្បីថែរក្សា ប្រាសាទបុរាណ និងវត្ថុបុរាណឱ្យបានគង់វង្សយើងចូលរួមការពារ ដោយផ្សព្វផ្សាយ កេរដំណែលដូនតាយើងឱ្យពិភពលោកបានស្គាល់ ។ ត្រូវខិតខំសិក្សារៀនសូត្រពីប្រវត្តិនៃប្រាសាទ និងវត្ថុបុរាណឱ្យបានដឹង ។ បង្កើតច្បាប់ការពារ និងដាក់ទោសទៅលើជនណាដែលមានគំនិតបំផ្លាញ និងលួចលក់... ។

11.មូលហេតុអ្វីបានជាបុព្វបុរសខ្មែរយើងកសាងប្រាសាទច្រើនម្ល៉េះ ?

__ចម្លើយ__ បានជាបុព្វបុរសខ្មែរយើងកសាងប្រាសាទច្រើនម្ល៉េះ ដោយសារៈ

៙ ***សាសនា៖*** ការប្រកាន់ជំនឿសាសនាខុសគ្នា បានធ្វើឱ្យព្រះរាជាខ្មែរព្រមគោរពបូជាប្រាសាទដដែល ហើយក៏បានចាត់ចែងឱ្យគេសាងសង់ប្រាសាទដទៃទៀត តម្រូវតាមបំណងនិងជំនឿរបស់ព្រះអង្គ ។

៙ ***កិត្តិយស៖*** ការស្ថាបនាប្រាសាទ ជាសក្ខីភាពបញ្ជាក់នូវកិត្តិយសរបស់ព្រះរាជាក្នុងការបង្ហាញនូវស្នាព្រះហស្ថ ការប៉ិនប្រសព្វ និងប្រាជ្ញាដ៏វាងវៃរបស់ព្រះអង្គ ។ បណ្ដាក្បូរក្បាច់រចនា ភាពខ្ពង់ខ្ពស់ត្រដឹមត្រដែតលើនភាល័យ ជាងប្រាសាទដទៃជាការបញ្ជាក់នូវកិត្តិយសរបស់ព្រះរាជាអ្នកស្ថាបនាព្រមទាំងផ្សាយ ...ារមីរបស់ព្រះអង្គ ដល់ប្រជារាស្ត្រ ។

➢ *ប្រវត្តិសាស្ត្រ៖* ការស្ថាបនាប្រាសាទប្លែកៗគ្នាជាគោលបំណងមួយទៀតរបស់ព្រះរាជាខ្មែរគឺដើម្បីឱ្យកិត្តិនាមរបស់ព្រះល្បីល្បាញល្បីក្នុងប្រវត្តិសាស្ត្រ ។

➢ *ទម្លាប់៖* នៅពេលឡើងសោយរាជ្យម្តងៗ ស្តេចខ្មែរទម្លាប់ឱ្យស្ថាបត្យករជំនាញសង់ប្រាសាទទុកធ្វើជាកេរដំណែលសម្រាប់រជ្ជកាលរបស់ព្រះអង្គ ។

➢ *បម្លាស់ប្តូរទីក្រុង៖* ការផ្លាស់ប្តូរទីក្រុងតម្រូវឱ្យព្រះមហាក្សត្របញ្ជាឱ្យសង់ប្រាសាទ ។ ដូចជា ភ្នំគូលែននៅសៀមរាម នៅលង្វែក និងនៅឧត្តុង្គជាដើម ។

➢ *សង្គ្រាម៖* ការកសាងប្រាសាទធំទូលាយ រឹងមាំមានច្រកចេញចូលខ្ទាត់ខ្ទែងជាមធ្យោបាយដ៏ល្អមួយសម្រាប់ទប់ទល់នឹងសត្រូវ ។

12.តើការសិក្សាពីស្ថាបត្យកម្មប្រាសាទបុរាណ ផ្តល់សារៈសំខាន់យ៉ាងណាខ្លះសម្រាប់អ្នក ?

<u>ចម្លើយ</u> ការសិក្សាពីស្ថាបត្យកម្មប្រាសាទបុរាណ ផ្តល់សារៈសំខាន់ដល់ខ្ញុំដូចជា៖

➢ បានស្គាល់ពីស្នាដៃ និងតម្លៃនៃវប្បធម៌បុព្វបុរសខ្មែរ

- ដឹងថាខ្មែរធ្លាប់មានអរិយធម៌រុងរឿង តាមរយៈប្រវត្តិសាស្ត្រ
- មានគំនិតចង់ថែរក្សា និងគំនិតច្នៃប្រឌិត
- មានមោទនភាពចំពោះស្ថាបត្យដ៏អស្ចារ្យរបស់ខ្មែរ
- មានសមត្ថភាពអាចផ្សព្វផ្សាយពីស្ថាបត្យកម្មដល់មនុស្សជំនាន់ក្រោយនិងជនបរទេស...។

13. ប្រសិនបើប្រាសាទបុរាណត្រូវបាត់បង់ដោយសារគេដណ្តើមយក តើអ្នកមានអារម្មណ៍ដូចម្តេចដែរ ?

<u>ចម្លើយ</u> ប្រសិនបើប្រាសាទបុរាណត្រូវបាត់បង់ដោយសារគេដណ្តើមយក ខ្ញុំមានអារម្មណ៍សោកស្តាយ និងភ័យព្រួយយ៉ាងខ្លាំង.... ។

មេរៀនទី៣ **របបមាតាធិបតេយ្យ**

## <u>សំណួរចម្លើយ</u>

1. តើរបបមាតាធិបតេយ្យជាអ្វី ?

<u>ចម្លើយ</u> របបមាតាធិបតេយ្យ ជារបបមួយដែលដែលឱ្យតម្លៃទៅលើម្តាយក្នុងការដឹកនាំគ្រួសារ និងសង្គមទាំងមូល ។

2. តើមានរឿងព្រេងអ្វីខ្លះដែលឱ្យតម្លៃទៅលើស្ត្រី ?

<u>ចម្លើយ</u> រឿងព្រេង ដែលឱ្យតម្លៃទៅលើស្ត្រី គឺ ឪពុកក្មេករើសកូនប្រសា រឿងភ្នំប្រុសភ្នំស្រី ...។

3. តើក្នុងរបបមាតាធិបតេយ្យបានជះឥទ្ធិពលដូចម្តេចខ្លះដល់វិស័យផ្សេងៗនៅក្នុងសង្គមខ្មែរចាប់តាំងពី អតីតកាលរហូតដល់បច្ចុប្បន្ន ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

<u>ចម្លើយ</u> ក្នុងរបបមាតាធិបតេយ្យបានជះឥទ្ធិពល ដល់វិស័យផ្សេងៗនៅក្នុងសង្គមខ្មែរចាប់តាំងពី អតីតកាលរហូតដល់បច្ចុប្បន្ន គឺ៖

◆ *គ្រួសារ*

▪ បុរសត្រូវចូលស្តីដណ្តឹងនារី

ឧទាហរណ៍: រៀបការនៅផ្ទះខាងស្រីហើយនៅបម្រើ

ខាងស្រី ។

◆ *សង្គម*

▪ រាប់ខ្សែស្រឡាយខាងម្ដាយ

ច្រើនដាក់ឈ្មោះស្ត្រីមុនបុរស ។

ឧទាហរណ៍ៈ មេបា ម្ដាយឪពុក មាតាបិតា មីងមា ...។

▪ ភូមិកំណើតប្រទេសជាតិសុទ្ធតែរបស់ស្ត្រី

◆ *វិស័យរដ្ឋបាល*

▪ មេស្រុក មេឃុំ មេទ័ព

▪ មេចោរ មេក្រុម មេបញ្ជាការ ។ល។

4. តើក្នុងពិធីឡើងផ្ទះ ចំណុចណាដែលបញ្ជាក់ថា ស្ត្រីជាធំ ?

ចម្លើយ ក្នុងពិធីឡើងផ្ទះ ចំណុច ដែលបញ្ជាក់ថា ស្ត្រីជាធំ គឺ ស្ត្រីត្រូវគិតអំពីការចាត់ចែង ទិញសម្ភារៈ សំណង់ រៀបចំចំអិនម្ហូបអាហារ ហើយក្នុងពេលបញ្ចប់ពិធីឡើងផ្ទះ ដើម្បីសេរីសួស្តី គេអញ្ជើញស្ត្រីចូលផ្ទះមុនគេ ។

5. ក្នុងពិធីស្ដីដណ្ដឹង ចំណុចត្រង់ណាដែលបុព្វបុរសយើងឱ្យតម្លៃសាច់ញាតិខាងស្រី ?

ចម្លើយ ក្នុងពិធីស្ដីដណ្ដឹង ចំណុច ដែលបុព្វបុរសយើងឱ្យតម្លៃសាច់ញាតិខាងស្រី គឺ បុរសត្រូវចូលស្ដីដណ្ដឹងស្ត្រី ដោយទទួលគោរពតាមលក្ខខណ្ឌផ្សេងៗតាមការកំណត់របស់មេបា និងតាមទំនៀមទម្លាប់ ។

6. ចូរសរសេរពាក្យផ្ដើមដោយ " មេ " ឱ្យបាន ១០ពាក្យ

ចម្លើយ សរសេរពាក្យផ្ដើមដោយ " មេ " ឱ្យបាន ១០ពាក្យ គឺ

- មេបា
- មេចោរ
- មេក្រុម
- មេទ័ព
- មេភូមិ
- មេឃុំ
- មេបន
- មេក្លោង
- មេស្រុក
- មេបញ្ជាការ ...។

7. តើបច្ចុប្បន្នស្ត្រីត្រូវបានគេយកចិត្តទុកដាក់ដូចម្តេចខ្លះ ? ចូរអត្ថាធិប្បាយ ។

<u>ចម្លើយ</u> បច្ចុប្បន្នស្ត្រីត្រូវបានគេយកចិត្តទុកដាក់ និងត្រូវបានលើកតម្កើងក្នុងសង្គម មានសេរីភាពសមត្ថភាពចូលរួមអភិវឌ្ឍប្រទេសជាតិដូចបុរសដែរ ។ស្ត្រីអាចកាន់តំណែងខ្ពស់ចូលរួមក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ប្រទេសជាតិរបស់ខ្លួនក្នុងលក្ខណៈស្មើភាព និង សមស្របពាក្យស្លោកពិភពលោកកំណត់ថា *ស្ត្រីជាមាតានៃពិភពលោក* ។

8. ចូរអ្នកស្រាវជ្រាវពិធីចូលម្លប់តាមប្រពៃណីខ្មែរយើង ។

<u>ចម្លើយ</u> ស្រាវជ្រាវពិធីចូលម្លប់តាមប្រពៃណីខ្មែរយើង ៖

ពិធីចូលម្លប់ជាប្រពៃណីខ្មែរមួយដែលធ្វើឡើងសម្រាប់ស្ត្រីក្រមុំព្រហ្មចារីឈានចូលវ័យក្រមុំ (ឃើញរដូវលើកដំបូង) ហើយជាកូនស្រីច្បងក្នុងគ្រួសារ ។ គ្រួសារមានជីវភាពបង្គួរអាចទប់ទល់នឹងភាពលំបាកខ្វះខាត និងជាគ្រួសារដែលមានកម្លាំងពលកម្មគ្រប់គ្រាន់ ។ ឯគោលបំណងនៃពិធីចូលម្លប់នេះ គឺ ៖

- ចង់ប្រកាសពីភាពក្រមុំរបស់កូន ដែលអាចឱ្យមាតាបិតា ដែលមានកូនប្រុស ចូលស្ដីដណ្ដឹង យកធ្វើជាគូស្រករបាន ។
- ទាក់ទាញអារម្មណ៍ញាតិមិត្ត តាមលក្ខណៈរូបសម្បត្តិ និងចរិយាសម្បត្តិពេលចូលម្លប់ចាស់បុរាណតម្រូវឱ្យកូនស្រីបំពេញភារកិច្ចសំខាន់ដូចខាងក្រោម ។
- សិក្សាក្បួនច្បាប់ទូន្មានល្អៗ ជាពិសេសច្បាប់ទូន្មានសម្រាប់ស្ត្រី ដើម្បីឱ្យកូនស្រីស្គាល់ច្បាស់ពីតួនាទីរបស់ស្ត្រីក្នុងការរស់នៅ ។
- សិក្សាពីធម៌វិន័យ ធម៌អាថ៌កំបាំងរបស់ព្រះពុទ្ធ ដើម្បីអប់រំចិត្តស្ត្រីឱ្យកាន់តែអំណត់ខន្តីដូចដូនជីដែលកាន់សីលដប់ ។
- សិក្សាពីវិជ្ជាមេផ្ទះ ធ្វើម្ហូប តម្បាញ ការរៀបចំផ្ទះសម្បែង ការអប់រំកូនចៅ ដើម្បីឱ្យក្លាយជាភរិយា និងម្ដាយដ៏ប្រសើរ ។
- ថែទាំសាច់ឱ្យស្អាត ស្រស់ថ្លា ដោយលាបរមៀតស្ងួតពេញខ្លួនដៃជើង ឱ្យមានសម្បុរលឿងល្អផូរផង់ ។

មេរៀនទី៨ **សុខមង្គល គ្រួសារ**

## សំណួរចម្លើយ

1. ចូរឱ្យនិយមន័យគ្រួសារ ?

<u>ចម្លើយ</u> និយមន័យគ្រួសារ ៖

គ្រួសារជាក្រុមមួយដែលមានសមាជិក ប្តីប្រពន្ធ កូនស្ថិតនៅក្រោមដំបូលផ្ទះតែមួយ គ្រួសារជាកោសិកាសង្គម ។

2. តើអាពាហ៍ពិពាហ៍មានលក្ខខណ្ឌអ្វីខ្លះ ? ចូររៀបរាប់ ។

<u>ចម្លើយ</u> អាពាហ៍ពិពាហ៍មានលក្ខខណ្ឌ ៤ គឺ៖

*ក. លក្ខខណ្ឌសម្ភារៈ*

កូនប្រុសស្រីត្រូវមានសុខភាពល្អ មានសមត្ថភាពអាចចិញ្ចឹមខ្លួនឯងបាន ទើបអាចរៀបអាពាហ៍ពិពាហ៍បាន ។ កូនប្រុសស្រីត្រូវមានមុខរបរ អាជីពឬជំនាញអ្វីមួយដែលអាចរកថវិកាផ្គត់ផ្គង់ជីវភាព ដោយមិនចាំបាច់ពឹងផ្អែកលើអ្នកដទៃ ។ សព្វថ្ងៃកូនប្រុស កូនស្រីត្រូវពិនិត្យឈាមរកមេរោគអេដស៍សិនទើបសម្រេចចិត្តឱ្យរៀបការ ។

*ខ. លក្ខខណ្ឌវេទនា*

កូនប្រុសកូនស្រីត្រូវប្រាកដថា មានចិត្តប្រតិព័ទ្ធរវាងគ្នា និងគ្នា ទើបឪពុកម្ដាយសងខាងផ្សំផ្គុំឱ្យរៀបការ ។ ឪពុកម្ដាយមិនត្រូវបង្ខំពួកគេ ប្រសិនបើពួកគេមិនស្រឡាញ់គ្នា ។

*គ. លក្ខខណ្ឌសង្គម*

ការស្រឡាញ់គ្នាទៅវិញទៅមកពុំទាន់គ្រប់គ្រាន់នៅឡើយទេ គឺប្ដីប្រពន្ធត្រូវចុះកិច្ចសន្យាលើបញ្ជីអត្រានុកូលដ្ឋាន ដើម្បីបញ្ជាក់ជាផ្លូវការនៅមុខអជ្ញាធរមូលដ្ឋាន (សាលាឃុំ) ជាគូស្វាមីភរិយាស្របច្បាប់ ។ ក្រៅពីនេះ ពួកគេត្រូវគោរពតាមប្រពៃណី និងសាសនាផងដែរ ។

*ឃ. លក្ខខណ្ឌខាងផ្លូវសីលវិជ្ជា*

ជាគុណធម៌ ចរិយាធម៌ដែលដែលជាកត្តាទ្រទ្រង់ការរស់នៅ និងសណ្ដាប់ធ្នាប់របស់គ្រួសារ ។ ដូចនេះប្ដីប្រពន្ធត្រូវមានភាពស្មោះត្រង់ចំពោះគ្នា និងចេះជួយរំលែកកិច្ចការគ្នាក្នុងគ្រួសារ រែកពន់ទាំងគ្នា នូវភ័ព្វសំណាងល្អ ឬអាក្រក់និងខិតខំកសាងជីវភាពដើម្បីទ្រទ្រង់ជីវិតគ្រួសារ ។

3. តើអ្នកគិតថា លក្ខខណ្ឌអាពាហ៍ពិពាហ៍ណាមួយសំខាន់ជាងគេ?ព្រោះអ្វី ?

ចម្លើយ ខ្ញុំគិតថា លក្ខខណ្ឌអាពាហ៍ពិពាហ៍ដែលសំខាន់ជាងគេ គឺលក្ខខណ្ឌវេទនា ព្រោះថា ក្នុងលក្ខខណ្ឌនេះ គឺតម្រូវកូនប្រុស កូនស្រី មានចិត្តស្រឡាញ់អាណិតគ្នាដោយស្មោះអស់ពីចិត្ត ទើបឪពុកម្តាយសម្រេចចិត្តឱ្យកូនរៀបការនឹងគ្នា។ ឪពុកម្តាយមិនត្រូវបង្ខិតបង្ខំពួកគេឡើយ ព្រោះអាចបណ្តាលឱ្យមានទំនាស់ ខ្វែងគំនិតគ្នា ឬអាចលែងលះគ្នាទៅថ្ងៃក្រោយ ធ្វើឱ្យគ្រួសារទាំងមូលគ្មានសុភមង្គល ។

4. ប្រសិនបើឪពុកម្តាយអ្នកបង្ខំឱ្យរៀបការជាមួយនារីម្នាក់ ឬបុរសដែលអ្នកមិនពេញចិត្ត តើអ្នកត្រូវពន្យល់លោកទាំងពីដូចម្តេចដើម្បីបញ្ឈប់ការរៀបការ ? ចូរលើកអំនះអំណាងឱ្យបានបី ។

ចម្លើយ ប្រសិនបើឪពុកម្តាយ បង្ខំឱ្យរៀបការជាមួយនារីម្នាក់ ឬបុរសដែលអ្នកមិនពេញចិត្ត ខ្ញុំត្រូវពន្យល់លោកទាំងពីថា៖

- ខ្ញុំបានជាប់ចិត្តលើអ្នកផ្សេងរួចហើយ (ស្រលាញ់) ។ យើងបានសន្យាថា នឹងរៀបការនឹងគ្នា ។

- នេះជាសិទ្ធិក្នុងការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ឪពុកម្តាយមិនត្រូវបង្ខំកូនឡើយ ។
- បើសិនជាលោកទាំងពីរបង្ខំខ្ញុំ នៅពេលអនាគតមានបញ្ហាអ្វីកើតឡើងអ្នកទាំងពីរជាអ្នកទទួលខុសត្រូវមិនខានពេលនោះកូននឹងត្រូវបន្ទោសអ្នកទាំងពីរថារំលោភសិទ្ធិក្នុងការសម្រេចចិត្ត និងលោកទាំងពីរជាអ្នកធ្វើបាបកូន ។

5. ចូររៀបរាប់ពីទំនាក់ទំនងកូន និងឪពុកម្តាយ ។

<u>ចម្លើយ</u> ទំនាក់ទំនងកូន និងឪពុកម្តាយ ៖

កូននឹងឪពុកម្តាយមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ។ ឪពុកម្តាយជាអ្នកបង្កើតកូន បីបាច់ថែរក្សាកូន បំពេញតម្រូវការឱ្យកូនគ្រប់បែបយ៉ាង តាមដែលកូនត្រូវការ ។ ពួកគាត់ជាអ្នកដែលមានទំនួលខុសត្រូវនៅក្នុងគ្រួសារ មានក្តីស្រឡាញ់អាណិតកូន ។ កូនជាចំណងមួយដែលធ្វើឱ្យឪពុកម្តាយ មានភក្តីភាពចំពោះគ្នាទៅវិញទៅមកដែរ ។ពេលកូនធំឡើង ក៏មិនខុសអ្វីពីឪពុកម្តាយដែរ គឺត្រូវរៀបការ មានគូស្រករ និងបង្កើតកូនចៅដែរ ។ ដូច្នេះកូនក៏មានតួនាទីក្នុងការគោរពលោកទាំង

ពីរ ជួយធ្វើការងារ ស្តាប់ដំបូន្មាន និងសងគុណលោកទាំងពីរ តាមដែលអាចធ្វើទៅបាន ។

6. តើគ្រួសារមានតួនាទីដូចម្តេចក្នុងការអប់រំកូន ?

ចម្លើយ គ្រួសារមានតួនាទីយ៉ាងសំខាន់ខាងផ្លូវសង្គមក្នុងការអប់រំកូន ។

7. ចូររៀបរាប់ពីសុភមង្គលក្នុងគ្រួសារណាមួយដែលប្អូនបានជួបប្រទះ ។

ចម្លើយ សុភមង្គលក្នុងគ្រួសារដែលខ្ញុំ បានជួបប្រទះ គឺ ៖ មានគ្រួសារមួយដែលខ្ញុំបានជួបពួកគេជាគ្រួសារដែលចេះយោគយល់ អធ្យាស្រ័យគ្នាទៅវិញទៅមក រវាងកូនៗ និងឪពុកម្តាយ ។ ពួកគេមិនដែលឈ្លោះប្រកែកគ្នាទេ ។ ពេលមានបញ្ហាអ្វីនៅក្នុងគ្រួសារ ពួកគេចេះ ពិភាក្សាគ្នារកដំណោះស្រាយ និង មានភាពសាមគ្គីគ្នាបានល្អទៀតផង ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេមានទំនាក់ទំនងល្អជាមួយអ្នកជិតខាង និងអ្នកនៅក្នុងគ្រួសារ ។

8. តើធ្វើដូចម្តេចខ្លះ ដើម្បីថែរក្សាឱ្យមានសុភមង្គលក្នុងគ្រួសារ ?

ចម្លើយ ដើម្បីថែរក្សាឱ្យមានសុភមង្គលក្នុងគ្រួសារ យើងត្រូវគោរពតាមដំបូន្មានល្អៗរបស់ឪពុកម្តាយ មិនបង្ករការលំបាកដល់លោកទាំងពីរ ធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីជាប្រយោជន៍ដល់គ្រួសារ ជួយធ្វើកិច្ចការផ្ទះដោយពុំខ្លាចនឿយហត់ ស្រឡាញ់អាណិតសមាជិកនៅក្នុងគ្រួសារ និងញាតិមិត្តជិតខាង ព្រមទាំងជួយថែរក្សាទ្រព្យសម្បត្តិដែលម្តាយឪពុករកបាន ។

មេរៀនទី៩ **សុខភាពផ្លូវចិត្ត**

## សំណួរចម្លើយ

1. ដូចម្តេចដែលហៅថា សុខភាពផ្លូវចិត្ត ?

ចម្លើយ ដែលហៅថា *សុខភាពផ្លូវចិត្ត* គឺជាបំណងប្រាថ្នារបស់មនុស្សគ្រប់រូប ។ វាគឺជាសភាពមានសុខុមាលភាពពេញលេញផ្នែកកាយសម្បទា ផ្លូវចិត្ត និងសង្គម មិនមែនគ្រាន់តែជាភាពគ្មានជម្ងឺ ឬពិការទ្បើយ ។

2. តើភាពតានតឹងផ្លូវចិត្តបណ្តាលមកពីអ្វី ?

ចម្លើយ ភាពតានតឹងផ្លូវចិត្តបណ្តាលមកពី៖

- ទំនាស់នៅក្នុងគ្រួសារ
- ជីវភាពក្រលំបាក
- បន្ទុកក្នុងគ្រួសារច្រើនហួសពេក
- ការមិនយល់ចិត្តគ្នា
- ការមិនចុះសម្រុងក្នុងការងារ
- ការបំពេញការងារមិនបានជោគជ័យ
- ការគិតព្រួយចំពោះហេតុការណ៍ក្នុងអនាគត និងជម្ងឺរ៉ាំរ៉ៃប្រចាំកាយ
- ការបែកបាក់គ្រួសារ ។ល។

3. នៅពេលអ្នកមានបញ្ហាផ្លូវចិត្តតើអ្នកដោះស្រាយដូចម្តេច ?

__ចម្លើយ__ នៅពេល មានបញ្ហាផ្លូវចិត្តយើងត្រូវដោះស្រាយ៖

- រកវិធីដោះស្រាយល្អៗ បណ្តុះគំនិតសុទិដ្ឋិនិយមសម្រាកឱ្យគ្រប់គ្រាន់ និងធ្វើការងារកំសាន្ត ផ្សេងៗដែលយើងចូលចិត្តដូចជា ការថែសួន ថែច្បារចំណាំ ថែសត្វចិញ្ចឹមឬធ្វើកិច្ចការផ្ទះផ្សេងៗ ។

- ជួបសំណេះសំណាលជាមួយមិត្តភក្តិ ឬអ្នកជិតស្និទ្ធបំផុតដើម្បីនិយាយពីអារម្មណ៍មួហ្មងទាំងអស់ប្រាប់គ្នាទៅវិញទៅមក
- ពិគ្រោះបញ្ហាជាមួយអ្នកដែលយើងទុកចិត្ត និងរាប់បំផុតដើម្បីឱ្យគេជួយផ្តល់កម្លាំងចិត្តក្នុងការដោះស្រាយបញ្ហាដែលយើងជួបប្រទះ ។
- ស្តាប់ឱវាទចាស់ព្រឹទ្ធាចារ្យ ឬព្រះសង្ឃ ។
- លេងកីឡា ស្តាប់ភ្លេង ទស្សនាភាពយន្ត រឿងកំប្លែង ការប្រគំតន្ត្រី ដើរកំសាន្ត លំហែកាយ ឬចូលរួមសកម្មភាពសង្គមផ្សេងៗ...។

4. តើការសេពគ្រឿងញៀនអាចដោះស្រាយបញ្ហាផ្លូវចិត្តបានឬទេ ?

<u>ចម្លើយ</u> ការសេពគ្រឿងញៀនមិនអាចដោះស្រាយបញ្ហាផ្លូវបានទេ ។

5. ប្រសិនបើអ្នកមានបងប្អូនមានបញ្ហាផ្លូវចិត្ត និងសេពគ្រឿងញៀន តើអ្នកជួយដោយវិធីណាខ្លះ ?

ចម្លើយ ប្រសិនបើខ្ញុំមានបងប្អូនមានបញ្ហាផ្លូវចិត្ត និងសេព គ្រឿងញៀន ខ្ញុំត្រូវជួយគេដោយ គាំទ្រផ្នែកផ្លូវចិត្ត និងការលើកទឹកចិត្ត ឬកម្លាំងចិត្តអំពីគ្រួសារ និងមិត្តភក្តិនៅជុំវិញខ្លួនគេ ។

## សំណួរបញ្ចប់ជំពូក ២

I. ចូរគូសសញ្ញា ✓ នៅមុខល្បះដែលត្រឹមត្រូវ ឬ ✗ ខាងមុខល្បះដែលមិនត្រឹមត្រូវ

១. —— គ្រប់ជាតិសាសន៍ទាំងអស់មានរបៀបរស់នៅ ប្រពៃណី ជំនឿសាសនាផ្សេងៗ គ្នា ។

២. —— ខ្មែរទទួលយកអរិយធម៌បរទេសទាំងស្រុងយកធ្វើជារបស់ខ្លួន ។

៣. —— ប្រភេទចម្លាក់ខ្មែរមានបីប្រភេទ ចម្លាក់មុនសម័យអង្គរ ក្រោយសម័យអង្គរ និងសម័យអង្គរ ។

៤. —— ប្រទេសកម្ពុជាមានការដឹកនាំតាមរបបមាតាធិបតេយ្យតាំងពីសតវត្សទី ១ មកម្ល៉េះ ។

៥. —— ការផឹកស្រា ជក់បារី សេពគ្រឿងញៀន ជាវិធីព្យាបាលមួយងាយស្រួលជាងគេបំផុត ។

II. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. របបមាតាធិបតេយ្យសំដៅយក

☐ ក. ស្ត្រីមានសិទ្ធិច្រើនជាងបុរស

☐ ខ. ស្ត្រីជាមាតានៃពិភពលោក

☐ គ. ស្ត្រីមានសិទ្ធិដឹកនាំប្រទេសដូចបុរសដែរ

☐ ឃ. ស្ត្រីជាមនុស្សពូកែជាងបុរស

២. គ្រួសារមានសុភមង្គលដោយសារ

☐ ក. មានប្រាក់ចំណូលច្រើន

☐ ខ. គ្រួសារមានសមាជិកច្រើន

☐ គ. មានសំភារៈទំនើបៗ

☐ឃ.ស្រុះស្រួលគ្នានិងមានចំណូលអាចទ្រទ្រង់ជីវភាពបាន

៣. មនុស្សបាត់បង់សុខភាពផ្លូវចិត្តត្រូវការៈ

☐ ក. ទៅឱ្យពេទ្យព្យាបាល

☐ ខ. គ្រួសារមានសមាជិកច្រើន

☐ គ. ក និង ខ

☐ ឃ. ដើរលេងកំសាន្តមាត់សមុទ្រ

III. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

១.ដើមកំណើតអរិយធម៌ខ្មែរចាប់កំណើតពីជនជាតិ .............. តាំងពីរាប់ពាន់ឆ្នាំមកហើយ ។

២.នៅសម័យអង្គរខ្មែរកាន់សាសនា ................ បែប ........។

៣.ប្រភេទចម្លាក់ខ្មែរមាន......គឺ...................................។

៤.......... ការផ្សំផ្គុំយ៉ាងឧឡារិកជាផ្លូវការតាមទំនៀមទម្លាប់ប្រពៃណីរវាងបុរស និងស្ត្រី ។ ប្រាសាទបុរាណអាចទាក់ទង .......... និង.....ចូលមកទស្សនានិង ................របស់ជាតិ ។

IV. ចូរឆ្លើយនឹងសំណួរខាងក្រោមនេះ

១. តើមនុស្សមានបញ្ហាផ្លូវចិត្ត ប៉ះពាល់ដល់ការអភិវឌ្ឍធនធានមនុស្សដែរឬទេ ? ព្រោះអ្វី ?

២. តើប្រាសាទនីមួយៗ បានឆ្លុះបញ្ចាំងពីរបៀបដឹកនាំសម័យមុនដូចម្តេចខ្លះ ?

៣. ពេលអ្នកមានអារម្មណ៍តានតឹង តើអ្នកធ្វើអ្វីខ្លះ ដើម្បីបំបាត់ភាពតានតឹងទាំងនោះ ?

៤. តើប្រពៃណី និងជំនឿអកុសលខុសប្លែកគ្នាដូចម្តេច ?

# ចម្លើយ

I. គូសសញ្ញា ✓ ឬ × ខាង...ល្បះខាងក្រោម

១. ✓

២. ×

៣. ×

៤. ✓

៥. ×

II. គូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូ...

១. របបមាតាធិបតេយ្យសំដៅយក

☑ ខ. ស្ត្រីជាមាតានៃពិភពលោក

២. គ្រួសារមានសុភមង្គលដោយសារ

☑ឃ.ស្រុះស្រួលគ្នានិងមានចំណូលអាចទ្រទ្រង់ជីវភាពបាន

៣. មនុស្សបាត់បង់សុខភាពផ្លូវចិត្តត្រូវការៈ

☑ គ. ក និង ខ

III. បំពេញល្បះខាងក្រោម

១. *មន-ខ្មែរ*

២. *ព្រះពុទ្ធ* បែប *ហិនយាន*

៣. *៣ ប្រភេទ* គឺ *ចម្លាក់លិប ល្បៀន លោត*

៤. អាពាហ៍ពិពាហ៍គឺជា ។ *ទេសចរក្នុង* និង *ក្រៅប្រទេស* ចូលមកទស្សនា និង *ទទួលបានប្រាក់ចំណូល* ។

IV. ឆ្លើយនឹងសំណួរ

១. មនុស្សមានបញ្ហាផ្លូវចិត្ត ប៉ះពាល់ដល់ការអភិវឌ្ឍធនធានមនុស្ស ព្រោះអ្វី បញ្ហាផ្លូវចិត្តធ្វើឱ្យមនុស្សទទួលនូវការបាត់បង់សតិបញ្ញា អារម្មណ៍មិនល្អ ការចងចាំមិនល្អ ជួនកាលធ្វើឱ្យគេមិនអាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនឯងបាន និងគ្មានក្តីសង្ឃឹមក្នុងឆាកជីវិត ។ កាលណាគេក្លាយជាមនុស្សបែបនេះ ធ្វើឱ្យគេមិនអាចសិក្សារៀនសូត្រ ធ្វើកិច្ចការងារផ្សេងៗទៀតបាន ។

២. ប្រាសាទនីមួយៗ បានឆ្លុះបញ្ចាំងពីរបៀបដឹកនាំសម័យមុនដូចជា ៖

- មានភាពអង់អាចក្លាហាន និងសាមគ្គីភាព
- អ្នកដឹកនាំមានសមត្ថភាព
  និងមានទេពកោសល្យគំនិតច្នៃប្រឌិត
- មានឆន្ទៈក្នុងការដឹកនាំ និងមានទំនួលខុសត្រូវ
- មានការបែងចែកតួនាទីគ្នាក្នុងការដឹកនាំ

▪ការដឹកនាំប្រកបដោយគតិបណ្ឌិត....។

៣. ពេលខ្ញុំមានអារម្មណ៍តានតឹង ដើម្បីបំបាត់ភាពតានតឹងទាំងនោះខ្ញុំបានទៅដដែកជាមួយមិត្តភក្តិ ស្តាប់ចម្រៀង វិទ្យុ មើលភាពយន្ត ហាត់ប្រាណ និងដើរលំហែរកំសាន្ត ។

៤. ប្រពៃណី និងជំនឿអកុសលខុសប្លែកគ្នាត្រង់ថា ប្រពៃណីជាអ្វីដែលធ្វើតៗគ្នាតាំងពីមុនមក ឬចាត់ទុកជាអត្តសញ្ញាណវប្បធម៌របស់ជាតិមួយពិតប្រាកដ ហើយមានប្រយោជន៍។ ចំណែកឯ ជំនឿអកុសលជាជំនឿដែលមិនសមហេតុផល មិនល្អ ធ្វើឱ្យមនុស្សខ្ជូចខាតបង់ និងគ្មានភាពជាក់លាក់ ។

ជំពូកទី ៣ **ការចូលរួមអភិវឌ្ឍសហគមន៍**

មេរៀនទី១ **នីតិរដ្ឋ**

## <u>សំណួរចម្លើយ</u>

1. ចូរឱ្យនិយមន័យនីតិរដ្ឋ ។

<u>ចម្លើយ</u> និយមន័យ៖

***នីតិរដ្ឋ*** គឺសំដៅយករដ្ឋប្រកាន់ការអនុវត្តច្បាប់ជាតិ ។ រដ្ឋប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ពោលគឺរាល់ការសម្រេចចិត្តធ្វើសកម្មភាព របស់រដ្ឋាភិបាលត្រូវពឹងផ្អែកលើច្បាប់ជាមូលដ្ឋាន ។

2. តើប្រទេសនីតិរដ្ឋមានគោលការណ៍អ្វីខ្លះ ?

<u>ចម្លើយ</u> ប្រទេសនីតិរដ្ឋមានគោលការណ៍ដូចជា ៖

- ប្រកាន់យកលទ្ធិប្រជាធិបតេយ្យ
- ផ្អែកលើច្បាប់ជាគោលឬ មូលដ្ឋាន
- ដោះស្រាយទំនាស់ដោយសន្តិវិធីឬតាមប្រព័ន្ធតុលាការ
- ផ្ដល់សិទ្ធិឱ្យប្រជាជនជ្រើសរើសអ្នកតំណាងរបស់ខ្លួនដោយផ្ទាល់

▪ប្រជាជនជាអ្នកកំណត់វាសនារបស់ប្រទេសជាតិខ្លួន។

3. តើការផ្សព្វផ្សាយច្បាប់សិទ្ធិដល់ប្រជាពលរដ្ឋមានសារៈសំខាន់ឬទេ ? ព្រោះអ្វី ?

<u>ចម្លើយ</u> ការផ្សព្វផ្សាយច្បាប់សិទ្ធិដល់ប្រជាពលរដ្ឋមានសារៈ ព្រោះប្រជាជនគ្រប់រូបបានយល់ដឹងពីសិទ្ធិសេរីភាពរបស់ខ្លួនក្នុងការប្រើប្រាស់សបច្បាប់ ។

4. បើប្រទេសជាតិមួយដែលមានអំពើហិង្សា តើវានឹងមានផលអាក្រក់អ្វីខ្លះចំ ពោះជាតិ ?

<u>ចម្លើយ</u> បើប្រទេសជាតិមួយដែលមានអំពើហិង្សា វានឹងមានផលអាក្រក់ចំ ពោះជាតិ ដូចជា ៖

▪សេដ្ឋកិច្ចសង្គមធ្លាក់ចុះ (ការព្យាបាល របួសស្នាម)

▪សង្គមមានការអភិវឌ្ឍយឺតយ៉ាវ

▪សម្បូរដោយមនុស្សឯកោ បាត់បង់ទំនុកចិត្ត ភាពកក់ក្ដៅ និងជួបតែភាពព្រាត់ប្រាសពីក្រុមគ្រួសារ

▪មានជម្ងឺផ្លូវចិត្តសង្គម

▪បាត់បង់ធនធានមនុស្ស...។

5. ហេតុអ្វីបានជាកងកម្លាំងប្រដាប់អាវុធត្រូវប្រកាន់យកអព្យាក្រឹតភាព ?

<u>ចម្លើយ</u> បានជាកងកម្លាំងប្រដាប់អាវុធត្រូវប្រកាន់យកអព្យាក្រឹតភាព ព្រោះកងកម្លាំងប្រដាប់អាវុធជាស្នូលប្រទេសជាតិ ជាអ្នករក្សាការពារបូរណភាពដែនដី សន្តិសុខសណ្តាប់ធ្នាប់សង្គម និងជាអ្នកការពារផលប្រយោជន៍រួមរបស់សង្គមផងដែរ ។

6. ហេតុអ្វីបានជាមន្ត្រីរាជការត្រូវប្រកាន់តួនាទីអព្យាក្រឹត ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

<u>ចម្លើយ</u> បានជាមន្ត្រីរាជការត្រូវប្រកាន់តួនាទីអព្យាក្រឹតព្រោះមន្ត្រីរាជការជាអ្នកបម្រើការងារឱ្យរដ្ឋឬផ្តល់សេវាកម្មសាធារណៈដល់ប្រជាជន មិនប្រកាន់វណ្ណៈឬពណ៌សម្បុរឡើយ ។ ឧទាហរណ៍: គ្រូពេទ្យ មានតួនាទីព្យាបាលអ្នកជម្ងឺគ្រប់ប្រភេទដោយមិនប្រកាន់ វណ្ណៈ ពណ៌សម្បុរឡើយ គឺធ្វើយ៉ាងណាឱ្យអ្នកជម្ងឺបានជាសះស្បើយ ។

7. ដើម្បីមានយុត្តិធម៌ក្នុងសង្គម ចៅក្រមត្រូវប្រកាន់ឥរិយាបថ ឬតួនាទីដូចម្តេចខ្លះ ?

__ចម្លើយ__ ដើម្បីមានយុត្តិធម៌ក្នុងសង្គម ចៅក្រមត្រូវប្រកាន់ឥរិយាបថ ឬតួនាទីដូចជា ៖

- ត្រូវសម្រេចចិត្តធ្វើឡើងដោយគ្មានការភិតភ័យ ឬធ្វើទុក្ខបុកម្នេញសម្ពាធពីខាងក្រៅ
- ឯករាជ្យភាពមិនលំអៀង
- មិនត្រូវកាត់ក្តីតាមការគាបសង្កត់ពីអ្នកមានអំណាច
- មិនត្រូវអគតិដោយសារលោភសក្ការៈផលប្រយោជន៍ផ្ទាល់ខ្លួន
- ត្រូវមានហេតុផលគ្រប់គ្រាន់ក្នុងការសម្រេចក្តី
- ផ្តល់យុត្តិធម៌ចំពោះជនរងគ្រោះ និងជនដែលល់តាមច្បាប់ដែលបានចែង.... ។

## មេរៀនទី២ **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

<u>សំណួរចម្លើយ</u>

1. តើរដ្ឋធម្មនុញ្ញជាច្បាប់អ្វី ?

<u>ចម្លើយ</u> រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេសជាតិ ឬជាគោលសាធារណៈកំពូលនៅក្នុងប្រទេសដែលមនុស្សគ្រប់ត្រូវតែគោរពតាម ។

2. ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញប៉ុន្មាន តាំងពី ១៩៤៧រហូតដល់បច្ចុប្បន្ន ។

<u>ចម្លើយ</u> ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញ ប្រាំ តាំងពី ១៩៤៧រហូតដល់បច្ចុប្បន្ន ។

3. តើរដ្ឋធម្មនុញ្ញជំនាន់ណាពុំមានភាពច្បាស់លាស់ ?

<u>ចម្លើយ</u> រដ្ឋធម្មនុញ្ញ ពុំមានភាពច្បាស់លាស់ គឺ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៧៥ ។

4. តើរដ្ឋសភាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យតំណាងឱ្យវណ្ណៈអ្វីខ្លះ ?

<u>ចម្លើយ</u>រដ្ឋសភាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យតំណាងឱ្យវណ្ណៈ កសិករ ពលករ និង កងទ័ពបដិវត្តន៍ ។

5. តើរដ្ឋធម្មនុញ្ញមានផលប្រយោជន៍អ្វីខ្លះ ?

<u>ចម្លើយ</u> រដ្ឋធម្មនុញ្ញមានផលប្រយោជន៍ដូចជា៖

- ធានាឱ្យមានស្ថេរភាពសង្គមនិងមានតុល្យភាពរវាងអំណាចទាំងបី នីតិប្បញ្ញត្តិ ប្រតិបត្តិ និងតុលាការ
- ធានាព្រះរាជាណាចក្រកម្ពុជារដ្ឋមិនអាចបំបែកបាន
- ធានាឱ្យប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់
- ធានាសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់គ្មានការរំលោភបំពានពីអ្នកដទៃឡើយ
- ធានាប្រជាពលរដ្ឋមានសិទ្ធិពេញលេញខាងជំនឿសាសនា និងអាចចូលរួមធ្វើនយោបាយ និងបង្កើតសហគមន៍
- ធានាឱ្យមានសិទ្ធិកាន់កាប់កម្មសិទ្ធិឯកជន
- ផ្ដល់សិទ្ធិឱ្យពលរដ្ឋអភិវឌ្ឍសហគមន៍និងប្រទេសជាតិខ្លួន
- ធានាអាយុជីវិតពលរដ្ឋប្រកបដោយពុំមានការកាត់ទោសប្រហារជីវិតឡើយ

៦. ផ្ដល់សិទ្ធិជ្រើសរើសតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតជាសកល

៦. ជាគោលនយោបាយធំបំផុតសម្រាប់ជាប្រទីបដឹកនាំប្រទេសជាតិឱ្យមានការអភិវឌ្ឍជឿនលឿន ។

6. តើគណបក្សបីដែលបានបង្កើតក្នុងឆ្នាំ ១៩៤៩-១៩៥៣ មានឈ្មោះអ្វីខ្លះ?

<u>ចម្លើយ</u> គណបក្សបីដែលបានបង្កើតក្នុងឆ្នាំ ១៩៤៩-១៩៥៣ មានឈ្មោះ៖

- គណបក្សប្រជាធិបតេយ្យដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ
- គណបក្សសេរីភាព ដឹកនាំដោយនរោត្តម នរិន្ទដេត
- គណបក្សជឿនលឿនដឹកនាំដោយនរោត្តម ម៉ុងតាណា

7. តើបារាំងប្រគល់អំណាចឱ្យខ្មែរពេញលេញនៅឆ្នាំណា ?

<u>ចម្លើយ</u> បារាំងប្រគល់អំណាចឱ្យខ្មែរពេញលេញនៅ ១៩៥៣ ។

8. តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពួកគេបែងចែកប្រជាជនជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

ចម្លើយ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពួកគេបែងចែកប្រជាជនជាបីប្រភេទគឺៈ

- កសិករ
- ពលករ
- កងទ័ពបដិវត្តន៍...។

9. តើមានហេតុការណ៍អ្វីកើតឡើងខ្លះក្នុងឆ្នាំ ១៩៩៣ ?

ចម្លើយ ក្នុងឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាប្រើសិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដែលមានការគាំទ្រពីអង្គការសហប្រជាជាតិ (UNTA C) ។ សភាបានសម្រេចយករបប "រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ " ដោយថ្វាយអតីតព្រះមហាក្សត្រឱ្យព្រះអង្គជានិមិត្តរូបនៃឯករាជ្យជាតិ និងនិរន្តរភាពជាតិ តែព្រះអង្គមិនកាន់អំណាចឡើយ ។

## មេរៀនទី៣ **ស្ថាប័នកំពូលនៃព្រះរាជាណាចក្រកម្ពុជា**

<u>សំណួរចម្លើយ</u>

1. តើដូចម្តេចហៅថា ស្ថាប័ន ?

<u>ចម្លើយ</u> ដែលហៅថា *ស្ថាប័ន* សំដៅយកអ្វីទាំងឡាយដែលមនុស្សបង្កើតឡើង ដើម្បីសម្របសម្រួលរៀបចំសង្គមឱ្យមានសណ្តាប់ធ្នាប់ល្អប្រសើរ និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការដឹកនាំ និងគ្រប់គ្រងជាតិរបស់ខ្លួន ។

2. ចូរអ្នករៀបរាប់ពីការជ្រើសតាំងរដ្ឋសភាជាតិ ។

<u>ចម្លើយ</u> ការជ្រើសតាំងរដ្ឋសភាជាតិ ៖

រដ្ឋសភាជាតិកើតឡើងពីការបោះឆ្នោតជ្រើសតាំងជាសកល ។ បន្ទាប់មកតំណាងរាស្ត្រទាំងអស់ដែលជាប់ឆ្នោតត្រូវកោះប្រជុំជាលើកដំបូងរបស់ព្រះមហាក្សត្រមិនឱ្យលើសពី៦០ថ្ងៃបន្ទាប់ពីការបោះឆ្នោត ។ក្នុងកំឡុង ៦០ថ្ងៃ ក្រោយពីការបោះឆ្នោតសមាជិករដ្ឋសភាថ្មីត្រូវចូលកាន់តំណែងរបស់ខ្លួនក្រោមអធិបតីភាពនៃព្រះមហាក្សត្រ ។

សមាជិកសភា មានយ៉ាងតិច ១២០រូប និងអាចប្រែប្រួលបាន តាមចំនួនប្រជាជនកើតឡើង តែពុំអាចថយចុះក្រោមពី ១២០ រូបឡើយ ។

3. តើការបោះឆ្នោតរដ្ឋសភាជាតិ និងព្រឹទ្ធសភាខុសគ្នាដូចម្តេច ?

<u>ចម្លើយ</u> ការបោះឆ្នោតរដ្ឋសភាជាតិ និងព្រឹទ្ធសភាខុសគ្នាដោយៈ

- ការបោះឆ្នោតរដ្ឋសភាជាតិ គឺកើតឡើងដោយការជ្រើសតាំងជាសកល
- ការបោះឆ្នោតព្រឹទ្ធសភាគឺកើតឡើងដោយការជ្រើសតាំងជាអសកល។

4. ចូរប្រាប់ពីរបៀបបង្កើតរាជរដ្ឋាភិបាល ។

<u>ចម្លើយ</u> របៀបបង្កើតរាជរដ្ឋាភិបាល ៖

ក្រោយពីការបោះឆ្នោតជាសកលសភាជាតិបានដំណើរ គណបក្សឈ្នះឆ្នោតរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនបញ្ជីឈ្មោះសមាជិករដ្ឋាភិបាលដែលទទួលបន្ទុកស្ថាប័ន ឬ ក្រសួងរួចទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ បន្ទាប់ពីសភាបានផ្តល់សេចក្តីទុកចិត្តរួចហើយ ទើបព្រះមហាក្សត្រចេញព្រះរាជក្រឹតតែងតាំង

គណៈរដ្ឋមន្ត្រីទាំងមូលដោយអនុលោមតាមមាត្រា ១១៩នៃរដ្ឋធម្មនុញ្ញ ។

5. តើស្ថាប័នសភាមានតួនាទីអ្វីខ្លះ ?

<u>ចម្លើយ</u> ស្ថាប័នរដ្ឋសភាមានតួនាទី៖

- ត្រួតពិនិត្យមើលការចំណាយផ្សេងៗរបស់រាជរដ្ឋាភិបាលដោយអនុម័តលើថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការ ឱ្យរដ្ឋឱ្យប្រាក់គេខ្ចី លុបចោលពន្ធដារ និងឱ្យសេចក្តីយល់ព្រមលើគណនីរដ្ឋបាល ។
- រដ្ឋសភាជាអង្គការតែមួយគត់ដែលអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលពីតំណែងតាមរយៈការអនុម័តញ្ញត្តិបន្ទោស ។
- មានអំណាចកោះហៅ សមាជិករដ្ឋាភិបាលមកសួរបំភ្លឺ និងអាចដកហូតសមាជិករដ្ឋាភិបាលបាន ។
- អនុម័តច្បាប់ផ្សេងៗ និងធ្វើវិសោធនកម្មច្បាប់ ។

ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត

៥០ ជិករដ្ឋសភាទាំងមូលតាមរយៈការបោះឆ្នោត ។

6. តើតួនាទីរដ្ឋសភា និងព្រឹទ្ធសភាខុសគ្នាដូចម្តេចខ្លះ ?

<u>ចម្លើយ</u> តួនាទីរដ្ឋសភា និងព្រឹទ្ធសភាខុសគ្នា ត្រង់ ៖

❖ *រដ្ឋសភា*

- ត្រួតពិនិត្យមើលការចំណាយផ្សេងៗរបស់រាជរដ្ឋាភិបាល ដោយអនុម័តលើថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការ ឱ្យរដ្ឋឱ្យប្រាក់គេខ្ចី លុបចោលពន្ធដារ និងឱ្យសេចក្តីយល់ព្រមលើគណនីរដ្ឋបាល ។
- រដ្ឋសភាជាអង្គការតែមួយគត់ដែលអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលពីតំណែងតាមរយៈការអនុម័តញ្ញត្តិបន្ទោស ។
- មានអំណាចកោះហៅ សមាជិករដ្ឋាភិបាលមកសួរបំភ្លឺ និងអាចដកហូតសមាជិករដ្ឋាភិបាលបាន ។
- អនុម័តច្បាប់ផ្សេងៗ និងធ្វើវិសោធនកម្មច្បាប់ ។
- អនុម័តប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត ៥០+១ នៃសមាជិករដ្ឋសភាទាំងមូលតាមរយៈការបោះឆ្នោត ។

❖ *ព្រឹទ្ធសភា*

- ផ្តល់យោបល់ឬធ្វើអនុសាសន៍ចំពោះច្បាប់ដែលខ្លួនបានពិនិត្យ
- មានអំណាចផ្តួចផ្តើមធ្វើច្បាប់
- ជួយរកដំណោះស្រាយនយោបាយពេលប្រទេសជាតិជួបវិបត្តិនយោបាយ
- ធ្វើអន្តរាគមន៍គ្រប់ពេលវេលាពេលមានវិបត្តិនយោបាយ រវាងរដ្ឋសភា និងរដ្ឋាភិបាលតាមមធ្យោបាយផ្សេងៗ ។

7. តើអំណាចតុលាការមានសារៈសំខាន់ដូចម្តេចខ្លះ ចំពោះជីវភាពប្រជាជន ?

<u>ចម្លើយ</u> អំណាចតុលាការមានសារៈសំខាន់ណាស់ ចំពោះជីវភាពប្រជាជន គឺតុលាការជា អ្នកធានារក្សាអនាគតនិងការពារសេរីភាពរបស់ប្រជាពលរដ្ឋ ហើយក៏ជាអ្នកផ្តល់នូវភាពយុត្តិធម៌ជូនប្រជារាស្ត្រខ្មែរគ្រប់រូបតាមរយៈការជម្រះក្តី ឱ្យសមស្របតាមច្បាប់ ។

8. ហេតុអ្វីបានជាប្រទេសនីមួយៗចាំបាច់មានរដ្ឋសភា ?

ចម្លើយ បានជាប្រទេសនីមួយៗចាំបាច់មានរដ្ឋសភា ព្រោះរដ្ឋសភាជាអង្គការឯករាជ្យហើយចំបាច់បំផុតក្នុងការធ្វើឱ្យប្រទេសជាតិមួយមានស្ថេរភាពនយោបាយ មានសន្តិសុខ មានសណ្តាប់ធ្នាប់និងមានការដឹកនាំត្រឹមត្រូវ ។ បើគ្មានរដ្ឋសភាទេ ប្រទេសនោះនឹងក្លាយទៅជាអនាធិបតេយ្យជាមិនខានឡើយ

9. តើប្រទេសកម្ពុជាយើងប្រកាន់យករបបដឹកនាំអ្វី ?

ចម្លើយ ប្រទេសកម្ពុជាយើងប្រកាន់យករបបដឹកនាំលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

10.តើអ្នកណាជាអ្នកដឹកនាំប្រទេសជាតិ ? ចូររៀបរាប់ ។

ចម្លើយ អ្នកដែលជាអ្នកដឹកនាំប្រទេសជាតិគឺអ្នកដែលស្ថិតក្នុងអំណាចទាំងបី មានដូចជា៖

- នាយករដ្ឋមន្ត្រី
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា...។

# មេរៀនទី៤ **សិទ្ធិ និងករណីយកិច្ច**

<u>សំណួរចម្លើយ</u>

1. ដូចម្តេចដែលហៅថា សិទ្ធិមនុស្ស ? តើសិទ្ធិមនុស្សជាមូលដ្ឋានមានអ្វីខ្លះ?

<u>ចម្លើយ</u> ដែលហៅថា *សិទ្ធិមនុស្ស* គឺជាអ្វីៗទាំងអស់ដែលមនុស្សត្រូវការជាចាំបាច់សម្រាប់ឱ្យមនុស្សរស់នៅបានក្នុងសេចក្តីថ្លៃថ្នូរជាមនុស្ស ។ សិទ្ធិមនុស្សជាមូលដ្ឋានមានសិទ្ធនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិវប្បធម៌ ។

2. ដូចម្តេចដែលហៅថា ករណីយកិច្ច ?

<u>ចម្លើយ</u> ដែលហៅថា ***ករណីយកិច្ច*** ជាកិច្ចដែលប្រជាពលរដ្ឋត្រូវបំពេញតាមច្បាប់រដ្ឋបានចែងសម្រាប់ប្រជាពលរដ្ឋគ្រប់រូប

3. តើប្រជាពលរដ្ឋមានករណីយកិច្ចអ្វីខ្លះ ?

<u>ចម្លើយ</u> ប្រជាពលរដ្ឋមានករណីយកិច្ចដូចជា ៖

- បំពេញតួនាទីការពារជាតិ
- ត្រូវមានតួនាទីបង់ពន្ធអាករ
- មានតួនាទីគោរពច្បាប់

- មានតួនាទីសិក្សាវិជ្ជាផ្សេងៗ
- ត្រូវរក្សានូវរបបគ្រប់គ្រងរដ្ឋតាមរដ្ឋធម្មនុញ្ញ
- ត្រូវប្រើសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ សិទ្ធិធ្វើបេក្ខជន សិទ្ធិធ្វើប្រជាមតិដោយសេចក្ដីសុចរិត ដោយសម្លឹងឃើញផលប្រយោជន៍ជាតិ ។ល។

4. តើការគោរពច្បាប់មានសារៈសំខាន់ចំពោះប្រជាពលរដ្ឋដូចម្ដេចខ្លះ ?

<u>ចម្លើយ</u> ការគោរពច្បាប់មានសារៈសំខាន់ ចំពោះប្រជាពលរដ្ឋដូចជា ៖

- ការសម្ដែងនូវសកម្មភាពអាកប្បកិរិយា និងការប្រព្រឹត្តល្អចំពោះខ្លួនឯង គ្រួសារ និងសហគមន៍ ។
- គឺជាករណីយកិច្ច និងទំនួលខុសត្រូវរបស់ប្រជាពលរដ្ឋគ្រប់រូប
- គ្មានអំពើអមនុស្សធម៌ ដូចជា ការរំលោភបំពាន អំពើហិង្សា ចោរកម្ម ..
- ធ្វើឱ្យប្រជាពលរដ្ឋ មានការគោរពសិទ្ធិគ្នាទៅវិញទៅមក

5. ប្រសិនបើនរណាមករំលោភបំពានលើសេរីភាពរបស់អ្នក តើអ្នកត្រូវដោះស្រាយយ៉ាងដូចម្តេច ?

<u>ចម្លើយ</u> ប្រសិនបើនរណាមករំលោភបំពានលើសេរីភាពរបស់ខ្ញុំ ខ្ញុំត្រូវដោះស្រាយដោយ ធ្វើសេចក្តីណែនាំគេ កុំឱ្យប្រព្រឹត្តរបៀបនោះ ទៀត ។ ប្រសិនបើគេនៅតែបន្ត ខ្ញុំនឹងធ្វើសេចក្តីរាយការណ៍ជូនអជ្ញាធរមានសមត្ថកិច្ច ។

6. តើមនុស្សត្រូវអភិវឌ្ឍខ្លួនដូចម្តេចខ្លះ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិ ?

<u>ចម្លើយ</u> ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិ មនុស្សត្រូវអភិវឌ្ឍខ្លួនឯងដោយ ត្រូវតែជាមនុស្សល្អធ្វើអ្វីមានប្រយោជន៍ដល់សង្គមជាតិមិនបង្កភាពអសកម្មដល់សង្គម ពង្រីកជំនាញទទួលខុសត្រូវ ចំពោះសេដ្ឋកិច្ចគ្រួសារ គោរពច្បាប់ពន្ធដារមិនគេចវេះការបង់ពន្ធ រត់ពន្ធខុសច្បាប់ ពុំបានបង់ពន្ធជូនរដ្ឋដែលធ្វើឱ្យបាត់បង់ចំណូលជាតិ ។

7. តើសិទ្ធិមនុស្សបានអប់រំដូចម្តេចខ្លះ ?

<u>ចម្លើយ</u> សិទ្ធិមនុស្សបានអប់រំ ឱ្យមនុស្សចេះប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យសមស្របតាមព្រំដែនច្បាប់ និង គោរពសិទ្ធិ

អ្នកដទៃ ។ ចេះប្រើប្រាស់ក្នុងការស្វែងរកតម្រូវការនិងភាព យុត្តិធម៌ ។

## មេរៀនទី៥ ការសំដែងមតិ

### សំណួរចម្លើយ

1. តើប្រជាពលរដ្ឋមានសិទ្ធិសំដែលមតិនៅពេលណា ?

<u>ចម្លើយ</u> ប្រជាពលរដ្ឋមានសិទ្ធិសំដែលមតិនៅពេល មានការគាបសង្កត់ដោយមធ្យោបាយណាមួយឬសកម្មភាពដែលខុសច្បាប់បញ្ញត្តិបានចែង ។

2. តើការសំដែងមតិ ត្រូវប្រើអំពើហិង្សាឬទេ ? ព្រោះអ្វី ?

<u>ចម្លើយ</u> ការសំដែងមតិ មិនត្រូវប្រើអំពើហិង្សាទេ ព្រោះវាគ្រាន់តែជា សកម្មភាពមួយដែលបង្ហាញពីតម្រូវការរបស់ខ្លួនឱ្យអ្នកដទៃបានដឹងឮ និងស្វែងរកដំណោះស្រាយស្រាយឱ្យបានទាន់ពេលវេលាប៉ុណ្ណោះ ។ ហើយការសម្តែងមតិនេះ ធ្វើឡើងដោយស្របច្បាប់ និងប្រើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។

3. តើការសំដែងមតិរបស់សារព័ត៌មានត្រូវគោរពក្រមសីលធម៌អ្វីខ្លះ ?

ចម្លើយ ការសំដែងមតិរបស់សារព័ត៌មានត្រូវគោរពក្រមសីលធម៌ ដូចជា ៖

- គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងសច្ចធម៌របស់សាធារណៈជន ។
- ត្រូវផ្សាយដំណឹងដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយឬវិះគន់ឱ្យត្រឹមត្រូវនិងសមស្របតាមគតិយុត្តិធម៌
- ត្រូវរាយការណ៍ពីហេតុការណ៍ដែលខ្លួនបានដឹងពីប្រភពដើមប៉ុណ្ណោះ ។ អ្នកសារព័ត៌មានមិនត្រូវលុបចោលព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ ។
- ត្រូវកែតម្រូវព័ត៌មានណាដែលចេញរួចហើយដែលមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានភាពយល់ច្រលំ ។
- ត្រូវចៀសវាងការផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា មតិ ឬស្ថានភាពដទៃទៀត ។
- ត្រូវគោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល ។

- ត្រូវគោរពឱ្យបានម៉ត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរក្នុងការសរសេរអត្ថបទ ។
- ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពអំពើហិង្សា ។
- ហាមរំលោភលើសិទ្ធិដើម្បីមានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

4. តើការសំដែងមតិមានសារៈសំខាន់អ្វីខ្លះ ?

<u>ចម្លើយ</u> ការសំដែងមតិមានសារៈសំខាន់ដូចជា ៖

- ◆ ជាឧបករណ៍ដែលប្រាប់ហេតុការណ៍ពិតកើតឡើងដល់រដ្ឋាភិបាលបានដឹង និងរកវិធីដោះស្រាយទាន់ពេលវេលា ។
- ◆ ប្រាប់ពីគោលបំណង និងទុក្ខលំបាករបស់ខ្លួន ដល់អ្នកដឹកនាំបានដឹង
- ◆ សម្តែងនូវសិទ្ធិសេរីភាពផ្ទាល់ខ្លួន ដើម្បីបង្ហាញការយល់ព្រមនិងមិនព្រមចំពោះបុគ្គលសាធារណៈ ឬក្រុមហ៊ុនដាក់ការគាបសង្កត់លើខ្លួន ។

5. តើការសំដែងមតិត្រូវការទទួលខុសត្រូវឬទេ ? ព្រោះអ្វី ?

ចម្លើយ ការសំដែងមតិត្រូវការទទួលខុសដែរ ព្រោះថា ថ្វីត្បិតតែការសម្តែងមតិជាសិទ្ធិសេរីភាពមែនពិត តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គល កិត្តិយស កេរ្តិ៍ឈ្មោះ មាក់ងាយបង្កភាពញុះញង់ គ្មានសីលធម៌ ដែលធ្វើឱ្យបាត់បង់ស្ថិរភាពសង្គម និងខុសច្បាប់ ។

## មេរៀនទី៦ កិច្ចការពារសិទ្ធិរបស់ខ្លួន

### សំណួរចម្លើយ

1. ដូចម្តេចដែលហៅថា ការរំលោភសិទ្ធិមនុស្ស ?

ចម្លើយ ដែលហៅថា *ការរំលោភសិទ្ធិមនុស្ស* គឺជាទង្វើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតរស់នៅ សេចក្តីថ្លៃថ្នូរ កិត្តិយស និងបាត់បង់ផលប្រយោជន៍ដោយអំពើរំលោភខុសច្បាប់ ។

2. តើទង្វើណាខ្លះដែលចាត់ទុកថា ជាសកម្មភាពរំលោភសិទ្ធិមនុស្ស ?

ចម្លើយ ទង្វើដែលចាត់ទុកថា ជាសកម្មភាពរំលោភសិទ្ធិមនុស្សមានដូចជា ៖

- អំពើហិង្សា ការរំលោភបំពានលើផ្លូវចិត្ត ផ្លូវកាយ ភេទ (វាយធ្វើបាប សម្លុត ធ្វើទារុណកម្ម ចាប់បង្ខំ ចាប់ពង្រាត់ ...)
- ការកេងប្រវ័ញ្ច លើកម្លាំងពលកម្ម
- ការសម្លាប់
- ការបោកបញ្ឆោត
- បង្អត់អាហារ
- ការជួយដូរដោយអយុត្តិធម៌
- ការបង្កសម្លេងរំខាន ។ល។

3. តើអ្នកធ្វើដូចម្តេចបើមាននរណាម្នាក់រំលោភលើសិទ្ធិអ្នក ?

<u>ចម្លើយ</u> បើមាននរណាម្នាក់រំលោភលើសិទ្ធិខ្ញុំ ខ្ញុំត្រូវការពារតាមផ្លូវច្បាប់ដោយស្វែងរកសាក្សី ហើយរាយការណ៍អាជ្ញាធរមានសមត្ថកិច្ចក្នុងភូមិ ឬឃុំ ដែលពួកគាត់មានទំនួលខុសត្រូវការស្វែងរកយុត្តិធម៌ និងមានសមត្ថភាពអាចដោះស្រាយបញ្ហានេះបាន ។

4. ដូចម្តេចដែលហៅថា ដីកា ? ប្រភេទដីកា មានអ្វីខ្លះ ?

ចម្លើយ ដែលហៅថា *ដីកា* គឺជាសេចក្តីសម្រេចរបស់អំណាចតុលាការដែលចេញដោយចៅក្រមម្នាក់ឯងឬ ព្រះរាជអាជ្ញារង ។ ប្រភេទដីកាមាន ដីកាលើលែងចោទប្រកាន់ ដីកាដោះលែងបណ្តោះអាសន្ន និងដីកាឃុំខ្លួន ។

5. តើមេធាវីមានមុខងារ ធ្វើអ្វី ? តើមេធាវីមានតួនាទី និងសិទ្ធិធ្វើអ្វីខ្លះ ?

ចម្លើយ មេធាវីមានមុខងារ ការពារកូនក្តី និងទទួលឯកសារសំណុំរឿងទាក់ទងពីការចោទប្រកាន់កូនក្តីរបស់ខ្លួន ។ តើមេធាវីមានតួនាទី និងសិទ្ធិដូចជា ៖

- ត្រូវរៀបចំពាក្យបណ្តឹងទៅតុលាការនៅពេលមានគេមកពឹងពាក្យគេជំនួយ ។
- ជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី ។
- ត្រូវចុះទៅជាមួយចៅក្រម នៅពេលមានការឆែកឆេរផ្ទះជនជាប់ចោទ។
- អាចទាក់ទងកូនរបស់ខ្លួនដោយសេរីគ្រប់ពេលតែមិនអាចប្រគល់ឯកសារឬវត្ថុអ្វីមួយដល់កូនក្តីរបស់ខ្លួនដោយគ្មានការអនុញ្ញាត ពីចៅក្រមស៊ើបអង្កេតឡើយ ។

- មានសិទ្ធិអានសំណុំរឿងក្នុងរយៈពេលខ្លីបន្ទាប់ពីចៅក្រមបញ្ចប់ការស៊ើបអង្កេត ។
- មានសិទ្ធិអានសំណុំរឿង ឬថតចម្លងឯកសារនោះបាន បើយល់ថា វាជាការចាំបាច់ ។

៦. ចូរអ្នករកដំណោះស្រាយតាមផ្លូវច្បាប់ ក្នុងករណីដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការដោយពុំមានភស្តុតាង (អ្នកពុំបានប្រព្រឹត្តខុសទេ) ។

<u>ចម្លើយ</u> រកដំណោះស្រាយតាមផ្លូវច្បាប់ ក្នុងករណីដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការដោយពុំមានភស្តុតាង (អ្នកពុំបានប្រព្រឹត្តខុសទេ) ។

យើងត្រូវបង្ហាញបញ្ជាក់ទៅតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចថា យើងពុំបានប្រព្រឹត្តអំពើនោះទេ ។ យើងត្រូវសួររកភស្តុតាងដល់ដើមចោទ ។ ម្យ៉ាងទៀតយើងត្រូវស្វែងរកសាក្សីណាមួយដែលបញ្ជាក់បានថា យើងពិតជាពុំបានប្រព្រឹត្តអំពើនោះមែន ។

## សំណួរបញ្ចប់ជំពូក ៣

I. ចូរគូសសញ្ញា ✓ នៅមុខឃ្លាដែលត្រឹមត្រូវឬ × ខាងមុខឃ្លាដែលមិនត្រឹមត្រូវ

១. ——— នីតិរដ្ឋសំដៅយកការអនុវត្តច្បាប់បានត្រឹមត្រូវ ។

២ ——— មន្ត្រីរាជការមានសិទ្ធិពិសេសចំពោះមុខច្បាប់ ។

៣. ——— ស្ថាប័នសភា និងព្រឹទ្ធសភាមានតួនាទីដូចគ្នា ។

៤.——— ស្ថាប័នតុលាការស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋាភិបាល ។

៥. ——— ប្រជាជនមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ។

II. ចូរឆ្លើយនឹងសំណួរខាងក្រោមនេះ

១. តើជនជាប់ចោទរកវិធីការពារខ្លួនដូចម្ដេចខ្លះ ?

២.តើមូលហេតុអ្វីបានជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផ្លាស់ប្ដូរជាញឹកញាប់ ?

៣. តើមូលហេតុអ្វីបានជាមានការផ្លាស់ប្ដូររូបមន្តនៃការបោះឆ្នោតពីរូបមន្ត ២/៣ មក ៥០+១ វិញ ?

៤. តើអ្នកដែលមានគំនិតផ្ដួចផ្ដើមរដ្ឋធម្មនុញ្ញខ្មែរមុនគេឈ្មោះអ្វី ? ប្រទេសខ្មែរបានទទួលឯករាជ្យឬទេ ?

៥. តើព្រះរាជក្រម និងព្រះរាជក្រឹតខុសគ្នាត្រង់ណា ?

III. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. កងកម្លាំងប្រដាប់អាវុធជា:

☐ ក. កម្លាំងសម្រាប់ការពារអ្នកមានអំណាច

☐ ខ. កម្លាំងសម្រាប់បម្រើគណបក្សណាមួយ

☐ គ. កម្លាំងរបស់ជាតិប្រឆាំងអព្យាក្រិតភាព

☐ ឃ. កម្លាំងរបស់អគ្គសេនាធិការជាតិ

២. រដ្ឋាភិបាលជា:

☐ ក. អង្គការនីតិប្បញ្ញត្តិ

☐ ខ. អង្គការក្រៅរដ្ឋាភិបាល

☐ គ. អង្គការនីតិប្បញ្ញត្តិ និងទទួលខុសត្រូវដឹកនាំប្រទេស

☐ ឃ. អង្គការនីតិប្រតិបត្តិ និងទទួលខុសត្រូវដឹកនាំប្រទេសជាតិ

៣. ប្រជាពលរដ្ឋខ្មែរមានសិទ្ធិ

☐ ក. ស្មើគ្នាចំពោះមុខច្បាប់

☐ ខ. ចំពោះតែបុរសប៉ុណ្ណោះ

☐ គ. ចំពោះមន្ត្រីរាជការ

☐ ឃ. មិនដូចគ្នាទេ

IV. ចូររកពាក្យមកបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

១.ព្រះរាជាណាចក្រកម្ពុជាប្រកាន់របបនយោបាយ ...............។

២.ប្រជាពលរដ្ឋមានសិទ្ធិ...........ជ្រើសរើសតំណាងរបស់ខ្លួន ។

៣. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកអំណាចជា.......គឺ..........។

៤.នគរបាលយុត្តិធម៌អាចឃុំខ្លួនជនជាប់ចោទមិនលើស..........។

៥.មេធាវីជាអ្នកការពារ .........................................។

<u>ចម្លើយ</u>

I. គូសសញ្ញា ✓ ឬ × ខាងមុខល្បះខាងក្រោម

១. ✓

២. ×

៣. ×

៤. ×

៥. ✓

II. ឆ្លើយនឹងសំណួរ

១.ជនជាប់ចោទរកវិធីការពារខ្លួនដោយសុំឱ្យតុលាការរក យុត្តិធម៌ជូនខ្លួន រួមទាំងប្តឹងឱ្យសងជម្ងឺចិត្តវិញ ។

២.បានជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផ្លាស់ប្តូរជាញឹក ញាប់ ដោយសារ ៖

- វិបត្តិនយោបាយ
- ការផ្លាស់ប្តូររបបដឹកនាំ ឬអ្នកដឹកនាំ
- សម័យកាលនិមួយៗ ...។

៣. បានជាមានការផ្លាស់ប្តូររូបមន្តនៃការបោះឆ្នោតពីរូបមន្ត ២/៣ មក ៥+១ វិញ ព្រោះរដ្ឋសភាបានធ្វើវិសោធនកម្មច្បាប់បោះ ឆ្នោត ពី២/៣មក ៥+១ ដោយនៅអាណត្តិទី ៤ សម្លេងឆ្នោត មានលក្ខណៈប្រហាក់ប្រហែលគ្នា ។

៤.អ្នកដែលមានគំនិតផ្តួចផ្តើមរដ្ឋធម្មនុញ្ញខ្មែរមុនគេឈ្មោះ ព្រះអង្គម្ចាស់ *ស៊ីសុវត្ថិ យុត្តិវង្ស* ។ ប្រទេសខ្មែរពុំទាន់បាន ទទួលឯករាជ្យនៅឡើយទេ ។

៥. ព្រះរាជក្រម និងព្រះរាជក្រិតខុសគ្នាត្រង់ថា ៖

- *ព្រះរាជក្រម*ជាលិខិតបទដ្ឋានគតិយុត្តិដែលចេញដោយព្រះមហាក្សត្រ សម្រាប់ប្រកាសឱ្យប្រើច្បាប់ក្រោយពីរដ្ឋសភាបានអនុម័តនិងពិនិត្យ ដោយព្រឹទ្ធសភារួចហើយ ។
- *ព្រះរាជក្រិត*ជាលិខិតបទដ្ឋានគតិយុត្តិដែលចេញដោយព្រះមហាក្សត្រ សម្រាប់តែងតាំងមន្ត្រីជាន់ខ្ពស់ ។

III.គូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. កងកម្លាំងប្រដាប់អាវុធជាៈ

☑ គ. កម្លាំងរបស់ជាតិប្រកាន់អព្យាក្រិតភាព

២. រដ្ឋាភិបាលជាៈ

☑ឃ.អង្គការនីតិប្រតិបត្តិ និងទទួលខុសត្រូវដឹកនាំប្រទេសជាតិ

៣. ប្រជាពលរដ្ឋខ្មែរមានសិទ្ធិ

☑ ក. ស្មើគ្នាចំពោះមុខច្បាប់

IV. បំពេញល្បះខាងក្រោម

១. *លទ្ធិប្រ[redacted]តេយ្យសេរីពហុបក្ស*

២. ពោះវៀន

៣. ៣ គឺ នីតិប្[illegible]ប្រតិបត្តិ និង តុលាការ

៤. ៤៨ ម៉ោង

៥. កូនក្ដីរបស់ខ្លួន ។

# គេហវិទ្យា

# សុខមាលភាពគ្រួសារនិងការចាត់ចែងក្នុងគេហដ្ឋាន

## មេរៀនទី១ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន

### សំណួរចម្លើយ

1. ចូរអ្នករៀបរាប់ពីទិដ្ឋភាពនៃការរីកចម្រើនរបស់សហគមន៍ដែលអ្នករស់នៅក្នុងរយៈ ១០ ឆ្នាំកន្លង និងបកស្រាយសូចនាករ (អាំងឌីកាទ័រ) ខាងក្រោមនេះ

| | ១៩៦០ | ១៩៩០ | ២០០០ | ២០០៥ | ២០០៤ | ២០០៧ | ២០០៨ | ២០០៩ |
|---|---|---|---|---|---|---|---|---|
| ផលិតផលក្នុងស្រុកសរុប(លានដុល្លាអាមេរិច) | ៥៧៧ | ១៤០៤ | ៣៦៤៩ | ៦២៩៣. | ៧២៧៥ | ៨៦៣៨ | ១១០២៣ | ១២៤៤៥ |
| អត្រាកំណើន | ៤.៨% | ៤.៥% | ៤.៨% | ១៣.៣% | ១០.៨% | ១០.២% | ៧.០% | ៦.០% |
| ផលិតផលក្នុង | ៨ | ១ | ២៨ | ៤៥ | ៥១ | ៥៩ | ៧៥ | ៨៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ស្រុករបស់មនុស្សម្នាក់ (លានដុល្លាអាមេរិច) | ៣ | ៣៦ | ៨ | ៥ | ៤ | ៨ | ១ | ៤ |
| អត្រាកំណើនផលិតផលក្នុងស្រុករបស់មនុស្សម្នាក់ | - | ៩.៥% | ២.៤% | ១៥.៥% | ១២.៩% | ១៦.៤% | ២៥.៦% | ១១.១% |

ប្រភព: វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ទិន្នន័យបឋមដកស្រង់ពីឯកសាររដ្ឋាភិបាលនិងអង្គការអន្តរជាតិ

ចម្លើយ បកស្រាយសូចនាករ (អាំងឌីការទ័រ)៖

នៅឆ្នាំ ១៩៦០ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ៥៧៧លានដុល្លាអាមេរិចបើគិតជាអត្រាកំណើនមាន១.៨%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ៨៣ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនមិនច្បាស់លាស់ ។

នៅឆ្នាំ ១៩៩០ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ១៨០៨លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន

៤.៥%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ១៣៦ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ៩.៥% ។ នៅឆ្នាំ ២០០០ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ៣៦៤៩លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន ៤,៨%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ២៨៨ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ២.៥% ។ នៅឆ្នាំ ២០០៥ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ៦២៩៣លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន ១៣.៣%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ៤៥៥ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ១៥.៥% ។

នៅឆ្នាំ ២០០៨ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ២៧៥លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន ១.៨%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ៥១៨ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ១២.៩% នៅឆ្នាំ ២០០៧ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ៨៦៣៨លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន

•១០.២%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ៥៩៨ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ១៦.៨% នៅឆ្នាំ ២០០៨ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ១១០២៣លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន ៧.០%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ៧៥១ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ២៥.៦% នៅឆ្នាំ ២០០៩ ប្រទេសកម្ពុជាមានផលិតផលក្នុងស្រុកសរុប ១២៨៤៥លានដុល្លាអាមេរិច បើគិតជាអត្រាកំណើនមាន ៦.០%។ បើគិតពីផលិតផលក្នុងស្រុករបស់មនុស្សម្នាក់មាន ៨៣៤ លានដុល្លាអាមេរិច បើគិតពីអត្រាកំណើនគឺ ១១.១%

2. ចូរពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយសំណួរ ដូចខាងក្រោម

ក.តើក្រុមគ្រួសាររបស់អ្នកអាចរកប្រាក់ចំណូលជាមធ្យមបាន ប៉ុន្មានក្នុងមួយឆ្នាំ ?បើគិតតាមបុគ្គលតើសមាជិកម្នាក់ៗរក ប្រាក់ចំណូលជាមធ្យមបានប៉ុន្មានក្នុងមួយឆ្នាំ ?

ខ. តើអ្នកគិតថាសេដ្ឋកិច្ចជាតិកម្ពុជាបានពឹងផ្អែកលើវិស័យ សំខាន់ៗ អ្វីខ្លះ ? ចូររៀបរាប់ ។

គ. តើអ្នកមើលឃើញសេដ្ឋកិច្ចជាតិកម្ពុជាមានការរីកចម្រើនឡើងឬថយចុះ ? តើអ្នកសំគាល់លើអ្វី ?

ឃ. តើប្រទេសកម្ពុជាមានប្រភពធនធានអ្វីខ្លះដែលអាចយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យបានកំណើនទៅមុខ ? តើអ្នកគិតថាធនធានទាំងនោះ ត្រូវប្រើប្រាស់ដោយរបៀបណា ? ហេតុអ្វី ?

<u>ចម្លើយ</u> *ចូរពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយសំណួរដូចខាងក្រោម*

ក.ក្រុមគ្រួសាររបស់ខ្ញុំអាចរកប្រាក់ចំណូលជាមធ្យមបាន ២ពាន់ដុល្លាក្នុងមួយឆ្នាំ ។(ឧ.ផ្តោតលើគ្រួសារនីមួយៗ)

បើគិតតាមបុគ្គល សមាជិកម្នាក់ៗរកប្រាក់ចំណូលជាមធ្យមបាន៣០០ដុល្លាក្នុងមួយឆ្នាំ ។ (ឧ.ផ្តោតលើគ្រួសារនីមួយៗ)

ខ.ខ្ញុំគិតថាសេដ្ឋកិច្ចជាតិកម្ពុជាបានពឹងផ្អែកលើវិស័យសំខាន់ៗ ដូចជា ៖

- កសិកម្ម
- ឧស្សាហកម្ម
- សេវាកម្ម

- ការគ្រប់គ្រង និងការប្រើប្រាស់ធនធាន។

គ.ខ្ញុំមើលឃើញថាសេដ្ឋកិច្ចជាតិកម្ពុជាមានការរីកចម្រើនឡើង ។ សំគាល់លើ មានការនាំចូលនូវបច្ចេកទេសទំនើបៗ ការងារកើនឡើង កំនើននៃឧស្សាហកម្ម តម្លៃនៃទំនិញឡើងថ្លៃ ចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកើនឡើង ។

ឃ. ប្រទេសកម្ពុជាមានប្រភពធនធាន ដែលអាចយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យបានកំណើនទៅមុខ ដូចជា៖

- ធនធានធម្មជាតិ (រ៉ែប្រេងកាត ត្បូងថ្ម ដែក មាស ព្រៃឈើ...)
- មរតកវប្បធម៌និងសម្បត្តិវប្បធម៌ (ចម្រៀង របាំប្រពៃណី ប្រាសាទ...)
- ធនធានមូលធនហិរញ្ញវត្ថុ (ពន្ធដារ)
- ធនធានមនុស្ស
- សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម
- អភិបាលកិច្ចល្អ

ខ្ញុំគិតថាធនធានទាំងនោះ ត្រូវប្រើប្រាស់ដោយមានការចូលរួមពីប្រជាជនខ្មែរគ្រប់រូប និងមានភាពត្រឹមត្រូវយុត្តិធម៌ ស្របច្បាប់ ព្រោះ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានការកើនឡើង ហើយប្រជាពលរដ្ឋមានសិទ្ធិស្មើគ្នា ក្នុងការប្រើប្រាស់ធនធានទាំងនោះ ។

## មេរៀនទី២ **ស្ថានភាពសេដ្ឋកិច្ចគ្រួសារខ្មែរ**

### <u>សំណួរចម្លើយ</u>

1. តើគ្រួសារជាអ្វី ? តើសមាសភាពគ្រួសារមាននរណាខ្លះ ?

<u>ចម្លើយ</u> គ្រួសារជា កោសិការសង្គម ។ ហើយគ្រួសារក៏ជាមនុស្សមួយក្រុមដែលជាប់សាច់ឈាមគ្នាតាមរយៈអាពាហ៍ពិពាហ៍ ពូជពង្ស ឬកុលសម្ព័ន្ធ ។ សមាសភាពគ្រួសារមាន ជីដូនជីតា ឪពុកម្តាយ កូន ចៅ ក្មួយ ...។

2. តើបម្រែបម្រួលសមាសភាពសមាជិកគ្រួសារកើតមានឡើងដូចម្តេចខ្លះ ?

ចម្លើយ បម្រែបម្រួលសមាសភាពសមាជិកគ្រួសារកើតមានឡើង ដោយការនិរាសព្រាត់ប្រាសលែងលះគ្នា មានអ្នករងគ្រោះថ្នាក់ផ្សេងៗ មានអ្នកពិការ មានអ្នកជម្ងឺឬទទួលមរណៈភាព ...។

3. តើអ្វីជាមូលហេតុនៃបម្រែបម្រួលសមាសភាពសមាជិកគ្រួសារ ?

ចម្លើយ មូលហេតុនៃបម្រែបម្រួលសមាសភាពសមាជិកគ្រួសារគឺ:

- ភាពចលាចលនៃសង្គ្រាម ឆ្នាំ ១៩៧០ ធ្វើឱ្យប្រជាជនកម្ពុជាមួយចំនួនស្លាប់ និរាសព្រាត់ប្រាស់ និងរស់នៅបែកគ្នា
- ពី១៩៧៥-១៩៧៩ ប្រជាជនផ្លាស់ទីលំនៅពាសពេញប្រទេសនិងសម្លាប់រង្គាលធ្វើឱ្យគ្រួសារកាន់តែព្រាត់ប្រាស់
- ឆ្នាំ១៩៧៩ប្រជាជនដែលរស់រានមានជីវិតសល់ពីការស្លាប់ក្នុងរបបពលពុលពត ខ្លះបានត្រឡប់មករស់នៅស្រុកកំណើតវិញ ខ្លះក៏ទៅរស់នៅក្នុងជំរុំជនភៀសខ្លួនតាមបណ្តោយព្រំដែនកម្ពុជា-ថៃហើយខ្លះទៀត ក៏បាន

ទៅរស់នៅប្រទេសទីបី ដែលធ្វើឱ្យដាច់ទំនាក់ទំនងជាមួយសាច់ញាតិមិត្ត

- ក្រោយឆ្នាំ ១៩៧៩ គ្រួសារខ្មែរភាគច្រើនបាត់បង់ឪពុក សល់តែស្ត្រីជាម្ដាយ និងកូនតូចៗ ។

4. តើបម្រែបម្រួលសមាសភាពសមាជិកគ្រួសារមានផលវិបាកដូចម្ដេច ?

<u>ចម្លើយ</u> បម្រែបម្រួលសមាសភាពសមាជិកគ្រួសារមានផលវិបាកដូចជា៖

- កង្វះអ្នកថែទាំកុមារ ឬកង្វះការយកចិត្តទុកដាក់ថែទាំកុមារឱ្យបានដិតដល់
- លទ្ធភាពថែទាំកុមារនៅមានកម្រិត បើប្រៀបធៀបសម័យមុនសង្គ្រាម
- កង្វះធនធានសម្រាប់ផ្ដល់ឱ្យអ្នកជួយមើលថែទាំកុមារ

ផលវិបាកទាំងនេះ ពាក់ព័ន្ធយ៉ាងខ្លាំងលើលទ្ធភាពរបស់ឪពុកម្ដាយឬអាណាព្យាបាលក្នុងការការពារ និងគោរពសិទ្ធិកុមារឱ្យបានពេញលេញ ។

5. តើកុមារទទួលផលប៉ះពាល់ពីបម្រែបម្រួលសមាសភាពសមាជិកគ្រួសារយ៉ាងដូចម្ដេច ?

<u>ចម្លើយ</u> កុមារទទួលផលប៉ះពាល់ពីបម្រែបម្រួលសមាសភាពសមាជិកគ្រួសារដូចជា ៖

- ធ្វើឱ្យកុមារបាត់បង់អាណាព្យាបាល
- បាត់បង់អ្នកគ្រប់គ្រង ឬបាត់បង់អ្នកថែរក្សាពួកគេ
- គ្មានអ្នកផ្ដល់ដំបូន្មាន លួងលោម ជាហេតុធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ផ្នែករាងកាយ ប្រាជ្ញា ស្មារតី ចិត្តគំនិត និងទំនាក់ទំនងក្នុងសង្គមរបស់កុមារ ។

6. តើថវិកាចំណូលប្រចាំខែគិតជាមធ្យមរបស់គ្រួសារខ្មែរមានចំនួនប៉ុន្មាន? តើថវិកា ចំណូលនេះ មានប្រភពពីរបរអ្វី ?

<u>ចម្លើយ</u>ថវិកាចំណូលប្រចាំខែគិតជាមធ្យមរបស់គ្រួសារខ្មែរមានចំនួន៦៩.៥ លានដុល្លានអាមេរិច ក្នុងឆ្នាំ ២០០៩ ថវិកាចំណូលនេះ មានប្រភពពីរបរធ្វើកសិកម្ម និងការងារក្នុងប្រព័ន្ធរួមមានវិស័យកាត់ដេរ ទេសចរណ៍ និងរដ្ឋបាលសាធារណៈ ។

7. តើការចំណាយប្រចាំខែជាមធ្យមរបស់គ្រួសារខ្មែរមាន

ចំនួនប៉ុន្មាន ? តើគេចំណាយលើអ្វីខ្លះ ?

ចម្លើយ ការចំណាយប្រចាំខែជាមធ្យមរបស់គ្រួសារខ្មែរមាន ៩៥ដុល្លារលើម្ហូបអាហារ ។ នៅភ្នំពេញ ២៦៤ ដុល្លាចំណាយលើការប្រើប្រាស់ ចំណែកនៅឯជនបទ ចំណាយត្រឹមតែ ៧៥ដុល្លា ។

8. តើថវិកាចំណូល និងចំណាយរបស់ពលរដ្ឋកម្ពុជាមានតុល្យភាពនឹងគ្នាដែរឬទេ ?

ចម្លើយ ថវិកាចំណូល និងចំណាយរបស់ពលរដ្ឋកម្ពុជាមិនមានតុល្យភាពនឹងគ្នា ទេ ។

9. តើឱនភាពថវិកាគ្រួសារបណ្តាយមកពីមូលហេតុអ្វីខ្លះ ?

*ការងារប្រតិបត្តិ:*

ចូរអ្នកសរសេររៀបរាប់សមាសភាពសមាជិកគ្រួសារ របៀបមើលថែទាំអប់រំសមាជិក និងស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារអ្នក ។

ចម្លើយ ឱនភាពថវិកាគ្រួសារបណ្តាយមកពីមូលហេតុ:

- កង្វះទម្លាប់ម្ចាស់ការក្នុងការដាំដុះនិងចញ្ចឹមសត្វសម្រាប់ផ្គត់ផ្គង់អាហារក្នុងគ្រួសារផ្ទាល់

- ការមិនទាន់មានឆន្ទៈទៅតាំងទីលំនៅនៅក្នុងតំបន់ដីសម្បទានសង្គមកិច្ចដែលមានដីទំនេរអាចប្រកបរបរកសិកម្មបាន
- ការចំណាយច្រើនទៅលើសេវាផ្សេងៗ ដូចជា សេវាដឹកជញ្ជូន ថែទាំសុខភាព ការពារសន្តិសុខ ជាដើម...។ល។
- កង្វះឆន្ទៈក្នុងការថែរក្សាទ្រព្យសម្បត្តិសាធារណៈឬទ្រង់ប្រយោជន៍រួមមានដូចជា ការចូលរួមកិច្ចការសាធារណៈ ការពារទ្រព្យសម្បត្តិសាធារណៈជាដើម ព្រោះសម្បត្តិសាធារណៈជាប្រយោជន៍រួមជាមូលដ្ឋានគ្រឹះនៃសម្បត្តិឯកជន ។
- បណ្តោតបណ្តោយខ្លួនឬសមាជិកខ្លួនឱ្យធ្លាក់ក្នុងអំពើអបាយមុខផ្សេងៗ
- ការខ្វះគំនិតផ្តួចផ្តើមក្នុងការបង្កើតការងារដោយខ្លួនឯង
- ការពឹងផ្អែកទៅលើរបបកសិកម្មប្រចាំគ្រួសារតែមួយដងក្នុងមួយឆ្នាំ ឬតែដំណាំមួយមុខប៉ុណ្ណោះ...។

## មេរៀនទី៣ គេហកិច្ច និងការគ្រប់គ្រងគ្រួសារ

### សំណួរចម្លើយ

1. ដូចម្តេចដែលហៅថា ការងារគេហកិច្ច ? ដើម្បីបំពេញការងារគេហកិច្ចតើគេត្រូវធ្វើអ្វីខ្លះ ?

__ចម្លើយ__ ដែលហៅថា ការងារគេហកិច្ច គឺជាកិច្ចក្នុងផ្ទះសំដៅដល់ការងាររៀបចំចាត់ចែង ការសន្សំសំចៃ ការថ្នមការប្រយ័ត្នប្រយែងមិនឱ្យគ្រោះថ្នាក់ ឬអន្តរាយកើតមានឡើងដល់សមាជិកណាមួយក្នុងគ្រួសារ ។ ដើម្បីបំពេញការងារគេហកិច្ចគេត្រូវរៀចចំចាត់ចែងជាមុននូវផែនការនានាសម្រាប់គ្រួសារ ។

2. ចូរពន្យល់ពីរបៀបធ្វើផែនការសេដ្ឋកិច្ចក្នុងគ្រួសារ ?

__ចម្លើយ__ ពន្យល់ពីរបៀបធ្វើផែនការសេដ្ឋកិច្ចក្នុងគ្រួសារៈ មានបួនដំណាក់កាល

✧ ផែនការបង្កើនថវិកាចំណូលៈ គឺការរៀបចំគម្រោងឬមធ្យោបាយមួយចំនួន ដើម្បីឱ្យមានកំណើននៃប្រាក់ចំណូលក្នុងគ្រួសារមានដូចជា ការច្នៃប្រឌិត បង្កើតមុខរបរអាជីវកម្មគ្រួសារ ការស្វែងរកការងារក្រៅម៉ោងធ្វើបន្ថែមដោយស្របច្បាប់ ការសិក្សាបន្ថែមជំនាញអាជីពជាដើម ។ល។

✧ ផែនការចំណាយៈ គឺជាការរៀបចំបម្រុងថវិកាធនធានឬ ធនធាននិងកំណត់មុខចំណាយក្នុងគ្រួសារឱ្យបានជាក់លាក់ ។ ជាទូទៅគ្រួសារខ្មែរតែងត្រៀមថវិកាដែលរកបានសម្រាប់មុខចំណាយសំខាន់ៗដូចជា៖

- ☛ ស្បៀងអាហារ និងការហូបចុកប្រចាំថ្ងៃ
- ☛ សម្លៀកបំពាក់ និងថ្នាំសង្កូវ
- ☛ ការតុបតែងលំអឬជួសជុលលំនៅដ្ឋាន
- ☛ ការសិក្សារៀនសូត្រ របស់កូនចៅនិងការបង់ពន្ធអាករផ្សេងៗ...

✧ ផែនការសន្សំសំចៃៈ ជាគម្រោងការងារឬសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងការសំចៃដែលជានាដល់និរន្តរភាពនៃការប្រើប្រាស់ ឬចំណាយ ។

✧ ផែនការបង្កើតធនសំចៃឬប្រាក់សំចៃៈ គឺជាគម្រោងការងារឬសកម្មភាពប្រែក្លាយធនសំចៃឬប្រាក់សំចៃឱ្យទៅជាដើមទុនប្រាក់ចំណេញ ។ ជាធម្មតាគេបង្កើតធនសំចៃឬប្រាក់សំចៃតាមវិធីដូចខាងក្រោម៖

- ការសន្សំដោយបន្ថែមគ្មានឈប់ឈរនូវប្រាក់សន្សំ

(ឧ. សន្សំដាក់កូនជ្រូក)

- ការប្រែក្លាយប្រាក់សំចៃឱ្យក្លាយទៅជាទុនអាជីវកម្ម (ឧ. ចិញ្ចឹមជ្រូក..) ពាណិជ្ជកម្ម (ឧ. ទិញជ្រូកលក់...) ឬផលិតកម្មណាមួយ (ឧ. សិប្បកម្មផលិតឆៀតសាច់ជ្រូក)ដើម្បីបង្កើតប្រាក់ចំណេញតាមរយៈការចូលភាគហ៊ុន ឬបើកផ្កាច់មុខ ។ការយកប្រាក់ទៅសន្សំក្នុងធនាគារ (ហៅថាគណនេយ្យសន្សំសំចៃ) ដើម្បីបង្កើតការប្រាក់ ដែលមានសមាមាត្រតាមចំនួនប្រាក់ និងរយៈពេលដែលបានកំណត់ ។

3. ដូចម្តេចដែលហៅថា ផែនការគ្រួសារ ? ហេតុអ្វីចាំបាច់ធ្វើផែនការគ្រួសារ ?

<u>ចម្លើយ</u> ដែលហៅថា ផែនការគ្រួសារ គឺជាបច្ចេកស័ព្ទទំនើបសំដៅលើមធ្យោបាយមួយចំនួនដែលត្រូវបានកំណត់ទុកជាមុន ដើម្បីរក្សាប្រក្រតីភាព ឬនិយ័តភាពនៃលទ្ធភាពបង្កើតកូន និងចិញ្ចឹមបីបាច់ថែរក្សាបុត្រធីតា ។ បានជាចាំបាច់ធ្វើផែនការគ្រួសារ ព្រោះងាយស្រួលក្នុងការកំណត់នូវគោលដៅនៃ

គ្រួសារជាមុន ធ្វើឱ្យឪពុកម្តាយមានពេលវេលាគ្រប់គ្រាន់ក្នុងការរកស៊ី និងធ្វើឱ្យគ្រួសារមានភាពសុខសាន្ត។

4. ដូចម្តេចដែលហៅថា " ការគ្រប់គ្រងគ្រួសារ " ?

ចម្លើយ ដែលហៅថា " ការគ្រប់គ្រងគ្រួសារ " គឺជាការដឹកនាំមើលខុសត្រូវ ការថែទាំ និងអប់រំសមាជិកគ្រួសារ ។

5. ក្នុងនាមអ្នកជាសមាជិកម្នាក់ក្នុងគ្រួសារ តើអ្នកគិតថា អ្នកត្រូវបំពេញភារកិច្ចអ្វីខ្លះ ? ដើម្បីអ្វី ?

ចម្លើយ ក្នុងនាមអ្នកជាសមាជិកម្នាក់ក្នុងគ្រួសារ ខ្ញុំគិតថា ខ្ញុំត្រូវបំពេញភារកិច្ចដូចជា ចេះជួយធ្វើកិច្ចការងារផ្ទះ គោរពស្រលាញ់បងប្អូន ឪពុកម្តាយ ស្តាប់បង្គាប់ ត្រូវមានទំនួលខុសត្រូវ ជួយថែរក្សាទ្រព្យសម្បត្តិ និងជាអ្នកសិក្សារៀនសូត្រ ។

6. តើការងារគេហកិច្ច និងការគ្រប់គ្រងគ្រួសារមានសារៈសំខាន់យ៉ាងណាខ្លះ ? ហេតុអ្វី ?

ចម្លើយ ការងារគេហកិច្ច និងការគ្រប់គ្រងគ្រួសារមានសារៈសំខាន់ណាស់ដូចជាសម្រាប់មនុស្សគ្រប់រូប ព្រោះវាធ្វើឱ្យមនុស្សមានទម្លាប់ក្នុងការធ្វើការងារផ្ទះ ធ្វើយ៉ាងណាឱ្យគ្រួសារមានសោភ័ណភាព និងមានសុភមង្គល ។

## មេរៀនទី៤ **តរិយាបថបំពេញភារងារក្នុងគ្រួសារ**

### <u>សំណួរចម្លើយ</u>

1. តើការងារក្នុងគ្រួសារមានប៉ុន្មានប្រភេទ ? គឺអ្វីខ្លះ ?

<u>ចម្លើយ</u> ការងារក្នុងគ្រួសារមាន ប្រាំបួន ប្រភេទ គឺ៖

- ការងារគ្រប់គ្រងគ្រួសារ
- ការងារផលិតស្បៀងប្រចាំគ្រួសារ ឬអាជីវកម្មគ្រួសារ
- ការងារគ្រប់គ្រងធនធាន
- ការងារការពារសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងគ្រួសារ
- ការងារផ្ទះបាយ
- ការងារផ្គត់ផ្គង់ទឹក និងថាមពល
- ការងារថែទាំសុខភាព
- ការងារសាងសង់និងជួសជុល
- ការងារលើកកម្ពស់ការរៀនសូត្រ...។

2. តើប្រភេទការងារនីមួយៗក្នុងគ្រួសារមានសារៈសំខាន់បែបណា? ហេតុអ្វី?

<u>ចម្លើយ</u> ប្រភេទការងារនីមួយៗក្នុងគ្រួសារមានសារៈសំខាន់ដោយឡែកៗពីគ្នា ។ ព្រោះថាកិច្ចការងារទាំងនេះធ្វើឱ្យ

គ្រួសារមានសេចក្ដីសុខ រួចផុតពីបន្ទាត់នៃភាពក្រីក្រ ហើយមានការលូតលាស់ជានិរន្តរ៍ ។

3. តើអ្នកគិតថា ប្រភេទការងារនីមួយៗត្រូវតែជាបន្ទុករបស់អ្នកណា ?

<u>ចម្លើយ</u> ខ្ញុំគិតថា ប្រភេទការងារនីមួយៗត្រូវតែជាបន្ទុករបស់សមាជិករាល់គ្នានៅក្នុងគ្រួសារ ។

4. តើនឹងមានផលប៉ះពាល់យ៉ាងណា ប្រសិនបើកូនៗក្នុងគ្រួសារមិនបំពេញការងារប្រភេទណាមួយ ?

<u>ចម្លើយ</u> ប្រសិនបើកូនៗក្នុងគ្រួសារមិនបំពេញការងារប្រភេទណាមួយ នោះវានឹងប៉ះពាល់ដល់គ្រួសារដូចជា៖

- ធ្វើឱ្យគ្រួសារមានភាព យ៉ាប់យ៉ឺន និងហត់នឿយកាន់តែខ្លាំង
- ធ្វើឱ្យអ្នកដទៃមើលងាយថា ជាមនុស្សខ្ជិលច្រអូស
- កិច្ចការនោះនឹងមានភាពរអាក់រអួល និងគ្មានដំណើរការល្អ
- បាត់បង់កម្លាំងពលកម្ម និងថវិកាចំណូលក្នុងគ្រួសារ
- បាត់បង់ទំនួលខុសត្រូវ និងភាពម្ចាស់ការក្នុងគ្រួសារ។

5. “ឪពុកជាអ្នករកប្រាក់មកផ្គត់ផ្គង់គ្រួសារ ឯម្ដាយជាអ្នករ៉ាប់រងគ្រប់ប្រភេទក្នុងគ្រួសារ” តើអ្នកយល់ថា បំណែងចែកការកិច្ចនេះ គ្រប់គ្រាន់សម្រាប់ការរីកចម្រើនរបស់គ្រួសារឬទេ ? ហេតុអ្វី ?

<u>ចម្លើយ</u> “ឪពុកជាអ្នករកប្រាក់មកផ្គត់ផ្គង់គ្រួសារ ឯម្ដាយជាអ្នករ៉ាប់រងគ្រប់ប្រភេទក្នុងគ្រួសារ” ខ្ញុំយល់ថា បំណែងចែកការកិច្ចនេះ មិនគ្រប់គ្រាន់សម្រាប់ការរីកចម្រើនរបស់គ្រួសារទេ ព្រោះថា ការបែងចែករបៀបនេះ មិនយុត្តិធម៌ទេ ហើយវាមិនត្រូវនឹងសមភាពយេនឌ័រឡើយ ។ គឺបុរសនិងស្ត្រីមានតួនាទីស្មើគ្នាក្នុងការធ្វើកិច្ចការងារគ្រប់ប្រភេទ ពួកគេអាចជួយធ្វើការងារគ្នាទៅវិញទៅមក តាមពេលវេលាអាចធ្វើទៅបាន ។

6. តើអ្នកត្រូវប្រកាន់ឥរិយាបថបែបណា ក្នុងការបំពេញការងារក្នុងគ្រួសារ ? ដើម្បីអ្វី ?

<u>ចម្លើយ</u> យើងត្រូវប្រកាន់ឥរិយាបថ ក្នុងការបំពេញការងារក្នុងគ្រួសារ ដូចជា៖

- មានផែនការ និងកាលវិភាគបំពេញការងារផ្ទាល់ខ្លួន
- ប្រកាន់ខ្ជាប់ការគោរពពេលវេលាយ៉ាងទៀងទាត់

- ធ្វើការងារដោយយកចិត្តទុកដាក់ ផ្ចិតផ្ចង់ និងចប់ចុងចប់ដើម
- ប្រកាន់ខ្ជាប់សេចក្តីក្លាហាន អំណត់អត់ធន់ចំពោះការលំបាកនិងបញ្ហាប្រឈមនានា
- ទទួលខុសត្រូវលើការងារចំពោះមុខរបស់ខ្លួន ដោយមិនទម្លាក់លើអ្នកដទៃ
- ស្មោះត្រង់នឹងការងារ គ្មានគំនិតកេងបន្លំយកប្រយោជន៍អ្នកដទៃ ឬប្រយោជន៍រួម មកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន
- ប្រកាន់ខ្ជាប់នូវគំនិតជួយសម្រាលបន្ទុកឪពុកម្តាយឬក្រុមគ្រួសារ
- ជួយថែទាំឬសន្សំសំចៃវត្ថុប្រើប្រាស់នានា.... ។

## សំណួរបញ្ចប់ជំពូក ១

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. កំណើនសេដ្ឋកិច្ចជាតិកម្ពុជាបច្ចុប្បន្នសំខាន់ៗ ពឹងផ្អែកលើៈ

☐ ក. វិស័យកសិកម្ម ☐ ខ. វិស័យឧស្សាហកម្ម

☐ គ. វិស័យអភិវឌ្ឍជនបទ ☐ ឃ. វិស័យអប់រំ ។

២.ការបាត់បង់សមាសភាពរចនាសម្ព័ន្ធគ្រួសារនាំឱ្យបានផលវិបាកចំពោះកុមារៈ

☐ ក. កង្វះអ្នកថែទាំកុមារ

☐ ខ. ការថែទាំកុមារមិនដិតដល់

☐ គ. កុមារបានរៀនសូត្រច្រើន

☐ ឃ. កង្វះធនធានផ្គត់ផ្គង់អ្នកជួយថែទាំ ។

៣. ការរីកចម្រើនក្នុងគ្រួសារកើតមានដោយសារ

☐ ក. សមាជិកគ្រួសាររស់នៅជួបជុំគ្នា

☐ ខ. ឪពុករកចំណូលបានច្រើន

☐ គ. ពលកម្មឬ ការងារគេហកិច្ចរបស់សមាជិកគ្រួសារ ។

៤. ការងារក្នុងគ្រួសារមានលទ្ធផល ឬ មិនល្អដោយសារ

☐ ក. អាកាសធាតុ ☐ ខ. ពេលវេលា

□ គ. ឥរិយាបថរបស់សមាជិកក្នុងគ្រួសារ ។

II. ចូរ បំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

១.ការមាន.......ស្របច្បាប់អាចជួយបង្កើនជីវភាពរបស់ប្រជាជនក្រីក្រ ។

២.ការគ្រប់គ្រងគ្រួសារមានន័យថា .................................។

៣.ពលកម្មនាំឱ្យយើងចៀសផុតពីគ្រោះបីយ៉ាងសំខាន់ៗគឺ.......។

៤.ការងារក្នុងគ្រួសារអាចបែងចែកជា..........ប្រភេទគឺ...........។

III. ចូរឆ្លើយនឹងសំណួរខាងក្រោម

១.តើប្រទេសកម្ពុជាមានប្រភពធនធានអ្វីខ្លះដែលអាចយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានកំណើនទៅមុខ ?

២. តើឱនភាពថវិកាគ្រួសារបណ្តាយមកពីមូលហេតុអ្វីខ្លះ ?

៣. ចូរពន្យល់ពីរបៀបធ្វើផែនការសេដ្ឋកិច្ចគ្រួសារ ?

៤.តើនឹងមានផលប៉ះពាល់បែបណា ប្រសិនបើកូនៗក្នុងគ្រួសារមិនបំពេញការងារប្រភេទណាមួយក្នុងគ្រួសារ ?

IV. ចូរបកស្រាយប្រធានបទខាងក្រោម

នាពេលអនាគត អ្នកនឹងក្លាយជាមេគ្រួសារម្នាក់ឬ មេផ្ទះ។ ដើម្បីគ្រប់គ្រងគ្រួ

សារឱ្យមានការរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ចទាំងផ្នែកសុខុមាលភាព ផ្លូវកាយ និងផ្លូវចិត្ត តើអ្នកគិតថា អ្នកនឹងធ្វើកិច្ចការអ្វីខ្លះ ? ចូរអត្ថាធិប្បាយ ?

<u>ចម្លើយ</u>

I. គូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

១.កំណើនសេដ្ឋកិច្ចជាតិកម្ពុជាបច្ចុប្បន្នសំខាន់ៗ ពឹងផ្អែកលើ:

☑ ក. វិស័យកសិកម្ម

☑ ខ. វិស័យឧស្សាហកម្ម ។

២.ការបាត់បង់សមាសភាពរចនាសម្ព័ន្ធគ្រួសារនាំឱ្យបានផលវិបាកចំពោះកុមារ:

☑ ក. កង្វះអ្នកថែទាំកុមារ

☑ ខ. ការថែទាំកុមារមិនដិតដល់

☑ ឃ. កង្វះធនធានផ្គត់ផ្គង់អ្នកជួយថែទាំ ។

៣. ការរីកចម្រើនក្នុងគ្រួសារកើតមានដោយសារ

☑ គ. ពលកម្មឬ ការងារគេហកិច្ចរបស់សមាជិកគ្រួសារ

៤. ការងារក្នុងគ្រួសារមានលទ្ធផល ឬ មិនល្អដោយសារ

☑ គ. ឥរិយាបថរបស់សមាជិកក្នុងគ្រួសារ ។

II. ចូរ បំពេញឈ្មោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. *មុខរបរ/អាជីវកម្ម* ។

២.*ការដឹកនាំ មើលខុសត្រូវ ការពារថែទាំ និងអប់រំសមាជិកគ្រួសារ*

៣. *ភាពអត់ឃ្លាន ភាពអផ្សុក និងទម្លាប់អាក្រក់* ។

៤. ៩ គឺ ៖

- ការងារគ្រប់គ្រងគ្រួសារ
- ការងារផលិតស្បៀងប្រចាំគ្រួសារ ឬអាជីវកម្មគ្រួសារ
- ការងារគ្រប់គ្រងធនធាន
- ការងារការពារសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងគ្រួសារ
- ការងារផ្ទះបាយ
- ការងារផ្គត់ផ្គង់ទឹក និងថាមពល
- ការងារថែទាំសុខភាព
- ការងារសាងសង់និងជួសជុល
- ការងារលើកកម្ពស់ការរៀនសូត្រ។

III. ឆ្លើយនឹងសំណួរ

១. ប្រទេសកម្ពុជាមានប្រភពធនធាន ដែលអាចយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យបានកំណើនទៅមុខ ដូចជា៖

- អាកាសធាតុ
- ធនធានធម្មជាតិ (រ៉ែប្រេងកាត ត្បូងថ្ម ដែក មាស ព្រៃឈើ...)
- មរតកវប្បធម៌និងសម្បត្តិវប្បធម៌ (ចម្រៀង របាំប្រពៃណី ប្រាសាទ...)
- ធនធានមូលធនហិរញ្ញវត្ថុ (ពន្ធដារ)
- ធនធានមនុស្ស
- សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម
- អភិបាលកិច្ចល្អ

២. ឱនភាពថវិកាគ្រួសារបណ្តាលមកពីមូលហេតុ:

- កង្វះទម្លាប់ម្ចាស់ការក្នុងការដាំដុះនិងចញ្ចឹមសត្វសម្រាប់ផ្គត់ផ្គង់អាហារក្នុងគ្រួសារផ្ទាល់

- ការមិនទាន់មានឆន្ទៈទៅតាំងទីលំនៅនៅក្នុងតំបន់ដីសម្បទានសង្គមកិច្ចដែលមានដីទំនេរអាចប្រកបរបរកសិកម្មបាន
- ការចំណាយច្រើនទៅលើសេវាផ្សេងៗ ដូចជា សេវាដឹកជញ្ជូន ថែទាំសុខភាព ការពារសន្តិសុខ ជាដើម...។
- កង្វះឆន្ទៈក្នុងការថែរក្សាទ្រព្យសម្បត្តិសាធារណៈ។
- បណ្តែតបណ្តោយខ្លួនឬសមាជិកខ្លួនឱ្យធ្លាក់ក្នុងអំពើអបាយមុខផ្សេងៗ
- ការខ្វះគំនិតផ្តួចផ្តើមក្នុងការបង្កើតការងារដោយខ្លួនឯង
- ការពឹងផ្អែកទៅលើរបបកសិកម្មប្រចាំគ្រួសារតែមួយដងក្នុងមួយឆ្នាំ ឬតែដំណាំមួយមុខប៉ុណ្ណោះ
- ការនិយមប្រណីតភាពក្នុងការប្រើប្រាស់ដែលមានតម្លៃខ្ពស់ហួសពីចំណូលខ្លួន ដូចជា ការប្រើប្រាស់ទូរស័ព្ទ ម៉ូតូ រថយន្តទំនើប ៗ... ។

៣. ពន្យល់ពីរបៀបធ្វើផែនការសេដ្ឋកិច្ចក្នុងគ្រួសារៈ មានបួនដំណាក់កាល

✧ ផែនការបង្កើនថវិកាចំណូលៈ

គឺការរៀបចំគម្រោងឬមធ្យោបាយមួយចំនួន ដើម្បីឱ្យមានកំណើននៃប្រាក់ចំណូលក្នុងគ្រួសារមានដូចជា ការច្នៃប្រឌិតបង្កើតមុខរបរអាជីវកម្មគ្រួសារ ការស្វែងរកការងារក្រៅម៉ោងធ្វើបន្ថែមដោយស្របច្បាប់ ការសិក្សាបន្ថែមជំនាញអាជីពជាដើម ។ល។

✧ ផែនការចំណាយៈ គឺជាការរៀបចំបម្រុងថវិកាធនធានឬ ធនធាននិងកំណត់មុខចំណាយក្នុងគ្រួសារឱ្យបានជាក់លាក់ ។

✧ ផែនការសន្សំសំចៃៈ ជាគម្រោងការងារឬសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងការសំចៃដែលធានាដល់និរន្តរភាពនៃការប្រើប្រាស់ ឬចំណាយ ។

✧ ផែនការបង្កើតធនសំចៃឬប្រាក់សំចៃៈ គឺជាគម្រោងការងារឬសកម្មភាពប្រែក្លាយធនសំចៃឬប្រាក់សំចៃឱ្យទៅជាដើមទុនប្រាក់ចំណេញ ។

៨. ប្រសិនបើកូនៗក្នុងគ្រួសារមិនបំពេញការងារប្រភេទណាមួយនោះវានឹងប៉ះពាល់ដល់គ្រួសារដូចជាៈ

- ធ្វើឱ្យគ្រួសារមានភាព យ៉ាប់យ៉ឺន និងហាត់នឿយកាន់តែខ្លាំង
- ធ្វើឱ្យអ្នកដទៃមើលងាយថា ជាមនុស្សខ្ជិលច្រអូស
- កិច្ចការនោះនឹងមានភាពរអាក់រអួល និងគ្មានដំណើរការល្អ
- បាត់បង់កម្លាំងពលកម្ម និងថវិកាចំណូលក្នុងគ្រួសារ
- បាត់បង់ទំនួលខុសត្រូវ និងភាពម្ចាស់ការក្នុងគ្រួសារ...។

## ជំពូកទី២ **អាជីព និងសមត្ថភាពផ្ទាល់ខ្លួន**

### មេរៀនទី១ **ប្រភេទការងារអាជីពសម្រាប់យុវជនកម្ពុជា**

<u>សំណួរចម្លើយ</u>

1. យុវជនដែលរស់នៅក្នុងសហគមន៍របស់អ្នកទោះកំពុងសិក្សា ឬបញ្ចប់ការសិក្សារួចហើយ តើពួកគេប្រកបការងារអ្វីខ្លះ ? ចូរអ្នកនិយាយប្រាប់សិស្សក្នុងថ្នាក់របស់អ្នក ។

<u>ចម្លើយ</u> យុវជនដែលរស់នៅក្នុងសហគមន៍របស់ខ្ញុំទោះកំពុងសិក្សា ឬបញ្ចប់ការសិក្សារួចហើយ ពួកគេប្រកបការងារដូចជា គ្រូពេទ្យ គ្រូបង្រៀន ជាងជួសជុលទូរស័ព្ទ អ្នកនេសាទ អ្នកលក់ដូរ...។

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាមួយសមាជិកក្រុម ដើម្បីឆ្លើយនឹងសំណួរខាងក្រោម ៖

ក. ដូចម្តេចដែលហៅថា ការងារអាជីព ? ចូរឱ្យឧទាហរណ៍

ខ. តាមការគិតរបស់អ្នក តើអ្នកបែងចែកការងារអាជីពជាប៉ុន្មានប្រភេទ ? គឺប្រភេទណាខ្លះ ? ចូរពន្យល់ ។

គ. តើអ្នកអាចមើលឃើញបរិយាកាសការងារអាជីពសម្រាប់យុវជនកម្ពុជា តាមទិដ្ឋភាពណាខ្លះ ? ហើយអ្នកអាចធ្វើសេចក្តីសន្និដ្ឋានបានយ៉ាងណាខ្លះ ?

ឃ. តើយុវជនកម្ពុជាអាចបង្កើតការងារអាជីពដោយខ្លួនឯងបានដែរឬទេ? ប្រសិនបើអាចបង្កើតបាន តើការងារនោះ ជាការងារអ្វី ?

ង. ចូរអ្នករៀបរាប់ការងារអាជីពឱ្យបាន ៥ ដែលអ្នក គិតថាអាចធ្វើឱ្យសេដ្ឋកិច្ចគ្រួសារអ្នកមានការល្អលាស់បាន ។

ចម្លើយ ពិភាក្សាជាមួយដៃគូ ឬជាមួយសមាជិកក្រុម ដើម្បីឆ្លើយនឹងសំណួរខាងក្រោម ៖

ក. ដែលហៅថា *ការងារអាជីព* គឺជា ការងារមុខរបរចិញ្ចឹមជីវិត ហើយមិនប៉ះដល់សេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានគាំទ្រដោយច្បាប់ ។ ឧទាហរណ៍៖ គ្រូពេទ្យ គ្រូបង្រៀន ពាណិជ្ជករ កសិករ អ្នករត់ម៉ូតូឌុប ...។

ខ. តាមការគិតរបស់ខ្ញុំ ខ្ញុំបែងចែកការងារអាជីពជា២ ប្រភេទគឺ៖

- *ការងារកម្លាំងកាយ:*

សំដៅលើការងារដែលប្រើប្រាស់យ៉ាងច្រើននូវកម្លាំងផ្ទាល់ខ្លួនរបស់កម្មករ ឬពលករទៅតាមស្ថានភាពនិងលក្ខខណ្ឌការងារដែលមាន ឬមិនមានជំនួយពីឧបករណ៍គ្រឿងម៉ាស៊ីន ។ មានដូចជាការងារលើកដាក់លីសែង ជីកជញ្ជូន ភ្ជួររាស់ ដកស្ទូង ច្រូតកាត់... ។

- *ការងារកម្លាំងបញ្ញា:*

សំដៅលើការងារទាំងឡាយណាដែលប្រើប្រាស់យ៉ាងច្រើននូវថាមពលខួរក្បាលទៅលើការផលិតស្នាដៃវប្បធម៌ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ការសិក្សាស្រាវជ្រាវផ្នែកសង្គម ការគិត ការច្នៃប្រឌិតបង្កើតស្នាដៃថ្មី គម្រោងថ្មី ឬការផ្តួចផ្តើមគំនិតថ្មីក្នុងការបង្កើតមួយជាដើម ។

គ. យើងអាចមើលឃើញបរិយាកាសការងារអាជីពសម្រាប់យុវជនកម្ពុជា តាមទិដ្ឋភាពដូចជា៖

- ប្រភពនៃចំណូលជាតិ
- ទិដ្ឋភាពកម្លាំងពលកម្មនៅកម្ពុជា

▪ ទិដ្ឋភាពជម្មនុញ្ញនៃសមាគមប្រជាតិអាស៊ីអាគ្នេយ៍ ( យើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថា៖ យុវជនកម្ពុជាមានការងារជាច្រើនដែលត្រូវបំពេញក្នុងពេលបច្ចុប្បន្ន ។

ឃ. យុវជនកម្ពុជាអាចបង្កើតការងារអាជីពដោយខ្លួនឯងបានបាន ។ ការងារនោះ ជាការងារស្របច្បាប់ និងជាការងារថ្លៃប្រឌិតដោយប្រើកម្លាំងកាយ និងបញ្ញា ។

ង. ការងារអាជីព ៥ ដែលខ្ញុំគិតថា អាចធ្វើឱ្យសេដ្ឋកិច្ចគ្រួសារមានការលូតលាស់បាន គឺ ការផ្សញដូរ គ្រូពេទ្យ ជាងកាត់ដេរ អ្នកចិញ្ចឹមសត្វ បើកភោជនីយដ្ឋាន ។

មេរៀនទី២ **តម្លៃនិងអត្ថប្រយោជន៍នៃការងារក្នុងសង្គម**

<u>សំណួរចម្លើយ</u>

1. នៅក្នុងសហគមន៍ដែលអ្នករស់នៅ តើអ្នកសង្កេតឃើញអ្នកស្រុកប្រកបការងារអ្វីខ្លះ ដើម្បីចិញ្ចឹមជីវិត ? ចូររៀបរាប់ប្រាប់សិស្សក្នុងថ្នាក់របស់អ្នក ។

<u>ចម្លើយ</u> នៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ ខ្ញុំសង្កេតឃើញអ្នកស្រុកប្រកបការងារ ដើម្បីចិញ្ចឹមជីវិត ដូចជា ធ្វើស្រែចំការ នេសាទត្រី ចិញ្ចឹមសត្វ (ជ្រូក មាន់ ទា ) ជួញដូរស្រូវអង្ករ គ្រូបង្រៀន ។

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬ សមាជិកក្នុងក្រុម ដើម្បីដោះស្រាយសំណួរដូចខាងក្រោម ៖

ក.ដូចម្តេចដែលហៅថា " ការងារ" ចូរអ្នកពន្យល់ដោយលំអិត ។

ខ. តើ "ការងារ " មានទីតាំងនៅត្រង់ណា នៅក្នុងរចនាសម្ព័ន្ធធនធានសេដ្ឋកិច្ច ? ចូរអ្នកពន្យល់ដោយលំអិត ។

គ. ដូចម្តេចដែលហៅថា " តម្លៃ " ចូរអ្នកពន្យល់ដោយលំអិត ។

ឃ. ដូចម្ដេចដែលហៅថា "តម្លៃការងារ "? តើមនុស្សយើងគួរឱ្យតម្លៃការងារដោយផ្អែកលើអ្វី ?

ង. តាមការយល់របស់អ្នក តើមនុស្សយើងគួរជ្រើសរើសការងារដោយផ្អែកលើអ្វី ? តើសង្គមគួរបន្ដោកបន្ទាបការងារណាមួយដែរ ឬទេ ? ហេតុអ្វី ?

<u>ចម្លើយ</u> ពិភាក្សាជាមួយដៃគូ ឬ សមាជិកក្នុងក្រុម ដើម្បីដោះស្រាយសំណួរដូចខាងក្រោម ៖

ក. ដែលហៅថា " ការងារ" ជាពលកម្មឬសកម្មភាពប្រកបដោយមនសិការនិងវិចារណញ្ញាណរបស់មនុស្សក្នុងគោលបំណងកែប្រែវត្ថុទាំងឡាយក្នុងធម្មជាតិ ឱ្យក្លាយទៅជាផលិតផលផ្ដល់សេវាបំរើបំពេញសេចក្ដីត្រូវការរបស់មនុស្ស ។

ខ. "ការងារ " នៅក្នុងរចនាសម្ព័ន្ធធនធានសេដ្ឋកិច្ចមានទីតាំងនៅត្រង់៖

- ធនធានធម្មជាតិ: គឺទាក់ទងនឹងធម្មជាតិទាំងអស់ដែលមាននៅក្នុងដី និងក្នុងដី ដូចជាអាកាសធាតុ ទឹក ខ្យល់ ភ្លើង ព្រៃ វត្ថុធាតុដើមរ៉ែ...។

- ទំនិញវិនិយោគៈ

  សំដៅលើមធ្យោបាយទាំងឡាយដែលបម្រើឱ្យដំណើរផលិតកម្ម ដើម្បីផលិតទំនិញ ឬសេវាកម្ម ។

- ធនធានមនុស្សៈ

  សំដៅលើមនុស្សដែលមានជំនាញមានបច្ចេកទេសប្រើកម្លាំងកាយ ឬកម្លាំងបញ្ញា ក្នុងសកម្មភាពការងារណាមួយឬក្នុងដំណើរការផលិតកម្មដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់សង្គម ។

គ. ដែលហៅថា " តម្លៃ " ជាអ្វីដែលមាននៅក្នុងមនុស្ស ឬវត្ថុណាមួយ ធ្វើឱ្យមនុស្សឬវត្ថុនោះគួរជាទីរាប់អាន ឬគួរជាទីចង់បាន ។ តម្លៃត្រូវបានបកស្រាយតាមន័យពីរ៖

- វត្ថុវិស័យភាពៈ

  តម្លៃមានអត្ថន័យចំពោះខ្លួនឯងវាផ្ទាល់មិនចំណុះការឱ្យតម្លៃរបស់មនុស្សឡើយ ។

ឃ. ដែលហៅថា "តម្លៃការងារ"គឺជាសំដៅលើលទ្ធផលឬផលត្រឡប់ដែលបានពីការបំពេញការងារណាមួយ ជាប្រយោ

ជូនដល់មនុស្សទាំងអស់គ្នាជាអ្នកធ្វើការងារ ទាំងមនុស្សដទៃទៀតក្នុងសង្គម ។

ង. តាមការយល់របស់ខ្ញុំ មនុស្សយើងគួរជ្រើសរើសការងារដោយផ្អែកលើសមត្ថភាព ចំណេះដឹង ជំនាញ ស្របច្បាប់រដ្ឋ។

## មេរៀនទី៣ **ធនធានសម្រាប់ការចាប់អាជីព**

<u>សំណួរចម្លើយ</u>

1. យុវជនដែលរស់នៅក្នុងសហគមន៍របស់អ្នកទោះ កំពុងសិក្សា ឬបញ្ចប់ការសិក្សារួចហើយ តើពួកគេប្រកបការងារអ្វីខ្លះ ? តើការងារនីមួយៗនោះ ត្រូវការអ្វីជាធនធានដើមទុន ? ចូរអ្នកនិយាយប្រាប់សិស្សក្នុងថ្នាក់របស់អ្នក ។

<u>ចម្លើយ</u> យុវជនដែលរស់នៅក្នុងសហគមន៍របស់ខ្ញុំទោះ កំពុងសិក្សា ឬបញ្ចប់ការសិក្សារួចហើយ ពួកគេប្រកបការងារដូចជាអ្នកនេសាទ កសិករ គ្រូបង្រៀន ទាហាន គ្រូពេទ្យ អ្នកលក់ដូរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬ ជាមួយសមាជិកក្រុម ដើម្បីឆ្លើយនឹងសំណួរខាងក្រោម ៖

ក. ដូចម្តេចដែលហៅថា "ការងារអាជីព " ? ចូរផ្តល់ឧទាហរណ៍ឱ្យបាន ៥ ។

ខ. ដូចម្តេចដែលហៅថា " ធនធានដើមទុន " ចូរផ្តល់ឧទាហរណ៍ឱ្យបាន ៥។

គ. តាមការអប់រំរបស់បុរាណចារ្យខ្មែរ មនុស្សត្រូវមានសម្បត្តិ ៨ ប្រការ ។ តើសម្បត្តិនោះ មានអ្វីខ្លះ ? ហើយអាចយកទៅធ្វើជាធនធានដើម្បីទុកសម្រាប់ការងារអាជីពឬទេ ? ចូរពន្យល់ ។

ឃ. ដូចម្តេចដែលហៅថា "ការងារពលកម្ម ឬសេវាកម្មស៊ីឈ្នួល" ? ចូរផ្តល់ឧទាហរណ៍ឱ្យបាន ៥ ។ តើការងារនេះត្រូវការធនធានអ្វីខ្លះ ?

ង. ដូចម្តេចដែលហៅថា " សហគ្រាសធុនតូច " ? ចូរផ្តល់ឧទាហរណ៍ឱ្យបាន ៥ ។ តើសហគ្រាសនេះ ត្រូវការធនធានអ្វីខ្លះ ?

ច. តើសហគ្រាសធុនតូចមានគោលដៅអ្វីខ្លះ ? ចូរពន្យល់អត្ថន័យនៃគោលដៅនីមួយៗ ។

ឆ. តើអ្នកធ្វើការងារអាជីពត្រូវប្រកាន់ខ្ជាប់នូវគុណធម៌អ្វីខ្លះ ? ហេតុអ្វី ?

ចម្លើយ ពិភាក្សាជាមួយដៃគូ ឬ ជាមួយសមាជិកក្រុម ដើម្បីឆ្លើយនឹងសំណួរខាងក្រោម ៖

ក. ដែលហៅថា "ការងារអាជីព " គឺសំដៅលើការធ្វើពលកម្មទាំងកម្លាំងកាយ និងបញ្ញាតាមកម្រិតជំនាញវិជ្ជាជីវៈ ។ ឧទាហរណ៍៖ គ្រូពេទ្យ គ្រូបង្រៀន ពាណិជ្ជករ កសិករ ជាងកាត់ដេរ ។

ខ. ដែលហៅថា " ធនធានដើមទុន " ជាសម្បត្តិដែលត្រូវយកទៅប្រើប្រាស់ក្នុងការងារអាជីពដើម្បីទទួលបានមកវិញនូវប្រាក់ឈ្នួល ឬប្រាក់ចំណេញ ។

គ. តាមការអប់រំរបស់បុរាណចាប់ខ្មែរ មនុស្សត្រូវមានសម្បត្តិ ៤ ប្រការ ។ សម្បត្តិនោះ មាន ៖

- រូបសម្បត្តិឬកាយសម្បទា
- ចរិយាសម្បត្តិ
- វិជ្ជាសម្បត្តិ ឬបញ្ញាសម្បទា
- ទ្រព្យសម្បត្តិ...។

ឃ. ដែលហៅថា "ការងារពលកម្ម ឬសេវាកម្មស៊ីឈ្នួល" គឺជាការងារពលកម្មដែលប្តូរយកប្រាក់បៀវត្សឬយកប្រាក់ឈ្នួល

មកបំពេញតម្រូវការរបស់ខ្លួន ។ ឧទាហរណ៍៖ អ្នករត់ម៉ូតូឌុប កម្មករសំណង់ ការជីកដី ការលីសែង សុខាភិបាល ។

ង. ដែលហៅថា “ សហគ្រាសធុនតូច ” គឺជាមុខរបរជំនួញ ឬអាជីវកម្មដែលនឹងមាននិយមន័យកំណត់ទៅតាមបទដ្ឋានមួយចំនួនដូចជា ចំនួនបុគ្គលិក(តិចជាង ១០នាក់ ) ទំហំអាជីវកម្ម (មិនមែនជាសហគ្រាសធុនធំ) ទ្រព្យសម្បត្តិការធានារ៉ាប់រងចំណាយ និងប្រាក់ផ្ញើនៅធនាគារ ។

ច. សហគ្រាសធុនតូចមានគោលដៅដូចជា ៖

- គោលដៅប្រាក់ចំណេញៈ

  ដើម្បីបំពេញឡើងវិញនូវការតម្លើងថ្លៃពលកម្មទៅឱ្យបុគ្គលិក ថ្លៃពលកម្មផ្ទាល់របស់សហគ្រិន និងដោះស្រាយបណ្ដាហានិភ័យដែលគេអាចជួបប្រទះ ។

- គោលដៅផ្ដល់ទំនិញឬសេវាកម្មៈ

  ដើម្បីបំពេញតម្រូវការរបស់អតិថិជន ទើបអាចទទួលបានចំណេញ ។ គោលដៅផ្ដល់ទំនិញឬសេវាកម្មជាកាតព្វកិច្ចរបស់សហគ្រាសចំពោះសង្គម ។ គោលដៅ

នេះបានផ្លាស់ប្តូរអាស្រ័យលើចំណង់ចំណូលចិត្ត របស់អតិថិជន និងស្ថានភាពប្រកួតប្រជែង ។

▪ គោលដៅអភិវឌ្ឍន៍:

ការអភិវឌ្ឍមានន័យថា ការទិញថែមទៀតនូវគ្រឿងម៉ាស៊ីន កសាងបន្ថែមរោងផលិតកម្ម ឬទិញយកសហគ្រាសផ្សេងៗ ដើម្បីពង្រីកសកម្មភាពផលិតកម្មរបស់ខ្លួន ។

ឆ. យើងធ្វើការងារអាជីពត្រូវប្រកាន់ខ្ជាប់នូវគុណធម៌ដូចជាស្មោះត្រង់ ប្រកាន់ភាពសុចរិតទាំងក្នុងការងារតូចតាច ឬធំរក្សាកេរ្តិ៍ឈ្មោះ ចៀសវាងការប្រកួតប្រជែងឥតប្រយោជន៍ និងប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវចំពោះសង្គម ព្រោះការធ្វើរបៀបនេះ ធ្វើឱ្យការងារក្នុងសហគ្រាសមានសណ្តាប់ល្អ មានកិត្តិយសថ្លៃថ្នូរ មានអតិថិជនជឿទុកចិត្តច្រើន ។

មេរៀនទី៨ **ការស្វែងរកការងារ**

## សំណួរចម្លើយ

1. ចូរអ្នករកនិងអានព័ត៌មានមួយដែលមានផ្សាយដំណឹងជ្រើសរើសបុគ្គលិក ហើយចូរប្រាប់ព័ត៌មាននោះ ដល់សិស្សក្នុងថ្នាក់ ។

ចម្លើយ ចូរអ្នករកនិងអានព័ត៌មានមួយដែលមានផ្សាយដំណឹងជ្រើសរើសបុគ្គលិក ហើយចូរប្រាប់ព័ត៌មាននោះដល់សិស្សក្នុងថ្នាក់ ។

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយសំណួរដូចខាងក្រោម ៖

ក. តាមការគិតរបស់អ្នក តើការស្វែងរកការងារមានអត្ថន័យដូចម្ដេច ? តើមនុស្សគ្រប់រូបចាប់ផ្ដើមគិតគូរ អំពីការងាររបស់ខ្លួនពីអាយុប៉ុន្មាន ? ហេតុអ្វី ?

ខ.មុននឹងស្វែងរកការងារតើមនុស្សមានអ្វីជាទុនរបស់ខ្លួន ?

គ. តើគេអាចស្វែងរកការងារនៅទីណាខ្លះ ?

ឃ. ការងារផ្សេងគ្នា មានតម្រូវការផ្នែកបច្ចេកទេសផ្សេងគ្នា ។ បើមនុស្សមានសម្បទាផ្សេងៗគ្នា តើពួកគេអាចជ្រើសរើសការងារដូចគ្នាឬទេ ? ហេតុអ្វី ?

ង. ប្រសិនបើអ្នកជានិយោជននៃក្រុមហ៊ុនមួយ តើមនុស្សប្រភេទណាខ្លះ ដែលជ្រើសរើសមកធ្វើការក្នុងក្រុមហ៊ុនរបស់អ្នក ?

ច. ប្រសិនបើអ្នកជានិយោជិក តើអ្នកត្រូវការជ្រើសរើសលក្ខខណ្ឌការងារសមស្របនឹងសម្បទារបស់អ្នកដែរឬទេ ? ហេតុអ្វី ?

ឆ. តើមនុស្សអាចបង្កើតការងារឬមុខរបរដោយខ្លួនឯងបានដែរឬទេ ? ចូរពន្យល់ ។

<u>ចម្លើយ</u> ពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយសំណួរដូចខាងក្រោម ៖

ក. តាមការគិតរបស់ខ្ញុំ ការស្វែងរកការងារមានអត្ថន័យថា ការស៊ើបសួររកព័ត៌មានស្តីពីការជ្រើសរើសបុគ្គលិកនៅតាមស្ថានប័នអង្គភាព ក្រុមហ៊ុនសហគ្រាស ឬគ្រឹះស្ថានរដ្ឋឬឯក

ជនណាមួយនិងធ្វើទំនាក់ទំនងឬធ្វើលក្ខខណ្ឌផ្សេងៗ ដើម្បីទទួលបានការជ្រើសរើសជាបុគ្គលិកបំពេញការងារនៅទីនោះ (ឆ្លើយតាមគិតរបស់មនុស្សម្នាក់ ឧទាហរណ៍ៈ មនុស្សចាប់ផ្តើមគិតគូរពីការងាររបស់ខ្លួនចាប់ពីអាយុ១៨ឆ្នាំ ព្រោះជាពេលវេលាដែលពួកគេចេះគិតបានច្រើន និងរៀនចប់បាក់ឌុប...)។

ខ.មុននឹងស្វែងរកការងារ មនុស្សមានសមត្ថភាព ឥរិយាបទ និងក្រមសីលធម៌ ជាទុនរបស់ខ្លួន ។

គ. គេអាចស្វែងរកការងារនៅតាម សារព័ត៌មាន វិទ្យុ សេចក្តីផ្សាយដំណឹង នៅគ្រឹះស្ថានសាធារណៈ ឯកជន ឬប្រាប់តគ្នា ឬការផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត ។

ឃ. ការងារផ្សេងគ្នា មានតម្រូវការផ្នែកបច្ចេកទេសផ្សេងគ្នា ។ បើមនុស្សមានសម្បទាផ្សេងៗគ្នា ពួកគេក៏អាចជ្រើសរើសការងារដូចគ្នាបាន ព្រោះមនុស្សទាំងអស់មានសិទ្ធិក្នុងការជ្រើសរើសកិច្ចការងារទាំងឡាយដែលខ្លួនពេញចិត្ត និងគ្មានការរើសអើង ។

ង. ប្រសិនបើខ្ញុំជានិយោជិតនៃក្រុមហ៊ុនមួយ មនុស្សប្រភេទដែលជ្រើសរើសមកធ្វើការក្នុងក្រុមហ៊ុនគឺជាមនុស្សដែលមានសមត្ថភាព (ចំណេះជំនាញ បទពិសោធ ការទំនាក់ទំនងល្អ ...)មានឥរិយាបទសមរម្យ មានក្រមសីលធម៌ក្នុងខ្លួន ។

ច. ប្រសិនបើខ្ញុំជានិយោជិក ខ្ញុំមិនត្រូវការជ្រើសរើសលក្ខខណ្ឌការងារសមស្របនឹងសម្បទារបស់ខ្ញុំទេ ព្រោះខ្ញុំគិតថាកាយសម្បទាមិនសូវសំខាន់ ហើយមិនត្រូវរើសអើងចំពោះមនុស្សណាមួយឡើយ ឱ្យតែមនុស្សនោះមានសមត្ថភាព បញ្ញា ឥរិយាបទ និងមានក្រមសីលធម៌ ។

ឆ. មនុស្សអាចបង្កើតការងារឬមុខរបរដោយខ្លួនឯងបាន ។ កាលណាមនុស្សមានជំនាញ មានសមត្ថភាព ធនធានគ្រប់គ្រាន់ពួកគេមានសិទ្ធិ និងមានលទ្ធភាពក្នុងការប្រើប្រាស់ ការបង្កើតការងារឬមុខរបរដោយខ្លួនបាន ឱ្យតែពួកគេមានឆន្ទៈ និងការប្តេជ្ញាចិត្តក្នុង ការធ្វើការងារនោះឱ្យបានល្អ ។

## សំណួរបញ្ចប់ជំពូក ២

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. នៅក្នុងសេដ្ឋកិច្ចទីផ្សា គេបែងចែកការងារជាពីរប្រភេទគឺ ៖

☐ ក. ការងារកម្លាំងកាយ

☐ ខ. ការងារពលកម្ម

☐ គ. ការងារកម្លាំងបញ្ញា

☐ ឃ. ការងារសហគ្រិន ។

២. ក្នុងបរិបទសេដ្ឋកិច្ចធនធាន មនុស្សត្រូវការបែង ចែកតាមន័យពីរគឺ

☐ ក. មនុស្សចាស់

☐ ខ. ពលកម្ម

☐ គ. មនុស្សច្រើន

☐ ឃ. ទេព្យកោសល្យសហគ្រិនភាព ។

៣. គេអាចវាយតម្លៃមនុស្ស វត្ថុ ឬធម្មជាតិ តាម ទស្សនវិស័យពីរបែបគឺ

☐ ក. វត្ថុវិស័យភាព ☐ ខ. ការរិះគន់

☐ គ. ប្រធានវិស័យភាព ☐ ឃ. លំអៀង ។

៤. ភាពគ្មានការងារធ្វើ បណ្តាលឱ្យមានបញ្ហាក្នុង សង្គម ដូចជា

☐ ក. ដីទំនេរចោល

☐ ខ. មនុស្សដើរលេង

☐ គ. គ្មានផលិតកម្ម

☐ ឃ. គ្មានសេវាកម្ម ។

II. ចូរ បំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

១.ពលកម្មស្មុគស្មាញតែងផ្តល់នូវ............ច្រើនជាងឬមាន........ ....ប្រសើរជាងពលកម្មសាមញ្ញ ។

២.លក្ខណៈពិសេសនៃការងារសហគ្រិនគឺការ.................. ...។

៣. កត្តានៃធនធានសេដ្ឋកិច្ចឬហៅថា ....................មានចំនួន ៣ គឺធនធានធម្មជាតិ .............និងធនធានមនុស្ស ។

៤.តម្លៃគឺ ................ធ្វើឱ្យមនុស្ស ឬវត្ថុនោះ មានភាពគួរជាទីរាប់អាន ឬគួរជាទីប្រាថ្នាចង់បាន ។

III. ចូរឆ្លើយនឹងសំណួរខាងក្រោម

១. ដូចម្តេចដែលហៅថា “ការងារ ” ?

២. ដើម្បីឱ្យការងារមានលទ្ធផលល្អ តើអ្នកធ្វើការងារត្រូវការលក្ខណសម្បត្តិអ្វីខ្លះ ?

៣.គោលបំណងទី ៥ ដែលមានចែងក្នុងធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មានចែងដូចម្ដេចខ្លះ ?

៤. តើលក្ខណៈពិសេសរបស់សហគ្រិនមានអ្វីខ្លះ ?

IV. ចូរបកស្រាយប្រធានបទដូចខាងក្រោម ៖

ដើម្បីបង្កើតសហគ្រិនធុនតូចមួយ តើសហគ្រិនត្រូវមានការយល់ដឹងអំពីអ្វីខ្លះ ? ចូរអ្នករៀបរាប់ ។

# ចម្លើយ

I. គូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

១. នៅក្នុងសេដ្ឋកិច្ចទីផ្សា គេបែងចែកការងារជាពីរប្រភេទ គឺ ៖

☑ ក. ការងារកម្លាំងកាយ

☑ គ. ការងារកម្លាំងបញ្ញា

២.ក្នុងបរិបទសេដ្ឋកិច្ចធនធានមនុស្សត្រូវការបែងចែកតាមន័យពីរគឺ

☑ ខ. ពលកម្ម

☑ ឃ. ទេព្យកោសល្យសហគ្រិនភាព ។

៣. គេអាចវាយតម្លៃមនុស្ស វត្ថុឬធម្មជាតិតាមទស្សនវិស័យពីរបែបគឺ

☑ ក. វត្ថុវិស័យភាព

☑ គ. ប្រធានវិស័យភាព

៤. ភាពគ្មានការងារធ្វើ បណ្តាយឱ្យមានបញ្ហាក្នុងសង្គមដូចជា

☑ ក. ដីទំនេរចោល

☑ គ. គ្មានផលិតកម្ម

☑ ឃ. គ្មានសេវាកម្ម ។

II. ចូរ បំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

១. *ទិន្នផល* ច្រើនជាង ឬមាន *លទ្ធភាព/គុណភាព* ។

២. *ផ្ដើមគំនិតក្នុងអាជីវកម្ម*។

៣. *កត្តាផលិតកម្ម... ទំនិញវិនិយោគ* ។

៤. *ជាអ្វីដែលមាននៅក្នុងមនុស្ស ឬវត្ថុណាមួយ* ។

III. ឆ្លើយនឹងសំណួរ

១. ដូចម្ដេចដែលហៅថា "ការងារ " គឺជាពលកម្មឬ សកម្មភាពប្រកបដោយមនសិការនិងវិចារណញ្ញាណរបស់មនុស្សក្នុងគោលបំណងកែប្រែវត្ថុទាំងឡាយក្នុងធម្មជាតិ ឱ្យក្លាយជាផលិតផលផ្ដល់សេវាសំដៅបំពេញសេចក្ដីត្រូវការរបស់មនុស្ស។

២. ដើម្បីឱ្យការងារមានលទ្ធផលល្អ អ្នកធ្វើការងារត្រូវការលក្ខណសម្បត្តិដូចជា ៖

- មានសុខភាពល្អ ទាំងកាយទាំងចិត្ត
- មានជំនាញបច្ចេសច្បាស់លាស់
- មានសីលធម៌វិជ្ជាជីវៈ

▪ មានបំណិនក្នុងការប្រាស្រ័យទាក់ទង និងដោះស្រាយទំនាស់ក្នុងការងារ ។

▪ មានការច្នៃប្រឌិតខ្ពស់ គម្រោងថ្មី ឬការផ្តួចផ្តើមគំនិតថ្មីក្នុងការបង្កើតអ្វីមួយ

▪ និងមានការសិក្សាជ្រៅជ្រះ ...។

៣.គោលបំណងទី ៥ដែលមានចែងក្នុងធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍មានចែងថា ៖

បង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្ម តែមួយដែលមានស្ថិរភាព មានការរីកចម្រើនមានការប្រកួតប្រជែងខ្ពស់ និងមានការបញ្ចូលគ្នាផ្នែកសេដ្ឋកិច្ច និងការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាពបម្រើអោយការធ្វើពាណិជ្ជកម្ម និងការវិនិយោគទុន ។

៤. លក្ខណៈពិសេសរបស់សហគ្រិនមាន៖

▪ ផ្តើមគំនិតក្នុងអាជីវកម្ម

▪ មានគោលដៅជាក់ដើម្បីរកផលប្រយោជន៍

▪ ជាអ្នកច្នៃប្រឌិត

▪ ជាអ្នកហ៊ានប្រថុយប្រថាន

ហ៊ានទទួលយកនូវរាល់គ្រោះថ្នាក់ជាយថាហេតុក្នុង ផលិតកម្ម ...។

## ជំពូកទី៣ **អាជីវកម្មគ្រួសារ**

### មេរៀនទី១ **ប្រភេទអាជីវកម្ម**

**សំណួរចម្លើយ**

1. នៅក្នុងសហគមន៍ដែលអ្នករស់នៅ តើអ្នកសង្កេត ឃើញ មាន ការប្រកបអាជីវកម្មណាមួយដែល មានការចូល ហ៊ុន គ្នាដែរឬទេ ? ប្រសិនបើមាន ចូរអ្នករៀបរាប់ប្រាប់សិស្ស ក្នុង ថ្នាក់របស់អ្នក ។

ចម្លើយ ការ *ឆ្លើយតាមការឃើញមានរបស់សហគមន៍សិស្សម្នាក់ៗ*

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាមួយសមាជិកក្រុម ដើម្បី ដោះស្រាយសំណួរដូចខាងក្រោម ៖

ក. ដូចម្តេចដែលហៅថា "អាជីវកម្ម" ? តើគេអាចបែងចែក អាជីវកម្មជាប៉ុន្មានប្រភេទ ? គឺអ្វីខ្លះ ?

ខ. ដូចម្ដេចដែលហៅថា អាជីវកម្មឯកកម្មសិទ្ធ ? ចូរផ្ដល់ឧទាហរណ៍និងអធិប្បាយពីភាពងាយស្រួលនិងលំបាកក្នុងការបង្កើត និងការប្រកបអាជីវកម្មប្រភេទនេះ ។

គ. ដូចម្ដេចដែលហៅថាអាជីវកម្មហ៊ុនគ្នា ? ចូរផ្ដល់ឧទាហរណ៍និងអធិប្បាយពីភាពងាយស្រួល និងលំបាកក្នុងការបង្កើត និងការប្រកបអាជីវកម្មប្រភេទនេះ ។

ឃ. ដូចម្ដេចដែលហៅថា ក្រុមហ៊ុន ? ចូរផ្ដល់ឧទាហរណ៍និងអធិប្បាយពីភាពងាយស្រួល និងលំបាកក្នុងការបង្កើត និងការប្រកបអាជីវកម្មប្រភេទនេះ ។

<u>ចម្លើយ</u> ពិភាក្សាជាមួយដៃគូ ឬជាមួយសមាជិកក្រុម ដើម្បីដោះស្រាយសំណួរដូចខាងក្រោម ៖

ក. ដូចម្ដេចដែលហៅថា "អាជីវកម្ម" គឺជាសកម្មភាពនៃផលិតកម្មជំនួញឬសេវាកម្មផ្សេងៗ ដើម្បីទទួលបានប្រាក់ចំណេញ។ គេអាចបែងចែកអាជីវកម្មជា ៣ ប្រភេទ គឺ៖

- អាជីវកម្មឯកសិទ្ធិ
- អាជីវកម្មហ៊ុនគ្នា ធុនមធ្យម
- ក្រុមហ៊ុន។

ខ. ដែលហៅថា អាជីវកម្មឯកកម្មសិទ្ធ គឺជាប្រភេទអាជីវកម្មដែលងាយបង្កើតជាងគេ ព្រោះវាមិនទាមទារការបំពេញបែបបទសាំញ៉ាំ គឺគ្រាន់តែបំពេញអាជ្ញាប័ណ្ណតាមគោលការណ៍របស់សមត្ថកិច្ចសេដ្ឋកិច្ច មូលដ្ឋានប៉ុណ្ណោះ ។ ឧទាហរណ៍៖ អាជីវកម្មចិញ្ចឹមជ្រូកលក់ ។ អាជីវកម្មប្រភេទនេះមានភាពងាយស្រួលនិងការលំបាកដូចជា៖

*ងាយស្រួល*

- ងាយបង្កើត និងទទួលបានប្រាក់ចំណេញច្រើនព្រោះសាច់ជ្រូកឡើងថ្លៃ
- យើងអាចថែទាំផ្តល់ចំណីដោយខ្លួនឯង។
- មិនចាំបាច់ចាត់ចែងប្រាក់ចំណេញ ម្ចាស់កម្មសិទ្ធិរីករាយនឹងទទួលបានប្រាក់តិចឬច្រើនដោយមិនចាំបាច់គិតគូរពីការបែងចែកលុយកាក់ ។
- គ្មានអ្នកណាបង្ខិតបង្ខំ គឺធ្វើឡើងដោយម្ចាស់ការលើខ្លួនឯង និងមានភាពទទួលខុសត្រូវ ។

- មិនចាំបាច់បំពេញលក្ខខណ្ឌស្មុគស្មាញ ឬទាមទារការទទួលស្គាល់ពីអជ្ញាធរសមត្ថកិច្ចឡើយ ។

*ការលំបាក*

- ត្រូវចំណាយទុនម្នាក់ឯង
- រ៉ាប់រងនូវការខូចខាត បាត់បង់ដោយជាយថាហេតុ ឬនឿយហត់ក្នុងការថែទាំ ព្រោះពេលវាអាចខ្លះឈឺ
- ខ្វះជំនាញនិងបទពិសោធ ក្នុងការចិញ្ចឹម ។ ពេលវាឈឺត្រូវប្រើថ្នាំអ្វី ត្រូវធ្វើយ៉ាងណាទើបល្អ ។

គ. ដែលហៅថា អាជីវកម្មហ៊ុនគ្នា ជាអាជីវកម្មដែលមានដំណើរការដាក់ហ៊ុនចូលគ្នា ចាប់ពីពីរហ៊ុនឡើងទៅ ។ ឧទាហរណ៍៖ អាជីវកម្មហ៊ុនគ្នាកិនស្រូវ ។ ភាពងាយស្រួល និងលំបាកក្នុងការបង្កើត និងការប្រកបអាជីវកម្មប្រភេទនេះ ។

*ងាយស្រួល*

- ដៃគូម្នាក់ៗមានបទពិសោធន៍ផ្សេងៗគ្នា ។ ពួកគេអាចទទួលខុសត្រូវតាមឯកទេសរៀងៗខ្លួន ។
- មិនចាំបាច់បង់ពន្ធលើប្រាក់ចំណូលជាបុគ្គលដូចអាជីវកម្មឯកសិទ្ធិទេ ។

- អាចមានប្រាក់ទុនច្រើនជាងការរកស៊ីបែបឯកកម្មសិទ្ធិ ព្រោះពួកគេមានប្រភពផ្សេងគ្នា បានប្រមូលផ្តុំទុកដាក់រួមគ្នា ។
- ងាយស្រួលក្នុងការបម្រើការទីផ្សារ ព្រោះមានលទ្ធភាពកែច្នៃគុណភាពផលិតផលតាមសេចក្តីត្រូវការ ។

*ការលំបាក*

- ភាគីចូលហ៊ុននីមួយៗត្រូវទទួលខុសត្រូវរាល់សកម្មភាពរបស់ដៃគូខ្លួន ប្រសិនបើដៃគូណាម្នាក់បង្កបញ្ហាឱ្យក្រុមហ៊ុនបង់ខាត ដៃគូឯទៀតក៏ត្រូវទទួលការខាតបង់ដែរ ។
- ទំនាស់អាចកើតមានឡើង ប្រសិនបើគេមិនចុះសម្រុងគ្នាដោយប្រការណាមួយ ។

ឃ. ដែលហៅថា ក្រុមហ៊ុន ជាអង្គភាពអាជីវកម្មស្របច្បាប់ និងមានការទទួលស្គាល់ពីរដ្ឋាភិបាល ។ ឧទាហរណ៍៖ ក្រុមហ៊ុន ផលិតកៅស៊ូ ។ ភាពងាយស្រួល និងលំបាកក្នុងការបង្កើត និងការប្រកបអាជីវកម្មប្រភេទនេះ ។

*ងាយស្រួល*

- ក្នុងការប្រមូលទុន ។ ប្រសិនបើក្រុមហ៊ុនត្រូវការទុនបន្ថែមគេអាចលក់ភាគហ៊ុនទៅឱ្យអ្នកវិនិយោគទុន ដើម្បីយកប្រាក់នោះទៅប្រើប្រាស់ក្នុងការដោះស្រាយ ឬពង្រីកក្រុមហ៊ុនរបស់គេ ។
- អ្នកគ្រប់គ្រងអាចរកបានអ្នកជំនាញនិងបទពិសោធន៍ឱ្យមកធ្វើការក្នុងក្រុមហ៊ុន ស្រមតាមច្បាប់ការងារ ។
- ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវរាល់បំណុលនិងដំណើរការក្រុមហ៊ុន គឺមិនមែនម្ចាស់ការភាគហ៊ុនម្នាក់ៗជាអ្នកទទួលខុសត្រូវទេ ។
- ក្រុមហ៊ុននៅតែមានដំណើរការទោះបីជាមានការផ្លាស់ប្តូរអ្នកចូលភាគហ៊ុនក៏ដោយ ។

*ការលំបាក*

- លំបាកក្នុងការបង្កើតលក្ខន្តិកៈ និងសំណុំបែបបទតាមផ្លូវច្បាប់
- សមាជិកភាគហ៊ុនម្នាក់ៗមិនមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តលើការងារក្រុមហ៊ុនតែម្នាក់ឯងបាន ។

## មេរៀនទី២ **អាជីវកម្មធុនតូចឬសហគ្រាសគ្រួសារ**

### <u>សំណួរចម្លើយ</u>

1. តាមការសង្កេតរបស់អ្នក តើគ្រួសារនីមួយៗក្នុងសហគមន៍ដែលអ្នករស់នៅប្រកបមុខរបរអ្វីខ្លះ ? តើមុខរបរនីមួយៗនោះមានបង្កើតជាផលិតផលណាមួយសម្រាប់ប្រើប្រាស់ឬសម្រាប់លក់ដូរដែរឬទេ ?

<u>ចម្លើយ</u> (ឆ្លើយតាមការយល់ឃើញរបស់អ្នក)។

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬ ក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម៖

ក.តើពីមុនអ្នកធ្លាប់ឮពាក្យ "អាជីវកម្មធុនតូច" និង "សហគ្រាសគ្រួសារ" ដែរឬទេ ?

ខ. តើអ្នកគិតថា អាជីវកម្មធុនតូចមានន័យដូចម្តេច ? ចូររាប់ឈ្មោះអាជីវកម្មធុនតូចដែលអ្នកបានស្គាល់ ។

គ. តើអាជីវកម្មធុនតូច មានសារប្រយោជន៍ដូចម្តេចខ្លះ ?

ឃ. តើគេអាចបង្កើតអាជីវកម្មធុនតូចជាប៉ុន្មានប្រភេទ ? គឺអ្វីខ្លះ ?

ង. តើអាជីវកម្មប្រភេទណា ដែលច្បាប់ហាមឃាត់ ?

ហេតុអ្វី ?

ច. តើគេអាចបង្កើតអាជីវកម្មធុនតូចតាមវិធីណា ?

ឆ. តើគេអាចពង្រីកអាជីវកម្មធុនតូចតាមវិធីណា ?

ជ.ដើម្បីធ្វើអាជីវកម្មផលិតកម្មតើគេត្រូវរៀបចំទុនដូចម្ដេច ?

ឈ. តើមានអ្វីខ្លះជាប្រភពជោគជ័យនៃអាជីវកម្មធុនតូច ?

ញ.តើមានកត្តាអ្វីដែលធានាជោគជ័យយូរអង្វែងនៃអាជីវកម្ម ?

<u>ចម្លើយ</u> ពិភាក្សាជាមួយដៃគូ ឬ ក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម៖

ក. ពីមុនខ្ញុំធ្លាប់ឮ ពាក្យ "អាជីវកម្មធុនតូច" និង "សហគ្រាសគ្រួសារ" ។

ខ. ខ្ញុំគិតថា អាជីវកម្មធុនតូចមានន័យថា អាជីវកម្មដែលមានបុគ្គលិកតិចជាង ១០ នាក់ មានទ្រព្យសម្បត្តិមួយចំនួន មានការធានារ៉ាប់រងចំណាយនិងប្រាក់ផ្ញើនៅធនាគារ។

គ. អាជីវកម្មធុនតូច មានសារប្រយោជន៍ដូចជា៖

- បង្កើនប្រាក់ចំណូលគ្រួសារ
- បង្កើតការងារសម្រាប់មនុស្ស

▪ បង្កើតផលិតផលមួយសម្រាប់សេចក្តីត្រូវការក្នុងគ្រួសារ និងទីផ្សារ ។

ឃ. គេអាចបង្កើតអាជីវកម្មធុនតូចជា ៤ប្រភេទ គឺ៖

▪ អាជីវកម្មផលិតកម្ម

▪ អាជីវកម្មលក់ដូរឬផ្គូរផ្គង

▪ អាជីវកម្មសេវាកម្ម

▪ អាជីវកម្មជាក់ហ៊ុន។

ង. អាជីវកម្ម ដែលច្បាប់ហាមឃាត់ គឺការបរបាញ់ចាប់សត្វព្រៃយកទៅលក់ ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ការជួញដូរអាវុធជាតិផ្ទុះ លក់គ្រឿងញៀន អាជីវកម្មជួញដូរមនុស្ស ។

ច. គេអាចបង្កើតអាជីវកម្មធុនតូចតាមវិធីការប្រើប្រាស់ដើមទុនដែលបានសន្សំទុកពីតិចទៅច្រើន ។

ឆ.គេអាចពង្រីកអាជីវកម្មធុនតូចតាមការប្រើប្រាស់ប្រាក់ចំណេញដែលមានការកើនឡើង ។

ជ. ដើម្បីធ្វើអាជីវកម្មផលិតកម្ម គេត្រូវរៀបចំទុនដោយបែងចែកទៅតាមប្រភេទ ដូចជា ទុនអចល័ត ទុនចល័ត និង ប្រាក់បម្រុង ជាដើម ។

ឈ. ប្រភពជោគជ័យនៃអាជីវកម្មធុនតូច មាន៖

- អាជីវកម្មមានទុនថវិកា ចំណេះដឹង បទពិសោធន៍ វិជ្ជាជីវៈច្បាស់លាស់ និងមានកម្លាំងពលកម្មគ្រប់គ្រាន់
- មានទីផ្សារសម្រាប់ លក់ផលិតផលឬសេវាកម្ម
- ផលិតផលឬសេវាកម្មមានគុណភាពសមស្របតាមសេចក្ដីត្រូវការ និង ការពេញចិត្តរបស់អតិថិជន
- អាជីវករមានបំណិនក្នុងការគ្រប់គ្រងអាជីវកម្មធ្វើឱ្យដំណើរការអាជីវកម្មទទួលបានប្រាក់ចំណេញជាប្រក្រតី
- អាជីវករមានអត្តចរិតស្មោះត្រង់រួសរាយរាក់ទាក់សមនឹងទទួលបានការគាំទ្រ ពីអតិថិជន
- អាជីវកម្មស្ថិតក្នុងបរិស្ថាន សង្គមដែលមានសន្តិសុខនិងសុវត្ថិភាព...។

៣. កត្តា ដែលធានាជោគជ័យយូរអង្វែងនៃអាជីវកម្មគឺ៖

- គោរពច្បាប់
- ការកសាង និងរក្សាកេរ្តិ៍ឈ្មោះល្អ
- រក្សាភាពស្មោះត្រង់
- សុចរិត ត្រឹមត្រូវ... ។

មេរៀនទី៣

## ធនធានសេដ្ឋកិច្ចគ្រួសារ និងការរកប្រាក់ចំណូល

<u>សំណួរចម្លើយ</u>

1. ចូរអ្នករៀបរាប់ពីដំណើរអាជីវកម្មមួយដែលមាននៅក្នុងសហគមន៍របស់អ្នក និងបញ្ជាក់ថា អាជីវកម្មនោះប្រើប្រាស់ធនធានអ្វីខ្លះ ?

<u>ចម្លើយ</u> *(ឆ្លើយទៅតាមការសង្កេតឃើញរបស់អ្នក)*។

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម ៖

ក.នៅក្នុងសង្គមកម្រិតធនធានសេដ្ឋកិច្ចដែលមាននៅក្នុងគ្រួសារនីមួយៗ តែងមានភាពខុសគ្នាខ្លះ ដូចគ្នាខ្លះ តាមការ

គិតរបស់អ្នក តើអ្វីទៅហៅថា ធនធានសេដ្ឋកិច្ចគ្រួសារ ? ចូរអ្នករៀបរាប់ ។

ខ. ដើម្បីធ្វើអាជីវកម្មណាមួយ គេតែងត្រូវការដើមទុនវិនិយោគ ។ ចំពោះអ្នកប្រសិនបើអ្នកចង់ធ្វើអាជីវកម្មមួយ តើអាជីវកម្មនោះជាអាជីវកម្មអ្វី?តើអាជីវកម្មនោះត្រូវការអ្វីជាដើមទុនវិនិយោគ?តើអ្នកបង្កើតដើមទុនវិនិយោគដោយរបៀបណា ?

គ. ដូចម្តេចដែលហៅថា ការវិនិយោគទុន ? តើគេអាចបង្កើតវិនិយោគទុនដោយវិធីណាខ្លះ ?

ឃ. ប្រសិនបើអ្នកមានប្រាក់សន្សំ តើអ្នកនឹងប្រើប្រាស់ប្រាក់នោះជាដើមទុនដើម្បីវិនិយោគតាមវិធីណា ?

<u>ចម្លើយ</u> ពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម ៖

ក. នៅក្នុងសង្គមកម្រិតធនធានសេដ្ឋកិច្ចដែលមាននៅក្នុងគ្រួសារនីមួយៗ តែងមានភាពខុសគ្នាខ្លះ ដូចគ្នាខ្លះ តាមការគិតរបស់ខ្ញុំ ដែលហៅថា ធនធានសេដ្ឋកិច្ចគ្រួសារ គឺជាធនធានទាំងឡាយណាដែលគ្រួសារនីមួយៗប្រើប្រាស់ក្នុងការ

ផលិតទំនិញឬផ្តល់សេវាកម្មដែលនឹងនាំមកនូវប្រាក់ចំណូលសម្រាប់គ្រួសារ ។

ខ. *(ឆ្លើយទៅតាមការចាប់អារម្មណ៍របស់សិស្សម្នាក់)* ។

គ. ដែលហៅថា ការវិនិយោគទុន គឺ ជាការបណ្តាក់ទុនធ្វើអាជីវកម្មដើម្បីបង្កើតប្រាក់ចំណូល ។ គេអាចបង្កើតវិនិយោគទុនដោយៈ

- សន្សំទុនដោយលះបង់ការប្រើប្រាស់បច្ចុប្បន្នដើម្បីទទួលបានការប្រើប្រាស់ (ច្រើនជាង) ឬដើម្បីរកបាននូវទំនិញមូលធនក្នុងពេលអនាគត
- បង្កើនម៉ោងការងារ ដើម្បីបង្កើនប្រាក់កម្រៃពលកម្ម
- រក្សាទុកប្រាក់ចំណេញដែលបានពីអាជីវកម្មបច្ចុប្បន្ន
- ប្រមូលយកប្រាក់សន្សំឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនធ្វើជាទុនអាជីវកម្មថ្មីមួយ
- ខ្ចីប្រាក់ពីធនាគារដែលបម្រើសេវាកម្មផ្តត់ផ្គង់ឥណទានខ្នាតតូច ដើម្បីធ្វើជាទុន
- ទិញទំនិញផលិតកម្ម ឬកម្មវត្ថុផលិតកម្មដោយការជឿបណ្តាក់ ដើម្បីធ្វើជាដើមទុន

▪ ស្វែងរកធនធានធម្មជាតិដែលអាចរកបាន នៅក្នុងសហគមន៍ដោយស្របច្បាប់ដើម្បីធ្វើជាដើមទុន ហើយច្នៃផលិតផលទំនិញ ដូចជា ទឹកស្អាត ឥដ្ឋ វល្លិ ឈើ ខ្សាច់ គ្រួស ឬ វាលស្បូវ ។ល។

▪ ប្រើប្រាស់កម្លាំងផ្ទាល់ខ្លួនក្នុងការបម្រើសេវាកម្មស្របច្បាប់ផ្សេងៗ ដើម្បីយកកម្រៃសន្សំជាដើមទុនសម្រាប់បង្កើតអាជីវកម្មមួយទៅអនាគត... ។

ឃ. ប្រសិនបើខ្ញុំមានប្រាក់សន្សំ ខ្ញុំនឹងប្រើប្រាស់ប្រាក់នោះជាដើមទុនដើម្បីវិនិយោគតាមវិធី បង្វិលទុនវិនិយោគ ។

## សំណួរបញ្ចប់ជំពូក ៣

. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. ការបង្កើតអាជីវកម្មសេវាកម្មគ្រប់ប្រភេទតែងមានទំនាក់ទំនងទៅនឹង

☐ ក. កត្តាបម្រែបម្រួលសេដ្ឋកិច្ច

☐ ខ. កត្តាបង្កើតប្រាក់ចំណូល

☐ គ. កត្តាការប្រកួតប្រជែង

☐ ឃ. កត្តាតម្រូវការរបស់អ្នកប្រើប្រាស់ ។

២. សារប្រយោជន៍សហគ្រិនគ្រួសារគឺ

☐ ក. បង្កើតប្រាក់ចំណូលក្នុងគ្រួសារ ☐ ខ. បង្កើតការងារ

☐ គ. បង្កើតជ័យជំនះ ☐ ឃ. បង្កើនកម្មករ ។

៣.ការប្រកួតប្រជែងក្នុងអាជីវកម្មជាមូលហេតុជម្រុញអាជីវករ

☐ ក. បង្កជម្លោះនឹងគ្នា

☐ ខ. បង្កើតអាជីវកម្មផ្តាច់មុខ

☐ គ. លើកកម្ពស់គុណភាពផលិតកម្ម

ឬសេវាកម្មរបស់ខ្លួន ។

II. ចូរ បំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

១. អាជីវកម្មមាន .....................ប្រភេទគឺ .................. ។

២.ក្រុមហ៊ុនជាអង្គភាព..........និងមានការ.....................ពីរដ្ឋាភិបាល។

៣. ការ........ថ្លៃទំនិញ អាចធ្វើឱ្យអាជីវករដាច់ទំនិញបានច្រើន ។

៤.ដើម្បីមានការគាំទ្រយូរអង្វែងសហគ្រាសមួយត្រូវមាន.....និង........ ។

III. ចូរឆ្លើយនឹងសំណួរខាងក្រោម

១. តើគេអាចបង្កើតអាជីវកម្មឯកកម្មសិទ្ធិដោយវិធីណា ?

២. តើអាជីវកម្មធុនតូចនៅកម្ពុជាមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

៣. តើអ្វីខ្លះ ជាប្រភពជោគជ័យនៃអាជីវកម្មធុនតូច ?

៤. តើអ្វីខ្លះ ត្រូវរាប់ថាជាធនធានសេដ្ឋកិច្ចគ្រួសារ ?

IV. ចូរបកស្រាយប្រធានបទដូចខាងក្រោម ៖

សហគ្រិនម្នាក់មានបំណងបង្កើត អាជីវកម្មធុនតូចមួយ ផ្នែកកសិដ្ឋានចិញ្ចឹមគោ ។ តើគាត់ត្រូវរៀបចំទុនដូចម្ដេច ? តើគាត់ត្រូវដោះស្រាយបញ្ហាអ្វីខ្លះ ដើម្បីឱ្យអាជីវកម្មរបស់គាត់ទទួល

បានជោគជ័យ ? ហើយគាត់ត្រូវធ្វើយ៉ាងណា ដើម្បីធានាជោគជ័យយូរអង្វែង ?

ចម្លើយ

I. គូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ

១. ការបង្កើតអាជីវកម្មសេវាកម្មគ្រប់ប្រភេទតែងមានទំនាក់ទំនងទៅនឹង

☑ ក. កត្តាបម្រែបម្រួលសេដ្ឋកិច្ច

☑ ខ. កត្តាបង្កើតប្រាក់ចំណូល

☑ គ. កត្តាការប្រកួតប្រជែង

☑ ឃ. កត្តាតម្រូវការរបស់អ្នកប្រើប្រាស់ ។

២. សារប្រយោជន៍សហគ្រិនគ្រួសារគឺ

☑ ក. បង្កើតប្រាក់ចំណូលក្នុងគ្រួសារ

☑ ខ. បង្កើតការងារ ។

៣. ការប្រកួតប្រជែងក្នុងអាជីវកម្មជាមូលហេតុជម្រុញអាជីវករ

☑គ.លើកកម្ពស់គុណភាពផលិតកម្មឬសេវាកម្មរបស់ខ្លួន ។

II. បំពេញឈ្មោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. *៣* ប្រភេទ គឺ *អាជីវកម្មឯកកម្មសិទ្ធិ ហ៊ុនគ្នាធុនមធ្យម ក្រុមហ៊ុន* ។

២. *អាជីវកម្មស្របច្បាប់* និងមានការ *ទទួលស្គាល់*

៣. *បញ្ចុះ*

៤. *ភាពសុចរិតស្មោះត្រង់* និង *គោរពច្បាប់*

III. ចូរឆ្លើយនឹងសំណួរខាងក្រោម

១. គេអាចបង្កើតអាជីវកម្មឯកកម្មសិទ្ធិដោយ ជ្រើសរើសរកទីកន្លែង (នៅតាមផ្ទះឬនៅតាមទីផ្សារ ) ដែលខ្លួនយល់ថាសមរម្យ នឹងរៀបចំដំណើរការទៅបាន ប៉ុណ្ណោះ ។

២. អាជីវកម្មធុនតូចនៅកម្ពុជាមាន ៤ ប្រភេទ គឺ ៖

- អាជីវកម្មផលិតកម្ម
- អាជីវកម្មលក់ដូរឬជួញដូរ
- អាជីវកម្មសេវាកម្ម
- អាជីវកម្មដាក់ហ៊ុន...។

៣. ប្រភពជោគជ័យនៃអាជីវកម្មធុនតូច គឺ ៖

- អាជីវកម្មមានទុនថវិកា ចំណេះដឹង បទពិសោធន៍ វិជ្ជាជីវៈច្បាស់លាស់ និងមានកម្លាំងពលកម្មគ្រប់គ្រាន់
- មានទីផ្សារសម្រាប់ លក់ផលិតផលឬសេវាកម្ម
- ផលិតផលឬសេវាកម្មមានគុណភាពសមស្របតាមសេចក្ដីត្រូវការ និងការពេញចិត្តរបស់អតិថិជន
- អាជីវករមានបំណិនក្នុងការគ្រប់គ្រងអាជីវកម្ម ធ្វើឱ្យដំណើរការអាជីវកម្មទទួលបានប្រាក់ចំណេញជាប្រក្រតី
- អាជីវករមានអត្តចរិតស្មោះត្រង់ រួសរាយរាក់ទាក់ សមនឹងទទួលបានការគាំទ្រ ពីអតិថិជន
- អាជីវកម្មស្ថិតក្នុងបរិស្ថាន សង្គមដែលមានសន្តិសុខ និងសុវត្ថិភាព
- អាជីវកម្មមានការគាំទ្រ និងលើកទឹកចិត្តពីសំណាក់រដ្ឋាភិបាល ...។

៤. ធនធានសេដ្ឋកិច្ចគ្រួសារ មាន៖

- ដីធ្លី
- ផ្ទះសម្បែង (ទីតាំង)
- គ្រឿងម៉ាស៊ីន ឧបករណ៍ មធ្យោបាយដឹកជញ្ជូន
- កម្លាំងពលកម្ម
- សមត្ថភាព
- ការទំនាក់ទំនង...។

# ចប់សេចក្ដីបរិបូណ៌